សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលរបស់ស្រុកសណ្ដាន់ ខេត្តកំពង់ធំ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ក. ណា ស៊ីវឈាន**
**ក. ពិន ស៊ីឈៃន**

សាស្ត្រាចារ្យណែនាំ
**បណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១៥

ឆ្នាំចូលរៀន ២០១៨
ឆ្នាំសរសេរសារណា ២០២២

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលរបស់ស្រុកសណ្ដាន់ ខេត្តកំពង់ធំ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ក. ណា ស៊ីវឈាន**
**ក. ពិន ស៊ីឈៃន**

សាស្ត្រាចារ្យណែនាំ
**បណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១៥

ឆ្នាំចូលរៀន ២០១៨
ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ ណា ស៊ីវឈាន និង ពិន ស៊ីឈៃន ជានិស្សិតផ្នែកបរិញ្ញាបត្ររដ្ឋបាលសាធារណៈ ជំនាន់ទី ១៥ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៨-២០២២។

**សូមគោរពដឹងគុណ និងថ្លែងអំណរគុណជាអនេកប្បការជូនចំពោះ៖**

- **លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាទូន្មានប្រៀនប្រដៅជួយទំនុកបម្រុងដល់រូបកូនៗ ទាំងស្មារតី និងសម្ភារៈគ្រប់បែបយ៉ាង ជាពិសេសរួមទាំងការផ្តល់ដំបូន្មានល្អៗរបស់លោកដល់រូបកូន ចាប់តាំងពីពេលកូននៅជាកុមាររហូតដល់ធំដឹងក្តី និងបានទទួលបានការបណ្តុះបណ្តាលថ្នាក់ឧត្តមសិក្សា ហើយបានបញ្ចប់ការសិក្សាជាស្ថាពរជាមួយនិងការទទួលបានលទ្ធផលជាទីគាប់ប្រសើរថែមទៀត។ លោកទាំងពីរបានប្រឹងអស់ទាំងកំលាំងកាយ និងកម្លាំងចិត្តរបស់លោកទាំងពីរមិនរុញរា លោកខិតខំពុះពារទាំងថ្ងៃទាំងយប់ ធ្វើយ៉ាងណាឱ្យកូនទទួលបានលទ្ធផលល្អដូចសព្វថ្ងៃ តាមរយៈការខិតខំអស់ពីកម្លាំងកាយចិត្តរបស់លោកទាំងពីរនេះហើយ បានធ្វើឱ្យកូនមិនអាចបំភ្លេចជារៀងរហូត។
- ឯកឧត្តមបណ្ឌិត **លុយ ចន្ណា** សាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរសអស់លោក លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានសមត្ថភាពខ្ពង់ខ្ពស់ និងជួយតម្រង់ទិសយើងខ្ញុំតាំងពីឆ្នាំសិក្សាមូលដ្ឋានរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រប្រកបដោយគុណភាព។
- លោកសាស្ត្រាចារ្យបណ្ឌិត **អ៊ុន សកក្កដា** ដែលជាសាស្ត្រាចារ្យដ៏ឆ្នើម និងជាសាស្ត្រាចារ្យគំរូប្រកបដោយព្រហ្មវិហារធម៌ គុណធម៌ សីលធម៌ លោកគ្រូបានដឹកនាំបង្ហាត់បង្ហាញពីគំនិត និងវិធីសាស្ត្រល្អៗទាក់ទងនឹងប្រធានបទ រួមទាំងការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកគ្រូ តាំងពីដើមរហូតដល់បញ្ចប់ការសិក្សាស្រាវជ្រាវនេះ។

ចុងក្រោយនាងខ្ញុំទាំងពីរនាក់ពិតជាមិនអាចបំភ្លេចបាននូវគុណូបការៈដ៏ធំធេងនេះបានឡើយ ហើយសូមប្រសិទ្ធិពរជ័យជូនលោកឪអ្នកម្តាយ ឯកឧត្តម លោក លោកស្រី ឱ្យមានសុខភាពល្អជាពិសេសទទួលបាននូវជោគជ័យគ្រប់ភារកិច្ច ហើយសូមឱ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណរគុណ

សារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ **ការគ្រប់គ្រងរដ្ឋបាលរបស់ស្រុកសណ្ដាន់ ខេត្តកំពង់ធំ** គឺជាប្រធានបទមួយដែលត្រូវបានស្រាវជ្រាវដោយនាងខ្ញុំ ណា ស៊ីវឈាន និង ពិន ស៊ីឈៃនជានិស្សិត ជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី១៥ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមការដឹកនាំរបស់សាស្ត្រាចារ្យបណ្ឌិត **អ៊ុន សកក្កដា**។

សារណានេះពិតជាមានសារៈសំខាន់ណាស់សម្រាប់និស្សិតរដ្ឋបាលសាធារណៈដូចនាងខ្ញុំ ក្នុងការសិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅ និងចងក្រងទុកជាឯកសារ។ នាងខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយយ៉ាងខ្លាំងក្នុងការចំណាយនូវកម្លាំងកាយចិត្ត ពេលវេលា និងធនធានផ្ទាល់ខ្លួន ដើម្បីរៀបចំចងក្រងនូវកិច្ចការនៃសារណាមួយនេះឱ្យលេញចេញជារូបរាងឡើង ព្រោះកិច្ចការមួយនេះបានធ្វើឱ្យខ្ញុំចេះធ្វើកិច្ចការស្រាវជ្រាវយ៉ាងសកម្មដែលបានបង្កើតនូវចំណេះដឹងមូលដ្ឋាន បណ្ដុះគំនិតប្រាជ្ញា និងមានការយល់ដឹងកាន់តែច្បាស់អំពីប្រធានបទមួយនេះ។

នាងខ្ញុំសង្ឃឹម និងរំពឹងទុកជាមុនថា កិច្ចការមួយនេះនឹងក្លាយទៅជាប្រយោជន៍សម្រាប់មជ្ឈដ្ឋានអ្នកស្នេហាការសិក្សាទាំងឡាយ មិត្តនិស្សិត ក៏ដូចជាសិស្សជំនាន់ក្រោយ ដោយចូលរួមក្នុងការបង្កើននូវពុទ្ធិចំណេះដឹងមូលដ្ឋានរបស់អ្នកគ្រប់គ្នា។ តាមរយៈសារណានេះដែរ ក៏អាចចូលរួមចំណែកក្នុងការពង្រឹងនៃការគ្រប់គ្រងរបស់រដ្ឋបាលផងដែរ។

ដោយសារតែចំណេះដឹងនៅមានកម្រិត ដូច្នេះក្រុមនាងខ្ញុំនៅជឿជាក់ថាកំហុសនៅតែកើតមានឡើងដោយជៀសពុំរួចនោះឡើយ ទាំងអត្ថន័យខ្លឹមសារ ពាក្យពេជឃ្លាឃ្លោង ទាំងអក្ខរាវិរុទ្ធ និងបច្ចេកទេសនៃការចងក្រងនៅមានកម្រិតផងនោះ។

អាស្រ័យហេតុដូចនេះ នាងខ្ញុំសូមការខន្តីអភ័យទោសចំពោះកំហុសខុសឆ្គងដែលនឹងអាចកើតមានឡើងដោយប្រការណាមួយពីសំណាក់ ឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ ហើយមានសេចក្ដីសោមនស្សរីករាយឥតឧបមាក្នុងការទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនា និងកែលំអ បំពេញចន្លោះខ្វះខាតនៅក្នុងអត្ថបទសារណានេះដើម្បីធ្វើឱ្យខ្លឹមសារ និងអត្ថបទសារណានេះកាន់តែល្អ និងស៊ីជម្រៅថែមទៀតពីសំណាក់ ឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................ ១

## ជំពូកទី១
## ស្ថានភាពទូទៅរបស់រដ្ឋបាលស្រុកសណ្តាន់ ខេត្តកំពង់ធំ

**១.១. ប្រវត្តិរបស់រដ្ឋបាលស្រុកសណ្តាន់ ខេត្តកំពង់ធំ** ........................................ ៦

១.១.១.លក្ខណៈភូមិសាស្រ្ត ........................................ ៦

១.១.២.លក្ខណៈប្រជាសាស្រ្ត ........................................ ៧

១.១.៣.ស្ថានភាពបច្ចុប្បន្នរបស់ស្រុកសណ្តាន់ ........................................ ៧

**១.២. ចក្ខុវិស័យ** ........................................ ១១

១.២.១. ប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ........................................ ១១

១.២.២.ប្រភេទសេវាសាធារណៈ ........................................ ១៣

១.២.៣. ការពង្រឹងគុណភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ........................................ ១៦

**១.៣. គោលដៅ** ........................................ ១៧

១.៣.១. គោលបំណងអភិវឌ្ឍ ........................................ ១៧

១.៣.២. គោលដៅអភិវឌ្ឍ ........................................ ១៧

១.៣.៤. ការអភិវឌ្ឍមូលដ្ឋាននៅថ្នាក់ស្រុក ........................................ ១៩

១.៣.៥. ការធ្វើសណ្តាប់ធ្នាប់សាធារណៈ ឱ្យកាន់តែល្អប្រសើរ ........................................ ២១

**១.៤. បេសកកម្ម** ........................................ ២២

១.៤.១. ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ........................................ ២៣

## ជំពូកទី២
## ការគ្រប់គ្រងរបស់រដ្ឋបាលស្រុកសណ្តាន់ ខេត្តកំពង់ធំ

**២.១. សញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាលសាធារណៈ** ........................................ ២៣

២.១.១. និយមន័យ ........................................ ២៤

២.១.២.គោលការណ៍នៃការគ្រប់គ្រង ........................................ ២៧

២.១.៣. មុខងាររដ្ឋបាល ........................................ ៣២

**២.២. រចនាសម្ព័ន្ធ និងតួនាទីរដ្ឋបាល ស្រុក** ........................................ ៣៣

២.២.១. ក្រុមប្រឹក្សា និងគណៈអភិបាល ............................................................................................... ៣៥
២.២.២. ការគាំទ្រនិងទំនាក់ទំនងរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ជាមួយក្រសួង ស្ថាប័ន .................. ៤១
២.២.៣. គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាស្រុក និងនាយករដ្ឋបាលសាលាស្រុក ............................ ៤៣
២.២.៤. ការិយាល័យទាំង១៣ក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលសាលាស្រុក........................................... ៤៤
២.២.៥. របៀបរបបធ្វើការងាររបស់ការិយាល័យចំណុះសាលាស្រុក-ក្រុង.............................................. ៥៣
**២.៣. យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍ** ........................................................................................ ៥៤
២.៣.១.គោលការណ៍សំខាន់ៗនៃការកសាងផែនការអភិវឌ្ឍ .............................................................. ៥៧
២.៣.២. កម្មវិធីវិនិយោគស្រុក ឃុំសង្កាត់.......................................................................................... ៥៧
**២.៤.សមិទ្ធិផល និងការតាមដានវាយតម្លៃនៃការអនុវត្តផែនការអភិវឌ្ឍស្រុក**....... ៥៨
**២.៥.បញ្ហាប្រឈម និងដំណោះស្រាយ** ....................................................................................... ៥៩
២.៥.១.បញ្ហាប្រឈម.......................................................................................................................... ៦០
២.៥.២. ដំណោះស្រាយ....................................................................................................................... ៦១
**សេចក្តីសន្និដ្ឋាន** .......................................................................................................៦២
**អនុសាសន៍** ...............................................................................................................៦៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ការគ្រប់គ្រងរដ្ឋបាល គឺជាផ្នែកមួយដ៏សំខាន់បំផុតក្នុងការគ្រប់គ្រង និងអភិវឌ្ឍនៅក្នុង អង្គភាព ស្ថាប័ន ឬ ក្នុងប្រទេសទាំងមូលមិនថាប្រទេសអភិវឌ្ឍ ឬកំពុងអភិវឌ្ឍនោះទេ គឺត្រូវមានការរៀបចំប្រព័ន្ធរដ្ឋបាល។ ក្រោមការ ដឹកនាំដ៏ឈ្លាសវៃរបស់រាជរដ្ឋាភិបាលប្រទេសកម្ពុជាទទួលជោគជ័យយ៉ាងឆាប់រហ័សលើគ្រប់វិស័យទាំង វិស័យ សេដ្ឋកិច្ច វិស័យសង្គមកិច្ច និងវប្បធម៌ ហើយត្រូវបានវាយតម្លៃថាជាប្រទេសជាប់លំដាប់ថ្នាក់លេខ ០៥ ក្នុងចំ ណាត់ប្រទេសកំពង់អភិវឌ្ឍសហស្សវត្ស ព្រមទាំងជាប្រទេសដែលជាប់ចំណាត់ថ្នាក់លេខ ០១ នៅតំបន់អាស៊ីប៉ា ស៊ីហ្វិក ដែលសម្រេចបាននូវវឌ្ឍនភាពដ៏ល្អប្រសើរក្នុងការលើស្ទួយផ្នែកសេដ្ឋកិច្ច។

ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍរាជរដ្ឋាភិបាលកម្ពុជា ក៏បានធ្វើការកំណែទម្រង់គោនយោបាយនាពេល បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះផ្នែកសេវាសាធារណៈ ស្ថេរភាពនយោបាយ សណ្តាប់ធ្នាប់ និងសន្តិសុខ ដើម្បីឱ្យសមស្របទៅនឹងការអភិវឌ្ឍរបស់សង្គមជាតិទាំងមូល។ រាជរដ្ឋាភិបាល កម្ពុជាបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់រិះរកវិធីសាស្ត្រណាដែលមានប្រសិទ្ធភាពខ្ពស់អាចផ្តល់សេវាជូនប្រជា ពលរដ្ឋឱ្យបានឆាប់រហ័ស មានភាពងាយស្រួល និងទាន់ពេលវេលា។ ដូច្នេះរាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវ គោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការ។ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ មានគោលដៅ អភិវឌ្ឍគ្រឹះលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន និងលើកកម្ពស់សិទ្ធិសេរីភាពប្រជាពលរដ្ឋ។ ការរៀបចំរដ្ឋបាល ថ្នាក់មូលដ្ឋាន ឬអាជ្ញាធរដែនដីនៃប្រទេសកម្ពុជាបែងចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ ការ បែងចែកនេះត្រូវទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។ បច្ចុប្បន្ននេះរាជរដ្ឋាភិបា លមានយុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់កាត់បន្ថយភាពក្រីក្រ ព្រមទាំងខិតខំស្វែងរកនូវគន្លឹះថ្មីៗក្នុងការជួយកសាង និងអភិវឌ្ឍប្រទេសជាតិទាំងមូល។ អាជ្ញាធរដែនដីជាមណ្ឌលរដ្ឋបាលមូលដ្ឋាន ចំណុះផ្ទាល់ឱ្យក្រសួង មហាផ្ទៃផង ដែលជាតំណាងឱ្យរដ្ឋាភិបាលដែលមានសមត្ថកិច្ច ក្នុងការគ្រប់គ្រងសណ្តាប់ធ្នាប់ការពារដែនដី ព្រមទាំង សន្តិសុខសាធារណៈ និងមានភារកិច្ចអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបា លកម្ពុជា ក៏ដូចជា ព្រះរាជក្រឹត្យ ប្រកាសនិងសេចក្តីណែនាំផ្សេងៗ ព្រមទាំងជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច វប្ប ធម៌ វិទ្យាសាស្ត្រ ការលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការការពារសិទ្ធិមនុស្ស បេតិកភ័ណ្ឌជាតិ និង ការពារបរិស្ថានធម្មជាតិ ក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួនផង។ កម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលមាន គោលបំណងផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ពង្រឹងលទ្ធិប្រជាធិបតេយ្យចាប់ពីថ្នាក់មូលដ្ឋាន និង អភិវឌ្ឍខេត្ត ក្រុងដោយខ្លួនឯងផ្ទាល់។ ជាពិសេសបានឆ្លុះបញ្ចាំងពីទំនាក់ទំនងយ៉ាងជិតស្និតរវាងប្រជាពលរដ្ឋ និងអាជ្ញាធរដែនដីនៅក្នុងមូលដ្ឋានរបស់ខ្លួនដែលឈានឆ្ពោះទៅរកភាពសហការគ្នា ដោយមានការរាក់ទាក់ស្និត

ស្នាលទាំងការងាររដ្ឋ ទាំងការទំនាក់ទំនងគ្នា សន្តិសុខ សណ្តាប់ធ្នាប់ ព្រមទាំងការអភិវឌ្ឍដែលនាំឱ្យ ខេត្ត ក្រុង មានការរីកចម្រើនពោពេញដោយមោទនភាព និងប្រកបដោយនិរន្តរភាពផងដែរ។

បច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជា មានរាជធានី០១ ខេត្ត២៤ ស្រុក១៥៩ ក្រុង២៦ ខណ្ឌ១៤ ឃុំ១៤០៦ និងសង្កាត់ ២២៧។ ខេត្តដែលទើបនឹងបង្កើតថ្មី គឺខេត្តត្បូងឃ្មុំ ដែលជាតំបន់បំបែកចេញពីខេត្តកំពង់ចាម។ ភូមិ មិនមែនជាផ្នែកមួយនៃរដ្ឋបាលដែនដីរបស់ប្រទេសកម្ពុជាទេ។ បច្ចុប្បន្ននេះ ចំនួនសរុបដែលត្រូវបានកត់ត្រា ដោយក្រសួងមហាផ្ទៃ មាន ១៤,១៦៨ ភូមិ។ ការរៀបចំ និងការប្រព្រឹត្តិទៅនៃរដ្ឋបាលដែនដី ត្រូវកំណត់នៅក្នុង ច្បាប់រៀបចំអង្គការ។ រដ្ឋបាលស្រុក ឃុំ/សង្កាត់ ត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលស្រុក ឃុំ សង្កាត់។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្នុងប្រទេសកម្ពុជាយើង មានការបែងចែកអំណាចតាមលំដាប់នៃការគ្រប់គ្រង នយោបាយវិសហមជ្ឈការ និង វិមជ្ឈការ ឱកាសដល់ប្រជាពលរដ្ឋឱ្យចូលរួមកាន់តែទូលំទូលាយនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនានានៅ ក្នុងមូលដ្ឋានរបស់ខ្លួនដើម្បីធ្វើការស្រាវជ្រាវប្រធានបទ ការគ្រប់គ្រងរដ្ឋបាល របស់សាលាស្រុក ឱ្យបានកាន់តែ ស៊ីជម្រៅ និងច្បាស់លាស់ ចំណោទបញ្ហាត្រូវបានលើកឡើងថា៖

- ❖ តើការគ្រប់គ្រងរដ្ឋបាលស្រុកមានលក្ខណៈបែបណាខ្លះ? តើគណៈអភិបាលស្រុកមាន វិធីសាស្ត្របែបណាដើម្បី ដំណើរការនៃការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព និងគុណភាពខ្ពស់?
- ❖ តើអាជ្ញាធរដែនដីមានវិធីសាស្ត្របែបណាខ្លះដើម្បីជំរុញដល់ការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន? តើមានផលប៉ះពាល់ដល់ការអនុវត្តការងារបែបណាខ្លះ? ហើយតើការអនុវត្តន៍ការងារបានដល់កម្រិតណា?
- ❖ តើប្រជាពលរដ្ឋមានការចំណែកចូលរួមសកម្មភាពក្នុងការអភិវឌ្ឍសហគមរបស់ខ្លួនដល់ណា?

ចំណោទបញ្ហានៃការស្រាវជ្រាវបានបញ្ចប់ ដូច្នេះហើយដើម្បីឱ្យកាន់តែស៊ីជម្រៅឈានចូលដល់គោល បំណងនៃការស្រាវជ្រាវបន្តទៀត។

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះគឺ មានគោលបំណងនៅក្នុងការរួមចំណែកបង្កើតនូវចំណេះដឹង ដល់ក្រុមយើងខ្ញុំដែលបានធ្វើការសិក្សាស្រាវជ្រាវទាំងអស់គ្នាព្រមទាំងបានយល់ដឹងកាន់តែច្បាស់ពីការគ្រប់គ្រង រដ្ឋបាលនៅសាលាស្រុកសណ្តាន់ផងដែរ ហើយវាក៏ជាឯកសារមួយសម្រាប់តម្កល់ទុកក្នុងសាកលវិទ្យាល័យ ដើម្បីឱ្យនិស្សិតជំនាន់ក្រោយបានធ្វើការសិក្សាស្វែងយល់។ គោលបំណងចម្បងនៃការសិក្សាស្រាវជ្រាវនឹងផ្តោត ទៅលើចំណុចសំខាន់ដូចជា៖

- ➢ សិក្សាទៅលើការគ្រប់គ្រងរដ្ឋបាលនៅស្រុកសណ្តាន់

- សិក្សាទៅលើដំណើរការផ្តល់សេវាសាធារណៈនៅសាលាស្រុកសណ្តាន់
- ការសិក្សាពីគោលការណ៍អភិបាលកិច្ចល្អរបស់សាលាស្រុកសណ្តាន់
- ការសិក្សាពីបរិបទជុំវិញក្នុងស្រុកសណ្តាន់
- សិក្សាទៅលើការសាមគ្គីភាពរវាងប្រជាពលរដ្ឋនិងរដ្ឋបាលស្រុក ដើម្បីឈានឆ្ពោះទៅរកការអភិវឌ្ឍ កិច្ចការសិក្សាស្រាវជ្រាវនេះផងដែរគឺយើងធ្វើការវិភាគទៅលើបញ្ហា និងដំណោះស្រាយទាំងអស់នៃការគ្រប់គ្រងរដ្ឋបាលរបស់សាលាស្រុកសណ្តាន់ដើម្បីស្វែងរកចំណុចខ្វះខាត និងកែលម្អបន្ទាប់មកធ្វើសេចក្តីសន្និដ្ឋាន ទៅលើគ្រប់ចំណុចព្រមទាំងផ្តល់អនុសាសន៍ផងដែរ បំណងនៃការសិក្សាស្រាវជ្រាវត្រូវបានបញ្ចប់ឈានចូលដល់ការកំណត់ពីទំហំនៃវិសាលភាពនៃការសិក្សាស្រាវជ្រាវវិញ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំគឺសិក្សាផ្តោតទៅលើការគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលស្រុកសណ្តាន់ ស្ថិតនៅក្នុងខេត្តកំពង់ធំ ហើយទិន្នន័យដែលក្រុមយើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវគឺចាប់ពី ខែមករា ឆ្នាំ២០១៩ រហូតដល់ខែធ្នូឆ្នាំ២០២០ តែប៉ុណ្ណោះ។ ការកំណត់នូវទំហំ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវធ្វើឱ្យយើងមានភាពងាយស្រួលក្នុងការកំណត់វិធីសាស្ត្រនៃការស្រាវជ្រាវ។ ទំហំនិងវិសាលភាពនៃការសិក្សាស្រាវជ្រាវត្រូវបានបញ្ចប់ក៏ឈានចូលដល់វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវបន្ថែមទៀត។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ នៅក្នុងការសិក្សាស្រាវជ្រាវអំពីប្រធានបទ "**ការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលស្រុកសណ្តាន់**" នេះក្រុមយើងខ្ញុំបានលើកយកវិធីសាស្ត្រមួយចំនួនដើម្បីធ្វើការស្វែងរកពីចំណុចខ្លះៗ។ ហើយវិធីសាស្ត្រដែលក្រុមយើងខ្ញុំចង់លើកយកមកធ្វើការសិក្សាបែងចែកជា ២ ផ្នែកគឺវិធីសាស្ត្រប្រមូលទិន្នន័យ និងវិធីសាស្ត្រវិភាគទិន្នន័យ។

### ក. វិធីសាស្ត្រប្រមូលទិន្នន័យ

ក្នុងការប្រមូលទិន្នន័យនេះ ក្រុមយើងខ្ញុំបានធ្វើការបែងចែកជាពីរទិន្នន័យដើម្បីយកមកសិក្សាបន្ថែមទៀតគឺ ទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។

**ទិន្នន័យចម្បងគឺជាទិន្នន័យទទួលបានពី៖**ការជួបសម្ភាសន៍ដោយផ្ទាល់ជាមួយប្រធានក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សាស្រុកសណ្តាន់ និងគណៈអភិបាលនៃអភិបាលស្រុកសណ្តាន់ និងសុំការណែនាំបន្ថែមពីលោកគ្រូសាស្ត្រាចារ្យដឹកនាំរបស់ក្រុមយើងខ្ញុំ។

**ទិន្នន័យបន្ទាប់បន្សំ គឺជាទិន្នន័យដែលទទួលបានពី៖**

- ការប្រមូលឯកសារពីសាលាស្រុក។
- ឯកសារគតិយុត្ត(ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីណែនាំ និងសៀវភៅដែលទាក់ទងទៅនិងការគ្រប់គ្រងរដ្ឋបាលនៅប្រទេសកម្ពុជា)។
- ឯកសារពីសាស្ត្រាចារ្យដឹកនាំ។
- ឯកសារដែលយើងខ្ញុំធ្លាប់បានសិក្សាពីមុនៗមក។
- និងឯកសារខ្លះទៀតក្រុមយើងខ្ញុំបានធ្វើការស្រាវជ្រាវតាមប្រព័ន្ធ Internet ឬវេបសាយណាមួយដើម្បីបានជាឯកសារបន្ថែមសម្រាប់ធ្វើឱ្យប្រធានបទកាន់តែមានន័យទូលំទូលាយបន្ថែមទៀត។

**ខ.វិធីសាស្ត្រវិភាគទិន្នន័យ**

នៅក្នុងការវិភាគទិន្នន័យដែលប្រមូលបាន គឺក្រុមយើងខ្ញុំបានធ្វើការវិភាគតាមបែបគុណភាពដោយផ្អែកលើការវិភាគភាពខ្លាំងភាពខ្សោយ ឱកាស និងការគំរាមកំហែង ដើម្បីធ្វើការវិភាគពី ការគ្រប់គ្រងរបស់រដ្ឋបាលសាលាស្រុកសណ្តាន់ ខេត្តកំពង់ធំ។ វិធីសាស្ត្រនៃការស្រាវជ្រាវត្រូវបានបញ្ជាប់ឈានចូលដល់សារៈសំខាន់នៃការសិក្សាស្រាវជ្រាវវិញម្តង។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ដើម្បីធ្វើឱ្យយើងដឹងពីស្ថានភាពទូទៅ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលរបស់សាលាស្រុកសណ្តាន់ ហើយពិសេសជាងនេះទៅទៀតគឺបានផ្តល់នូវចំណេះដឹងនិងចំណេះ ធ្វើក៏ដូចជាបទពិសោធន៍ពីការគ្រប់គ្រងរដ្ឋបាល។ ម្យ៉ាងទៀតដើម្បីបំពេញបន្ថែមនូវចំណុចខ្វះខាតដែលកើតឡើងក្នុងការគ្រប់គ្រងរដ្ឋបាលនិងបានផ្តល់សារៈសំខាន់ជាច្រើនដូចជា៖

- ដើម្បីធ្វើឱ្យក្រុមយើងខ្ញុំពង្រឹងនូវចំណេះដឹងដែលបានពី សិក្សាកន្លងមក
- ដើម្បីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈដោយជោគជ័យ
- ដើម្បីដកស្រង់នូវបទពិសោធន៍ថ្មីៗនៃផ្នែកទ្រឹស្តីជាមួយនឹងការអនុវត្តជាក់ស្តែង
- ដើម្បីបង្កើនសមត្ថភាពឱ្យបានសមស្របសម្រាប់តម្រូវការរបស់សង្គម
- ដើម្បីកាត់បន្ថយភាពខ្វះខាតមួយចំនួនដែលពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាល មូលដ្ឋាន។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវក្រោមប្រធានបទ **ការគ្រប់គ្រងរបស់រដ្ឋបាលសាធារណៈ** នេះត្រូវបានចងក្រងចែកចេញតាមប្លង់ដូចខាងក្រោម៖

- **ជំពូកទី១ ស្ថានភាពទូទៅរបស់រដ្ឋបាលស្រុក សណ្តាន់ ខេត្តកំពង់ធំ៖** និយាយអំពីស្ថានភាពទូទៅ របស់ស្រុកសណ្តាន់ ប្រវត្តិសាវតារបស់ស្រុកសណ្តាន់ ចក្ខុវិស័យ គោលដៅ និង

បេសកម្មនៃការផ្តល់សេវាសាធារណៈរបស់ស្រុក ។

- **ជំពូកទី២ ការគ្រប់គ្រងរបស់រដ្ឋបាលស្រុក សណ្តាន់៖** នៅក្នុងជំពូកនេះក្រុមនាងខ្ញុំ និង បង្ហាញអំពីចំណុចសំខាន់ៗគឺចំណុចទីមួយបង្ហាញអំពី សញ្ញាណទូទៅនៃការគ្រប់គ្រង់រដ្ឋបាល រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលស្រុក យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍ សមិទ្ធផល និងការតាមដានវាយតម្លៃលើការអនុវត្តការងាររបស់ស្រុក បញ្ហាប្រឈម និងដំណោះស្រាយ។

# ជំពូកទី១
# ស្ថានភាពទូទៅរបស់រដ្ឋបាលស្រុក
# សណ្តាន់ ខេត្តកំពង់ធំ

# ជំពូកទី១
# ស្ថានភាពទូទៅរបស់រដ្ឋបាលស្រុកសណ្ដាន់ ខេត្តកំពង់ធំ

## ១.១. ប្រវត្តិរបស់ស្រុកសណ្ដាន់ ខេត្តកំពង់ធំ

ស្រុកសណ្ដាន់ គឺជាស្រុកដាច់ស្រយ៉ាលមួយក្នុងចំណោមក្រុងស្រុកទាំង ៩ នៃខេត្តកំពង់ធំ។ ហើយមានចម្ងាយ៨៥គីឡូម៉ែត្រពីទីរួមខេត្ត និង ផ្លូវទឹកប្រវែង២៥០គីឡូម៉ែត្រ។ មានព្រំប្រទល់ខាងជើងជាប់និង ស្រុករវៀង ខេត្តព្រះវិហារ ខាងត្បូងជាប់និងស្រុកសន្ទុកនិងស្រុកប្រាសាទសំបូរ ខាងលិចជាប់ និងស្រុកប្រាសាទសំបូរ និងស្រុកប្រាសាទបល្ល័ង្គ និងខាងកើតជាប់និងស្រុកសៀមបូកខេត្តស្ទឹងត្រែង និងស្រុកសំបូរ ខេត្តក្រចេះ។ ស្រុកមានឃុំចំនួន ៩មានភូមិចំនួន ៨៤ មានប្រជាពលរដ្ឋសរុប ៦២.៥០៦ នាក់ ស្រី ៣១.៥៦៩នាក់ និងមានផ្ទៃដី៣.១២៤ គ.ម[2]។

នៅទស្សវត្តទី ៣០ ដល់ទស្សវត្សរទី ៧០ ស្រុកសណ្ដាន់ បែងចែកជា ៦ ឃុំ រួមមាន ៖ ឃុំសណ្ដាន់ ,ឃុំឈើទាល , ឃុំងន , ឃុំគោល , ឃុំឫស្សីព្រៃ និង ឃុំរំចេក។ ដែលរួមមានគណៈគ្រប់គ្រងមានងារជាចៅហ្វាយស្រុកចំនួន ៨ រូប។ ទីតាំងស្រុកស្ថិតនៅឃុំសណ្ដាន់ ស្រុកសណ្ដាន់។ ចាប់ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៩រដ្ឋបាលស្រុកត្រូវបានគ្រប់គ្រងដោយ របបកម្ពុជាប្រជាអធិបតេយ្យដែលមាន ថ្នាក់ដឹកនាំស្រុក ជាកម្មាភិបាលចំនួន ៩ រូប ទីតាំងស្រុក ស្ថិតនៅឃុំសណ្ដាន់ដដែល។ ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ ១៩៨០ ស្រុកសណ្ដាន់ត្រូវបានរំដោះចេញពីរបបខ្មែរក្រហម ពេលនោះទីតាំងស្រុក គឺស្ថិតនៅឃុំមានជ័យ។ បានដឹកនាំដោយអភិបាលស្រុក២រូប ចាប់ពីចុងឆ្នាំ ១៩៨០ ដល់ឆ្នាំ ២០១៩ នេះ ទីតាំងស្រុកត្រូវបានផ្លាស់ប្ដូរមកនៅទីរួមស្រុកសណ្ដាន់ នៅក្នុងឃុំ សណ្ដាន់ រហូតដល់បច្ចុប្បន្ននេះវិញ។[1] នាពេលបច្ចុប្បន្នមានឃុំចំនួន ៩ ឃុំ ៖ ឃុំឈើទាល ,ឃុំដងកាំបិត ,ឃុំក្លែង ,ឃុំមានរិទ្ធ ,ឃុំមានជ័យ ,ឃុំងន ,ឃុំសណ្ដាន់ ,ឃុំសុចិត្រ និងឃុំទំរីងដែលមានអភិបាលស្រុកដឹកនាំបន្តបន្ទាប់សរុបចំនួន៨ រូប។[2]

### ១.១.១. លក្ខណៈភូមិសាស្ត្រ

ស្រុកសណ្ដាន់ មានផ្ទៃដីសរុបចំនួន ៣.១២៤គ.ម² យោងតាមឯកសារស្ថានភាពស្រុកឆ្នាំ២០១៩ ផ្ទៃដីស្រូវវស្សាមានចំនួន ៧.៩៣២ ហ.ត ស្រូវប្រាំង ៣៣៨ហ.តា។

សាលាស្រុកសណ្ដាន់មានស្ថានភាពភូមិសាស្ត្រដូចខាងក្រោម៖

[1] ឯកសារព័ត៌មាន ប្រវត្តិរបស់រដ្ឋបាលស្រុក សណ្ដាន់ ឆ្នាំ ២០១៩

[2] សៀវភៅកម្រងទិន្នន័យឈ្មោះ និងចំនួន ក្រុង ស្រុក ឃុំ សង្កាត់ និងភូមិ ក្នុងខេត្តកំពង់ធំ

| ល.រ | ការបរិយាយ | សរុប | ឯកតា |
|---|---|---|---|
| ១ | ផ្ទៃដីសរុប | ៣.១២៤គ.ម$^{២}$ | ហិតា |
| ២ | ចំនួនឃុំសង្កាត់ | ០៩ | ឃុំ |
| ៣ | ចំនួនភូមិ | ៨៤ | ភូមិ |
| ៤ | ចំនួនគ្រួសារ | ១៤.៤០៤ | គ្រួសារ |
| ៥ | ចំនួនប្រជាពលរដ្ឋ | ៦២.៥០៦ | នាក់ |
| ៦ | ចំនួនប្រជាពលរដ្ឋជាស្ត្រី | ៣១.៥៦៩ | នាក់ |

សាលាស្រុកសណ្តាន់មានទីតាំងស្ថិតនៅបែកខាងលិចឈាងខាងកើតនៃខេត្តកំពង់ធំ៖

- ខាងជើងទល់នឹងឃុំមានជ័យ
- ខាងត្បូងទល់នឹងឃុំឈើទាល
- ខាងលិចទល់នឹងឃុំងន
- ខាងកើតទល់នឹងឃុំសុចិត្រនៃស្រុកសណ្តាន់។

### ១.១.២. លក្ខណៈប្រជាសាស្ត្រ

ស្រុកចែកជា ៩ឃុំ ស្មើ ៨៤ភូមិ មានប្រជាជនសរុប ៦២.៥០៦ នាក់ ស្រី ៣១.៥៦៩ នាក់។ អាយុ១៨ឆ្នាំ ឡើង ៣៥.១០៤នាក់ ស្រី១៨.១៥៧ គ្រួសារសរុប ១៤.៦០៤ គ្រួសារ និងខ្នងផ្ទះមានចំនួន ១២.៦៩៥ខ្នង។ ស្រុកមានប្រជាជនអាយុ ១៨ឆ្នាំឡើងប្រមាណ ៩៤.៣០ % ជាកសិកររស់នៅពឹងផ្អែក លើវិស័យកសិកម្មដែលជាវិស័យ ចម្បងក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងស្រុក។ ក្រៅពីវិស័យកសិកម្មដែលជាស្នូលនឹងជាចម្បង ក៏មានវិស័យផ្សេងៗទៀតដូចជាសិប្បកម្ម០.១៥% និងមានមុខរបរសេវាកម្ម ៤.៨២%។[3]

### ១.១.៣.ស្ថានភាពបច្ចុប្បន្នរបស់ស្រុកសណ្តាន់

សកម្មភាពចម្បងនៅក្នុងផ្នែកសេដ្ឋកិច្ចរួមមាន៖

**ក. អំពីសេវាពាណិជ្ជកម្ម**

ប្រជាជនអាយុ១៨ឆ្នាំឡើងចំនួន៣៥.១០៤នាក់(១២,៩១%) បានប្រកបមុខ របរក្នុងសេវាកម្មនេះ។ ស្រុកមានផ្សារលក់ដូរពេញ១ថ្ងៃ មានចំនួន៤កន្លែង ចំនួនទីតាំងផ្សារខ្នាតតូច ផ្សារលក់១ព្រឹក ឬល្ងាច ចំនួន៤ កន្លែងសម្រាប់ប្រជាជនលក់ដូរ។ ក្រៅពីនេះ ឃុំ ភូមិមួយចំនួនបានរៀបចំផ្សារតូចៗជូនប្រជាជនលក់ដូរ។ ឃុំភាគច្រើន

[3]ឯកសារព័ត៌មាន ប្រវត្តិរបស់រដ្ឋបាលស្រុក សណ្តាន់ ឆ្នាំ ២០១៩

មានកន្លែងលក់ដូរនៅលើចំណីផ្លូវ ឬនៅតាមផ្ទះប្រជាជន។ កសិផលសំខាន់ៗ ត្រូវបានឈ្មួញកណ្តាល ចូលទិញដល់គោលដៅទំនិញមួយចំនួនត្រូវបានឈ្មួញដឹកជញ្ជូនយកទៅលក់ដូរដល់ជនបទ។

**ខ. អំពីផ្សារ**

នៅក្នុងស្រុកមានផ្សារចំនួន ៦ ដែលមានសកម្មភាពធ្វើចរាចរណ៍ទំនិញទៅមកគឺៈ

- ផ្សារសណ្តាន់ មានទីតាំងស្ថិតនៅក្នុងភូមិបាជ័យ ឃុំសណ្តាន់
- ផ្សារមានជ័យ មានទីតាំងស្ថិតនៅភូមិរនាម ឃុំមានជ័យ
- ផ្សារឈើទាល មានទីតាំងនៅភូមិឈើទាល ឃុំឈើទាល
- ផ្សារ៩៩ មានទីតាំងស្ថិតនៅភូមិអូរពកសាមគ្គី ឃុំមានរិទ្ធ
- ផ្សារលើ មានទីតាំងស្ថិតនៅភូមិខោស ឃុំទំរីង
- ផ្សារ ៧មករា មានទីតាំងស្ថិតនៅភូមិខោស ឃុំទំរីង

ក្រៅពីនេះក៏មានផ្សារតិចតួច ដែលមានលក្ខណៈជាតូប លក់ដូរនៅតាមបណ្តាភូមិ-ឃុំនានាផងដែល ។[4]

**គ. ការចិញ្ចឹមសត្វ**

- គ្រួសារចិញ្ចឹមគោ
- គ្រួសារចិញ្ចឹមក្របី
- គ្រួសារចិញ្ចឹមជ្រូក
- គ្រួសារចិញ្ចឹមមាន់

ហើយក៏មានការចិញ្ចឹមទាយកសាច់នៅតាមភូមិ ភាគច្រើនមានពេទ្យសត្វភូមិដែលបានទទួលការបណ្តុះបណ្តាលជាបឋមដើម្បីផ្តល់ប្រឹក្សាដល់ប្រជាជនជួយចាក់ថ្នាំបង្ការនិងជួយព្យាបាលជម្ងឺសត្វ។

**ឃ. ប្រព័ន្ធធារាសាស្ត្រ**

ក្នុងស្រុកមានប្រព័ន្ធធារាសាស្ត្រចំនួន៤គឺ ១.ទំនប់ស្ទាក់ទឹកអូរមៀន ២.អូរទក់ ៣.អាងទឹកអូរក្រញ៉ាក ៤.អូរក្រហមករ ដែលអាចស្រោចស្រពដីស្រែសរុបផ្ទៃដី ២.០៩២ ប្រាំង ៥០ វស្សា ២.០៤២។ ប្រពន្ធធារាសាស្ត្រ **អាងទឹកអូរក្រញ៉ាក** មានលទ្ធភាពស្រោចស្រព ៧០០ ហ.ត នៅរដូវវស្សា និងរដូវប្រាំង។ ប្រពន្ធធារាសាស្ត្រ **អាងទឹកអូរទក់** មានលទ្ធភាពស្រោចស្រព ៣.៨១៦ហាត នៅរដូវវស្សា និងរដូវប្រាំង ៣០០ហាតស្រូវវស្សា ២.៥១៦ហាត ។ ប្រព័ន្ធធារាសាស្ត្រ **ទំនប់ស្ទាក់ទឹកអូរមៀន** មានលទ្ធភាពស្រោច ស្រព ១២៣០.៤២ហាត្ត នៅរដូវវស្សា និងដូ

[4] សៀវភៅផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ស្រុកសណ្តាន់ ២០១៩-២០២៤

វប្រាំង(បច្ចុប្បន្ន ត្រូវបានដាក់ឱ្យប្រើប្រាស់ ជាស្ពានពរក្រោយពីបានជួសជុល រួចរាល់)។ ក្រៅពីប្រព័ន្ធធារាសាស្ត្រធំៗ ទាំង៤ នេះនៅមានអាងទឹកតូចៗ ទំនប់ស្ទាក់ទឹក ប្រព័ន្ធប្រឡាយ និងសំណង់ជាច្រើនស្ទើរតែគ្រប់ឃុំ។

**ង.អំពីបណ្តាញគមនាគមន៍**

ផ្លូវដែលឆ្លងកាត់ស្រុកមានចំនួន២ខ្សែះ

- ផ្លូវពីព្រំប្រទល់ស្រុកប្រាសាទសំបូរកាត់តាម ឃុំមានជ័យ ឃុំសណ្តាន់ ឃុំមានរិទ្ធ និងឃុំទំរីង ប្រវែង៨៥ គ.ម
- ផ្លូវពីព្រំប្រទល់ស្រុកប្រាសាទសំបូរកាត់តាម ឃុំក្លែង ឃុំឈើទាល ដល់ឃុំសណ្តាន់ប្រវែង១៨គ.ម ក្រៅពីនេះនៅមានផ្លូវក្រាលកៅស៊ូនៅជនបទដែលបានកំពុងសាងសង់ និងស្តារឡើងវិញដោយមន្ទីរអភិវឌ្ឍន៍
- ដោយឡែកប្រព័ន្ធធារាសាស្ត្រភាគច្រើនបានជួយសម្រួលដល់ការធ្វើដំណើរនិងការដឹក ជញ្ជូនរបស់ប្រជាជន និងផ្លូវសាងសង់ដោយមូលនិធិឃុំជាច្រើនទៀត។

**ច. ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន**

- ផ្ទៃដីសម្បទានសង្គមកិច្ចចំនួន ២.៥៨៥ ហ.ត
- ផ្ទៃដីព្រៃ ២៦១.៧៩៤ ហ.ត
- ផ្ទៃដីដាំដុះ ២០.៧២០ ហ.ត
- ផ្ទៃដីលំនៅដ្ឋាន ១.៥៨០ ហ.ត
- ផ្ទៃដីផ្សេងៗ ៥.២២១ ហ.ត
- ផ្ទៃដីសម្បទានសេដ្ឋកិច្ចចំនួន ២០.៥០០ ហ.ត។

**ឆ.ការងារជលផល**

អ្នកប្រកបរបរនេសាទជាចម្បងមាន១.១៤៨គ្រួសារ(៩.០២០%)។ សហគមន៍នេសាទទូទាំងស្រុកមានចំនួន៧ សហគមន៍ គ្រប់គ្រងលើផ្ទៃដីសរុប១៤៣.៩ ហ.ត។

- ឧបករណ៍ស្ទង់កំពស់ទឹក ល្បឿនទឹកចំនួន១ នៅអូរល្អក់១"ភូមិអូរពកសាមគ្គី ឃុំមានរិទ្ធ ស្រុកសណ្តាន់"
- ឧបករណ៍វាស់សំណើមអាកាសធាតុនិងទឹកភ្លៀងមាន០១កន្លែងស្ថិតក្នុងភូមិខោសឃុំទំរីង
- ស្រុកមានស្ទឹងសែន និងមានបឹងតូច ធំជាច្រើន មានដូចជា បឹងក្រញ៉ាក បឹងធំ បឹងចាង បឹងប្រា បឹងក្រូច
- ដងស្ទឹងសែនហូរកាត់ស្រុក ដែលមានប្រភពពីខេត្តព្រះវិហារ។

**ជ.អំពីផលអនុផលព្រៃឈើ**

មានគ្រួសារមួយចំនួន ដែលរស់នៅក្នុងតំបន់អភិរក្សព្រៃឈើនិងដែនជម្រកសត្វព្រៃ ក្នុងនេះមាន៣៤២ គ្រួសារ ដែលនៅបន្តប្រកបរបរពីអនុផលព្រៃឈើជាចម្បង។ ដោយសារព្រៃឈើកាន់តែរេចរិលប៉ុន្តែមានអត្ថប្រយោជន៍ ជាសកលទើបបានជាកន្លងមកនេះក្រសួងកសិកម្មបានសម្រេចបង្កើតតំបន់ព្រៃសហគមន៍ក្នុងស្រុក ចំនួន ៣១ កន្លែងមានផ្ទៃដីព្រៃ សរុប ៥០៨.១៣៦ហ.ត។ ជាមួយនេះដែរ ដំណាំកសិ-ឧស្សាហកម្ម ជាពិសេស កៅស៊ូ កំពុងពង្រីកវិសាលភាពជំនួសព្រៃរេចរិល។ ដោយឡែកផ្នែករដ្ឋបាលព្រៃឈើស្រុកសណ្តាន់មានថ្នាលបណ្តុះកូនឈើចំនួន ៣កន្លែងបានបណ្តុះ កូនឈើ ឈើហូបផ្លែសម្រាប់ដាំ និងចែកជូនប្រជាជនជាលក្ខណៈគ្រួសារ។ ឡូតិ៍គំរូអចិន្ត្រៃយ៍របស់ផ្នែករដ្ឋបាលព្រៃឈើមានចំនួន៣ ឡូតិ៍ គំរូចំការពូជឈើមាន ១ កន្លែង ផ្ទៃដី ១១៣ហាត ប្រភេទ ឈើស្រល់ តាត្រាវ ដូងថែម កកោះ ឈើទាល ផ្ចឿក និងជ័រចុង។[5]

- ❖ **ស្ថានភាពចម្បងនៅក្នុងផ្នែកសង្គមកិច្ច**

**ក. វិស័យអប់រំ**

ក្នុងស្រុកសណ្តាន់បានផ្តល់ឱកាសឱ្យយុវជន និងកុមារបានចូលសិក្សារៀនសូត្រ និងប្រកបដោយ គុណភាព។ សម្រាប់វិស័យអប់រំមានកម្រិតថ្នាក់សិក្សាចំនួន៤ និងសាលារៀន សរុប ៩៦ សាលា ក្នុងនោះមាន បឋមសិក្សា សរុប ៨៦សាលា អនុវិទ្យាល័យ សរុប ០៧ សាលា វិទ្យាល័យ សរុប ០៣ សាលា។ មានបុគ្គលិកអប់រំមានចំនួន៤៦១នាក់ (ស្រី១៨៩ នាក់) ដែលក្នុងនោះរួមមាន៖

- ➢ បុគ្គលិកមត្តេយ្យសិក្សា សរុប ១៩ នាក់ ស្រី ១៩ នាក់
- ➢ បុគ្គលិកបឋមសិក្សា សរុប ២៨៩ នាក់ ស្រី ១២៥ នាក់
- ➢ បុគ្គលិកអនុវិទ្យាល័យ សរុប ៥៧ នាក់ ស្រី ១៥ នាក់
- ➢ បុគ្គលិកវិទ្យាល័យ សរុប ៨៣ នាក់ ស្រី ២៨ នាក់។

**ខ. វិស័យសុខាភិបាល**

នៅក្នុងស្រុក មានបណ្តាញសេវាសុខភាពជាច្រើនមានទាំងរដ្ឋ និងឯកជនដើម្បីពិនិត្យព្យាបាលអ្នកជំងឺ នៅក្នុងនោះផងដែរក៏មានមណ្ឌលសុខភាពសម្រាប់បម្រើសេវាជូនប្រជាពលរដ្ឋ ដើម្បីមកសម្រាកព្យាបាលនៅមន្ទីពេទ្យបង្អែកដែលនៅជិតមូលដ្ឋានរបស់ខ្លួនរួមមាន៖

- ➢ មណ្ឌលសុខភាព ឃុំសណ្តាន់ មានចំនួន៣ ឃុំចំណុះនិងមកទទួលសេវា
- ➢ មណ្ឌលសុខភាព ឃុំឈើទាល់ មានចំនួន២ ឃុំចំណុះនិងមកទទួលសេវា

[5]គេហទំព័ https://kampongthom.gov.kh/15664/ ,ដកស្រង់ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២

- មណ្ឌលសុខភាព ឃុំទំរើង មានចំនួន២ ឃុំចំណុះនិងមកទទួលសេវា
- មណ្ឌលសុខភាព ឃុំមានជ័យ មានចំនួន២ ឃុំចំណុះនិងមកទទួលសេវា។

## ១.២. ចក្ខុវិស័យ

ដើម្បីអភិវឌ្ឍវិស័យសេវាសាធារណៈឱ្យមានការរីកចម្រើន និងមាននូវប្រសិទ្ធភាពខ្ពស់ប្រកបដោយវឌ្ឍនភាព នៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តោតសំខាន់ទៅលើចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិត របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃកម្ពុជា និងការខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ពីសំណាក់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សម្រាប់ការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាយន្តការអន្តរក្រសួងសម្រាប់ ការលើកកម្ពស់ តាមរយៈកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការនៅក្នុងប្រទេសកម្ពុជា។

### ១.២.១. ប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ

ការផ្តល់សេវាសធារណៈជូនចំពោះប្រជាពលរដ្ឋពិតជាសំខាន់ខ្លាំងណាស់ ដើម្បីឱ្យការផ្តល់សេវាកាន់តែមានប្រសិទ្ធភាព គឺត្រូវតែមានការឆ្លើយតបទាន់ពេលវេលាទៅនិងសេចក្តីត្រូវការ និងមានភាពងាយស្រួលពីការចូលរួមរបស់អ្នកប្រើប្រាស់។ និងការផ្តល់សេវាផ្តោតទៅលើសេចក្តីត្រូវការជាក់ស្តែង របស់អ្នកប្រើប្រាស់សេវា (តាមតម្រូវការនិងសំណូមពរ) ការផ្តល់សេវាដោយការលើកម្ពស់តម្លាភាព និងមានភាពទទួលខុសត្រូវ ។ក្នុងនោះការផ្តល់សេវាសាធារណៈត្រូវបានគោរពតាមគោលការណ៍ នីតិវិធី និងស្តង់ដាសេវាសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចត្រូវរៀបចំ និងកំណត់ដោយក្រសួងស្ថាប័ននៃវិស័យនីមួយៗ។[6]

ការផ្តល់សេវាសាធារណៈ និងការដោះស្រាយបញ្ហាប្រឈម នៅមូលដ្ឋាន ត្រូវបន្តជំរុញ និងលើកកម្ពស់ការផ្តល់សេវាសាធារណៈនានាជូនប្រជាពលរដ្ឋប្រកបដោយ ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ដែលកាន់តែមានការកើនឡើង ក្នុងពេលដែលប្រទេសជាតិយើងកំពុងមានការអភិវឌ្ឍរីកចម្រើន យ៉ាងឆាប់រហ័ស។ ដើម្បីឆ្លើយតប និងការអភិវឌ្ឍន៍នៃការផ្តល់សេវាសាធារណៈត្រូវមានគោលការណ៍ដូចខាងក្រោម៖[7]

- **គោលការណ៍គ្រឹះនៃសេវាសាធារណៈ**

[6] មាត្រា៥ ( អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក )

[7] សៀវភៅរដ្ឋបាលសាធារណៈ សាស្ត្រាចារ្យ ខាំ សុមករា ( ឆ្នាំ២០១៣ ទំព័ ៨៤-៨៥ )

ដំណើរការនៃសេវាសាធារណៈទាំងអស់ ត្រូវតែស្របជាមួយនឹង គោលការណ៍គ្រឹះដើម្បីធានានូវផលប្រយោជន៍ទូទៅ ក៏ដូចជាសិទ្ធិរបស់អ្នកប្រើប្រាស់សេវាសាធារណៈ។ យើងសង្កេតឃើញមានគោការណ៍គ្រឹះចំនួន៣ គឺ គោលការណ៍និរន្តរភាព គោលការណ៍សមភាព និងគោលការណ៍បរិវត្តភាព។

- **គោលការណ៍និរន្តរភាពនៃសេវាសាធារណៈ**

សេវាសាធារណៈត្រូវមានដំណើការយ៉ាងទៀង ពេលនិងទៀងទាត់។ បញ្ហាជាសារវន្ត ដែលតែងតែចោទចំពោះនិរន្តរភាពនៃដំណើរការរបស់សេវាសាធារណៈ គឺបញ្ហានៃការសម្រុះសម្រួលសេវាសាធារណៈ ជាមួយនិងសិទ្ធិធ្វើកូដកម្មរបស់អ្នកផ្តល់សេវាទាំងនោះ។ ពេលខ្លះ ដើម្បីធានានិរន្តរភាពនៃសេវាសាធារណៈ រដ្ឋត្រូវបង្ខំចិត្តធ្វើច្បាប់ហាមឃាត់មិនឱ្យមន្ត្រីរាជការ ឬអ្នកផ្តល់សេវាសាធារណៈ មានលទ្ធភាពធ្វើកូដកម្ម នៅពេលដែលខ្លួនមានកាតព្វកិច្ចត្រូវបំពេញសេវា ។ ប្រសិនបើមិនធ្វើបែបនេះទេ កូដកម្មនិងផ្អាកដំណើរការ និងបំផ្លាញប្រសិទ្ធភាពនៃសេវាសាធារណៈ ហើយចុងបញ្ចប់ អ្នកដែលរងគ្រោះថ្នាក់គឺប្រជាពលរដ្ឋតែម្តង ។

- **គោលការណ៍សមភាពនៃសេវាសាធារណៈ**

គោលការណ៍ សមភាព នេះត្រូវបានទទួលស្គាល់ថា មានគោលបំណងការពារផលប្រយោជន៍ អ្នកប្រើប្រាស់សេវាសាធារណៈ ។ នេះមានន័យថា អ្នកប្រើប្រាស់ទាំងអស់ ត្រូវទទួលបានការបម្រើនិងការផ្តល់សេវាសាធារណៈ ស្មើៗគ្នា ។ ជាទូទៅ គោលការណ៍សមភាពនេះ ត្រូវបានចាត់ទុកថាជាគោលការណ៍ទូទៅនៃនីតិ។

នៅក្នុងការអនុវត្តជាក់ស្តែង គោលការណ៍នេះមិនមានលក្ខណៈដាច់ខាតទេ ប៉ុន្តែមានលក្ខណៈមិនដាច់ខាតខ្លះ ពោលគឺ សេវាសាធារណៈមានសភាពតាម ជំពូក ប្រភេទនៃអ្នកប្រើប្រាស់ផងដែរ។ ជារឿយៗ ភាពខុសគ្នានេះ កើតឡើងចំពោះការកំណត់តម្លៃនៃសេវាសាធារណៈ។ ជាផលវិបាក ប្រសិនបើមានភាពខុសប្លែកគ្នាចំពោះ ការផ្តល់សេវាបែបនេះ ការចោទប្រកាន់អំពីការរើសអើងក្នុងការផ្តល់សេវាសាធារណៈប្រាកដជាមានមិនខាន។

- **គោលការណ៍ បរិវត្តភាពនៃសេវាសាធារណៈ**

គោលការណ៍បរិវត្តភាពនេះបង្ហាញឱ្យឃើញថា សេវាសាធារណៈត្រូវតែស្ថិតនៅជាអចិន្ត្រៃយ៍ដើម្បីបម្រើផលប្រយោជន៍ទូទៅ ប៉ុន្តែប្រសិនបើមានតម្រូវការឱ្យកែប្រែភាពអចិន្ត្រៃយ៍នេះ សេវាសាធារណៈត្រូវតែតម្រូវ និងសម្របខ្លួនទៅតាមស្ថានភាពប្រែប្រួលនោះ។

គោលការណ៍នេះ ច្រើនតែកើតមាននៅក្នុងកិច្ចសន្យាសម្បទានសេវាសាធារណៈ។ រដ្ឋមានសិទ្ធិកែប្រែលក្ខខណ្ឌទាំងឡាយ នៅក្នុងកិច្ចសន្យាសម្បទានជាឯកតោភាគី ដើម្បីការពារផលប្រយោជន៍ទូទៅ។ ដូចនេះ នៅក្នុងករណីនេះ សម្បទានិក មិនមានសិទ្ធិផ្តាច់មុខលើការផ្តល់ សេវាសាធារណៈនោះទេ។

គោលការណ៍បរិវត្តភាពនៃសេវាសាធារណៈនេះ ត្រូវបានយកទៅអនុវត្តជាមួយនឹងលិខិតឯកតោភាគីផងដែរ។ យើងនិយាយអំពីបរិវត្តភាពនៃបទបញ្ជារដ្ឋបាល។ នេះមានន័យថាប្រជាពលរដ្ឋ មិនមានសិទ្ធិត្រូវបានការពារផលប្រយោជន៍ ចំពោះការបញ្ចប់ដំណើរការនៃសេវាសាធារណៈដោយរដ្ឋនោះទេ។

រដ្ឋបាលសាធាណៈត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ ក្នុងការបំពេញតួនាទីភារកិច្ចក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា។[៨] ក្នុងការធ្វើគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រដ្ឋបាលស្រុក គឺបានត្រូវរៀបចំឱ្យមានយន្តការ មធ្យោបាយ និងនីតិវិធីនៃការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋការទទួលព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋ និងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដើម្បីធានារាល់សេចក្តីសម្រេចនានា និងរាល់សកម្មភាពឬទង្វើរបស់រដ្ឋបាល ស្រុកត្រូវឆ្លើយតបទៅ និងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយសមត្ថភាពរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពតម្លាភាព បរិយាប័ន្ន និងសមធម៌សង្គម។[៩]

### ១.២.២. ប្រភេទសេវាសាធារណៈ

ប្រភេទសេវាសាធារណៈ ត្រូវបានចងក្រង និងប្រមូលផ្តុំជា ៦ប្រភេទធំៗទៅតាមវិស័យ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ដូចខាងក្រោម៖

**១. ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យរដ្ឋ**

សេវាពាក់ព័ន្ធនឹងអធិបតេយ្យរដ្ឋ គឺជាសេវាទទួលខុសត្រូវផ្តាច់មុខរបស់រដ្ឋ ដែលផ្តល់ដោយអង្គការរដ្ឋ ឬនីតិបុគ្គលនៃនីតិបុគ្គលសាធារណៈ ដែលរដ្ឋបានប្រគល់សិទ្ធិអំណាចឱ្យដើម្បីអនុវត្ត។ ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យរដ្ឋមានដូចជា៖ លិខិតអនុញ្ញាត អជ្ញាប័ណ្ណ បញ្ជីអត្រានុកូលដ្ឋាន សំបុត្របញ្ជាក់កំណើត ប័ណ្ណសំគាល់យានយន្ត អាកាសយាន្ត និងនាវា វិញ្ញាប័ណ្ណប័ត្រទទួលស្គាល់កម្មសិទ្ធិ អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋខ្មែរ សៀវភៅគ្រួសារ ការធ្វើនីត្យានុកូលកម្មជាដើម។ពាក់ព័ន្ធទៅនឹងចង្កោមសេវាសាធារណៈនេះ ការរៀបចំ និងការប្រតិបត្តិនៃការផ្តល់សេវាត្រូវទទួលខុសត្រូវដោយរដ្ឋ ឬភ្នាក់របស់រដ្ឋ។

**២. ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម**

សេវាពាក់ព័ន្ធផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការស្នាក់នៅ ការធ្វើដំណើរ ការប្រាស្រ័យទាក់ទងរបស់ប្រជាពលរដ្ឋ និងសុវត្ថិភាពសង្គម គឺជាសមត្ថកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ច នគរបាលជាតិ កងរាជអាវុធហត្ថ និងកងយោធពលខេមរភូមិន្ទគ្រប់លំដាប់ថ្នាក់ទូទាំងប្រទេស។ ចង្កោមសេវានេះជាសេវាដ៏ចាំបាច់ និងមិន

[៨] មាត្រា៤៩ ( អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក )

[៩] មាត្រា ៥០ ( អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក )

អាចខ្វះបាន ដើម្បីធានាបរិយាកាសល្អដល់ការអភិវឌ្ឍសង្គមជាតិ ការកាត់បន្ថយភាពក្រីក្រ ភាពសុខសាន្តរបស់ប្រជាពលរដ្ឋ និងជាទំនុកចិត្តដល់វិនិយោគិន ធុរជន ក្នុងការប្រកបរបរអាជីវកម្ម និងជំនួញជួញដូរ។

ចំពោះចង្កោមនៃសេវាសាធារណៈនេះ ការរៀបចំ និងការប្រតិបត្តិការនៃការផ្តល់សេវាត្រូវធ្វើឡើងដោយរដ្ឋ ឬភ្នាក់ងាររបស់រដ្ឋ។

**៣. ចង្កោមសេវាពាក់ព័ន្ធយុត្តិធម៌ និងអាជ្ញាកណ្តាល**

សេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាលដូចជា វិវាទរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ឬរវាងប្រជាពលរដ្ឋ និងអ្នករាជការ ឬរវាងប្រជាពលរដ្ឋ និងផ្នែកឯកជន ឬរវាងអ្នករាជការ និងផ្នែកឯកជនជាដើម សេវាដោះស្រាយវិវាទនេះធ្វើឡើងតាមរូបភាព ២ យ៉ាង៖

- តាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាអ្នកសម្របសម្រួល និងដោះស្រាយចំពោះករណីវិវាទមិនធ្ងន់ធ្ងរ ដើម្បីសម្រួលដល់គូភាគីទាំងសងខាងដោយមិនចាំបាច់ពឹងផ្អែកតែទៅលើតុលាការ និងកាត់បន្ថយការកកស្ទះសំណុំរឿងនៅតុលាការ។
- ក្នុងករណីគូវិវាទមិនទទួលយកនូវដំណោះស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេនោះការដោះស្រាយវិវាទ ត្រូវធ្វើឡើងតាមរយៈតុលាការ។

ភាពជឿទុកចិត្តរបស់អ្នកប្រើប្រាស់សេវា និងអ្នកពាក់ព័ន្ធទាំងអស់ អាស្រ័យទៅលើការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ នៅក្នុងបរិបទនៃនីតិរដ្ឋ។ ដូចនេះ រាល់សកម្មភាពកែលម្អប្រព័ន្ធការងារទាំងអស់ គឺត្រូវបានរៀបចំឡើងជាជំហានៗ និងដោយប្រុងប្រយ័ត្ន ក្នុងទិសដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាកម្មយុត្តិធម៌។

**៤. ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្មសហគ្រាសធុនតូច និងមធ្យម បរិស្ថានវិនិយោគ និងការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ**

**ក. ការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម**

រាជរដ្ឋាភិបាល ដែលជាអ្នករៀបចំយុទ្ធសាស្ត្រ និងជាអ្នកគ្រប់គ្រងការអភិវឌ្ឍ ដើម្បីធ្វើឱ្យបរិស្ថានធុរកិច្ចកាន់តែប្រសើរសម្រាប់វិស័យឯកជន បានចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច។ អាទិភាពជាពិសេសនឹងត្រូវផ្តោតទៅលើការរៀបចំឱ្យកាន់តែប្រសើរឡើងនូវបរិស្ថានរួមសម្រាប់ការអភិវឌ្ឍវិស័យឯកជន តាមរយៈវិធានការជាក់ស្តែងនានា៖

- ពង្រឹងអភិបាលកិច្ចល្អ ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន
- កាត់បន្ថយរាល់បែបបទស្មុគស្មាញ និងវែងអន្លាយ នៅតាមក្រសួងស្ថាប័ន ដែលពាក់ព័ន្ធដល់ការនាំចេញ នាំចូល។

- បំបាត់ចោលនូវភារកិច្ចជាន់គ្នារបស់ក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញដំណើរការត្រួតពិនិត្យតែមួយកន្លែងឱ្យមានប្រសិទ្ធភាព។
- ពង្រឹងការអនុវត្តយន្តការការិយាល័យ ច្រកចេញចូលតែមួយ នៅតាមបណ្តាច្រកអន្តរជាតិ។

**ខ. សហគ្រាសធុនតូច និងមធ្យម**

រាជរដ្ឋាភិបាល បន្តជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមតាមរយៈគោលនយោបាយៈ

- លើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យម ជាពិសេសតាមរយៈការផ្តល់ឥណទានរយៈពេលមធ្យម និងរយៈពេលវែង
- ទប់ស្កាត់ការរត់គេចពន្ធគ្រប់ប្រភេទ
- កាត់បន្ថយបែបបទការចុះបញ្ជី និងការរៀបចំដំណើរការក្រុមហ៊ុន។
- សម្របសម្រួលដល់ការនាំចេញនាំចូលតាមរយៈ ការកាត់បន្ថយបែបបទស្មុគស្មាញក្នុងការស្នើសុំអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតផ្សេងៗ ។ល។
- កាត់បន្ថយពេលវេលា និងកាត់បន្ថយថ្លៃសេវាកម្មក្នុងការអនុញ្ញាតឱ្យដំណើរការផលិតកម្មនៃសហគ្រាសធុនតូច និងមធ្យមតាមរយៈការអនុវត្តយន្តការការិយាល័យច្រកចេញចូលតែមួយ។
- ផ្តល់ការគាំពារដល់សហគ្រាសមួយចំនួនក្នុងរយៈពេលមួយសមស្រប។
- ជំរុញឱ្យមានសម្ព័ន្ធភាពរវាងសហគ្រាសធុនតូច និងមធ្យម ជាមួយនឹងឧស្សាហកម្មធុនធំ ជាដើម។

**ដើម្បីសម្រេចគោលដៅខាងលើ រាជរដ្ឋាភិបាលយកចិត្តទុកដាក់ៈ**

- ជំរុញលើកទឹកចិត្តដល់ការផលិតទំនិញបម្រើទីផ្សារក្នុងស្រុកជំនួសការនាំចូល ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រនៃការបង្កើតមូលដ្ឋានផលិតកម្មទំនិញក្នុងប្រទេសឱ្យបានច្រើនស្របទៅនឹងយុគសម័យនៃតំបន់ភាវូបនីយកម្ម និងសកលភាវូបនីយកម្ម
- រៀបចំយុទ្ធសាស្ត្របង្កើនសមត្ថភាពប្រកួតប្រជែងសម្រាប់សហគ្រាសធុនតូច និងមធ្យម
- រៀបចំផែនការសកម្មភាព និងបទប្បញ្ញត្តិនានា ដើម្បីគ្រប់គ្រង តាមដានត្រួតពិនិត្យ និងគាំទ្រដល់ដំណើរការរបស់សហគ្រាសធុនតូច និងមធ្យម។

**គ. បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធ**

ពាក់ព័ន្ធនឹងការងារនេះ រាជរដ្ឋាភិបាលនឹងចាត់វិធានការចាំបាច់ ដើម្បីពង្រឹង និងកែលំអបរិស្ថានវិនិយោគ និងធុរកិច្ចរួមមាន គោលនយោបាយលើកទឹកចិត្ត លិខិតបទដ្ឋានសម្រាប់ណែនាំ និងជំរុញការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធ។

រចនាសម្ព័ន្ធនៃផ្នែកពាក់ព័ន្ធទៅនឹងចង្កោមសេវានេះ ដែលមិនទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការជាចាំបាច់ក្នុងការសម្រួលដល់ការធ្វើអាជីវកម្ម ការវិនិយោគទុន និងការអភិវឌ្ឍផ្នែកឯកជន ត្រូវធ្វើការកែសម្រួលឱ្យបានសមស្រប និងឱ្យបានឆាប់រហ័សទៅតាមស្ថានភាពជាក់ស្តែង និងធនធានដែលមាន។

**ឃ. ចង្កោមសេវាសង្គមកិច្ច វប្បធម៌ និងកិច្ចការនារី**

ចង្កោមសេវានេះ រួមមានសេវាអប់រំ (លើកកម្ពស់គុណភាពសេវាអប់រំសម្រាប់ទាំងអស់គ្នា សម្ភារៈសិក្សាគ្រប់គ្រាន់ និងសិទ្ធិទទួលបានសេវាអប់រំជាមូលដ្ឋាន) សេវាអនាម័យ និងសុខភាព ( បង្កលក្ខណៈងាយស្រួល គុណភាព ប្រសិទ្ធភាព ដើម្បីផ្គត់ផ្គង់សេវាសុខាភិបាលមូលដ្ឋានប្រកបដោយសមធម៌ និងនិរន្តរភាពជូនប្រជាពលរដ្ឋគ្រប់រូប ជាពិសេសជនក្រីក្រ និងក្រុមជនងាយរងគ្រោះ ) សេវាសម្រាប់ការកំសាន្ត សេវាសង្គមកិច្ច សេវាគាំពារកុមារកំព្រា កុមារងាយរងគ្រោះ ជនពិការ សេវាលើកស្ទួយ និងការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសេវាដទៃទៀត ដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។

**ង. ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត**

ការផ្តល់សេវានៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គឺជាអាទិភាពចំបងមួយរបស់រាជរដ្ឋាភិបាលដើម្បីជំរុញនិងបង្កើនល្បឿនកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ត្រូវផ្តោតជាសំខាន់លើការបន្តការកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនរួមមាន៖ ផ្លូវថ្នល់ ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងអាកាសយានដ្ឋាន ដែលអាចតភ្ជាប់ទីក្រុងទៅជនបទ។[10]

### ១.២.៣. ការពង្រឹងគុណភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ

- រៀបចំបង្កើត និងដាក់អនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈក្នុងវិស័យនីមួយៗ
- ធ្វើបច្ចុប្បន្នកម្មកម្រងព័ត៌មានសេវាសាធារណៈ ព្រមទាំងជំរុញ ការបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីសេវាសាធារណៈ ព្រមទាំងជំរុញ ការបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីសេវាសាធារណៈ ជាពិសេសតាមប្រព័ន្ធអេឡិចត្រូនិច
- កែលម្អនីតិវិធី និងយន្តការផ្តល់សេវាសាធារណៈ សំខាន់ៗដែលពាក់ព័ន្ធផ្ទាល់ទៅនឹងជីវភាពរស់នូវរបស់ ប្រជាពលរដ្ឋ ដូចជា វិស័យសុខាភិបាល អប់រំ ពាណិជ្ជកម្ម សាធារណការ និងដឹកជញ្ជូន ការចុះបញ្ជីដីធ្លី និងសំណង់ អត្រានុកូលដ្ឋាន លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណ ជាដើម

[10] សៀវភៅ គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ (បម្រើប្រជាពលរដ្ឋអោយកាន់តែល្អប្រសើរឡើង អនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នៅថ្ងៃទី០៥ ឧសភា ឆ្នាំ២០០៦) ទំព័រទី០៨~ទី២០

➢ ធ្វើការវិភាគមុខងារ និងលំហូការងារសម្រាប់សេវាសាធារណៈ ដែលមានផលប៉ះពាល់ផ្ទាល់លើមន្ត្រីរាជការ ដូចជា ការបើក ផ្តល់ប្រាក់បេសកកម្ម ប្រាក់ឧបត្ថម និងប្រាក់សោធននិវត្តន៍

➢ កែលម្អនីតិវិធី និងយន្តការផ្តល់សេវាសាធារណៈ ដែលអនុវត្តន៍ដោយស្ថាប័នមានសមត្ថកិច្ច ឬស្ថាប័ន ទទួលសមត្ថកិច្ច តាមរយះយន្តការផ្សេងដូចជា គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ ទីភ្នាក់ងារប្រតិបត្តិការពិសេស និងការិល័យច្រកចេញចូលតែមួយជាដើម

➢ រៀបចំដាក់ឱ្យដំណើការ នូវយន្តការផ្តល់ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់ សេវាសាធារណៈនៅតាម យន្តការផ្តល់សេវាសសាធារណៈទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

➢ សិក្សា និងជំរុញការផ្តល់សេវាសាធារណៈ តាមប្រព័ន្ធព័ត៌មានវិទ្យា។[11]

## ១.៣. គោលដៅ

ដើម្បីធ្វើឱ្យការអភិវឌ្ឍស្របទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ខេត្តបានដាក់ចេញនូវចក្ខុវិស័យ ដើម្បីចូលរួមការកាត់បន្ថយភាពក្រីក្រ ដោយផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍមូលដ្ឋាន និងជម្រុញឱ្យមានអភិបាលកិច្ចល្អ តាមរយះកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ចក្ខុវិស័យរបស់ខេត្ត ប្រជាពលរដ្ឋខេត្តមានសុខភាពមាំមួន ជីវភាពធូរធារ មានសុវត្ថិភាព មានចំណេះដឹង ជំនាញ បច្ចេកទេស រស់នៅក្នុងបរិស្ថានល្អ រក្សាបាននូវវប្បធម៌ប្រពៃណីជាតិ បេតិកភណ្ឌ សាសនា មានការគោរពច្បាប់ និងមានសមធម៌។ ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ដោយជំរុញការកែលម្អស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចដែលផ្តល់ផលប្រយោជន៍ដល់ការលើកកម្ពស់ជីវភាពទាំងខាងស្មារតី និងសម្ភារៈ ដល់ប្រជាជន ។

### ១.៣.១.គោលបំណងអភិវឌ្ឍ

➢ បង្កើនចំណូលតាមរយៈការបង្កើត ការងារ បង្កើនមុខរបរនិងបង្កើនផលិតភាព ផលិតកម្មកសិកម្ម

➢ ប្រជាពលរដ្ឋគ្រប់រូបមានចំណេះដឹងមានសុខភាពល្អ និងទទួលបានសេវាថៃរក្សាការពារដោយស្មើភាព និងសមធម៌

➢ ធានាការគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ការគ្រប់គ្រងនិងប្រើប្រាស់ធនធានធម្មជាតិ និងបរិស្ថានប្រកបដោយប្រសិទ្ធភាព និងសមធម៌

➢ បង្កើនប្រសិទ្ធភាពការគ្រប់គ្រងរដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈឱ្យកាន់តែល្អប្រសើរ

### ១.៣.២.គោលដៅអភិវឌ្ឍ

**លើកកម្ពស់ផលិតភាពនៃពិធីកម្មកសិកម្មតាមរយះ**

[11]គេហទំព័រfile:///C:/Users/User/Documents/%E1%9E%AF%E1%%96%E1%9E%B8%E1%9E%8C%E1%9E%BC.pdf ចូលមើលនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២

- ការបង្កើន ទិន្នផលស្រូវ
- បង្កើនការដាំដុះដំណាំ ស្រូវ ឱ្យបានច្រើនដងលើផ្ទៃដីដែលមានស្រាប់
- បង្កើនការដាំដុះដំណាំ រយៈពេលខ្លី រយៈពេលវែង និងដំណាំរួមផ្សំផ្សេងទៀត
- ជំរុញកំណើនការចិញ្ចឹមសត្វជាលក្ខណៈ កសិដ្ឋាន និងជាលក្ខណៈគ្រួសារ។

**បង្កើនប្រាក់ចំណូល ពីមុខរបរក្នុងវិស័យកសិកម្មតាមរយៈ**

- ការជំរុញ ការអភិវឌ្ឍ វិស័យឯកជននិងការងារ
- ការអភិវឌ្ឍតំបន់ទេសចរណ៍ ។

**សម្រេចឱ្យបានជាទូទៅនូវការអប់រំកម្រិតមូលដ្ឋានតាមរយៈ**

- ពង្រឹងនិងពង្រីកកម្មវិធី អប់រំកុមារតូច
- លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការសិក្សានៅគ្រប់កំរឹត
- កាត់បន្ថយអនក្ខរជនឱ្យនៅមានកម្រិតទាបបំផុត

**បង្កើនគុណភាពនឹង ប្រសិទ្ធភាពក្នុងការផ្តល់សេវាសុខភាព ជូនប្រជាពលរដ្ឋតាមរយៈ**

- អប់រំលើកកម្ពស់សុខភាពមាតានិងទារក
- ពង្រឹងវិធានការការពារទប់ស្កាត់ជំងឺឆ្លងនិងជំងឺរុំារ៉ៃផ្សេងៗទៀត
- លើកកម្ពស់សុខភាពប្រជាពលរដ្ឋតាមរយៈការប្រើប្រាស់ទឹកស្អាតនិងបង្គន់អនាម័យ
- យកចិត្តទុកដាក់ចំពោះជនងាយរងគ្រោះហើយមានជីវភាពរស់នៅសមរម្យ
- បង្កើនការយល់ដឹងពីការបញ្ជ្រាបយេនឌ័រនិងការចូលរួមក្នុងឆាកនយោបាយរបស់ស្ត្រី

**បន្តដោះស្រាយសម្បទានដីសង្គមកិច្ច សម្រាប់បែងចែកដល់គ្រួសារក្រីក្រគ្មានដីតាមរយៈ**

- បន្តផ្តល់ដីសម្បទានសង្គមកិច្ច ដល់គ្រួសារក្រីក្រគ្មាន ដី និងកងកម្លាំងប្រដាប់អាវុធចូលនិវត្ត
- ជំរុញការអនុវត្តកិច្ចសន្យា វិនិយោគដីសម្បទានសេដ្ឋកិច្ច។

**ធានាការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព តាមរយៈ**

- ការគ្រប់គ្រងនិងអភិរក្សធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយចីរភាព
- គ្រប់គ្រង និងអភិរក្ស ធនធានជលផល ប្រកបដោយចីរភាព
- ធានាចីរភាពបរិស្ថាននិងអភិរក្សជីវៈចម្រុះ ។

**ពង្រឹងយន្តការគ្រប់គ្រងនិងឆ្លើយតបទៅនឹងគ្រោះមហន្តរាយផ្សេងៗតាមរយៈ**

- ត្រៀមលក្ខណៈគ្រប់គ្រង បង្ការនិងដោះស្រាយរាល់បញ្ហាដែលកើតឡើងដោយគ្រោះមហន្តរាយផ្សេងៗ

- ត្រៀមលក្ខណៈស្តារ ឡើងវិញនូវការខូចខាតដែលបណ្តាលមកពីគ្រោះមហន្តរាយ ។

**ពង្រឹងការផ្តល់សេវាសាធារណៈ ឱ្យមានប្រសិទ្ធភាពតាមរយៈ**

- ពង្រឹងការងារអត្រានុកូលដ្ឋាន
- បង្កើនសេវាផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី
- ពង្រឹងការគ្រប់គ្រងព័ត៌មានដើម្បីឆ្លើយតប គោលនយោបាយ គ្រប់វិស័យ
- គណនេយ្យភាពកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ
- បង្កើនការចូលរួមរបស់ស្ត្រីក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច។

**ពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈតាមរយៈ**

- កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ពីពង្រឹងសន្តិសុខសណ្តាប់ធ្នាប់និងសវត្ថភាពមូលដ្ឋាន
- កាត់បន្ថយអំពើហិង្សាក្នុងគ្រួសារនិងសហគមន៍។[12]

### ១.៣.៣. ការអភិវឌ្ឍមូលដ្ឋាននៅថ្នាក់ស្រុក

- **ការអភិវឌ្ឍសមត្ថភាព**

ការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងស្ថាប័នដែលចាំបាច់សម្រាប់ធានាដល់ការបង្កើតជំរុញ និងធ្វើឱ្យមានជីវភាពដល់ការអភិវឌ្ឍដើម្បីប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការគឺជាសភាពស្នូលដ៏សំខាន់មួយនៃកម្មវិធីជាតិ វិសាលភាពការងារនេះទាមទារឱ្យមានការប្រើប្រាស់វិធីសាស្ត្រជាច្រើនដើម្បីឆ្លើយតបទៅនឹងតម្រូវការដ៏ធំធេងសម្រាប់អភិវឌ្ឍសមត្ថភាព។[13]

ដើម្បីសម្រេចបាននូវគោលបំណងនៃកម្មវិធីជាតិការអភិវឌ្ឍសមត្ថភាព គឺសំដៅទៅលើការគាំទ្របច្ចេកទេសក្នុងការអនុវត្ត នៃការសិក្សារៀនសូត្រ និងតម្រូវការពត៌មានទិន្នន័យ សម្ភារៈបរិក្ខារ ប្រព័ន្ធ និងនីតិវិធីនានាដែលបង្ករអោយលក្ខណៈឱ្យបុគ្គលិក និងស្ថាប័ននានាអាចសម្រេចបាននូវ លទ្ធផលល្អនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះការអភិវឌ្ឍសមត្ថភាព គឺជាបុរេល័ក្ខខ័ណ្ឌក្នុងការផ្តល់លទ្ធភាពឱ្យបុគ្គលិក និងស្ថាប័ននានាអាចមានសមត្ថភាពបំពេញការងារបច្ចេកទេស ការងារគ្រប់គ្រង ឬការងាររដ្ឋបាលដោយខ្លួនឯងផ្ទាល់។ ផែនការសមត្ថភាព ត្រូវរៀបចំឡើងដើម្បីដោះស្រាយតម្រូវការចាំបាច់ និងបន្ទាន់របស់បុគ្គលិក និងស្ថាប័ននានាក្នុងការអនុវត្តនូវការទទួលខុសត្រូវ និងសិទ្ធិអំណាចរបស់ខ្លួននៅតាមថ្នាក់រដ្ឋបាលនីមួយៗ។ ផែនការអភិវឌ្ឍសមត្ថភាពត្រូវរៀបចំឡើយដើម្បីឱ្យស្ថាប័ននានា មានលទ្ធភាពអភិវឌ្ឍស្ថាប័ននិងកសាងសមត្ថភាពបុគ្គលិករបស់ខ្លួន។ ដូចនេះផែនការអភិវឌ្ឍសមត្ថភាពមានការពាក់ព័ន្ធ នឹង

---

[12] សៀវភៅផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ស្រុកសណ្តាន់ ២០១៩-២០២៤

[13] សៀវភៅ កម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០~២០១៩)បោះពុម្ពឆ្នាំ២០១៨ ទំព័រ២៦

លទ្ធផលទាំងឡាយនៃសមាសធាតុកម្មវិធីទាំងអស់របស់កម្មវិធីជាតិ។ ផែនការអភិវឌ្ឍសមត្ថភាពនេះនឹងត្រូវរៀបចំឡើងក្នុងកំឡុងឆមាសទី ១ឆ្នាំ ២០១០។

❖ **កម្មវិធីជាតិបរិយាយអំពីការរៀបចំនានាពាក់ព័ន្ធនឹងគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពដូចខាងក្រោមៈ**

១. លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវពិនិត្យមើលនិងតាមដានការអនុវត្តផែនការអភិវឌ្ឍសមត្ថភាពដែលបានកំណត់នៅក្នុងឯកសារផែនការ។ ឯកសារផែនការនេះអធិប្បាយពីវិធីសាស្ត្រដែលត្រូវអនុវត្តសម្រាប់ការផ្តល់ជំនួយបច្ចេកទេសការបណ្តុះបណ្តាលការបង្កើតកម្មវិធីសាកល្បងគ្រប់គ្រងអភិវឌ្ឍសមត្ថភាព និងបញ្ជីបរិយាយលម្អិតអំពីសមត្ថភាពចាំបាច់នានាដែលជាតំរូវការរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងលទ្ធផលរំពឹងទុកនានានៃកម្មវិធីជាតិ ។

២.ជំនួយបច្ចេកទេសត្រូវបានផ្តល់ដោយស្ថាប័នដែលមានភារកិច្ច ក្នុងការកសាងសមត្ថភាពរបស់បុគ្គលិក និងស្ថាប័នដូចជាសាលាភូមិន្ទរដ្ឋបាល សម្ព័ន្ធមិត្តភាពជាតិសមាគមក្រុមប្រឹក្សាឃុំសង្កាត់ និងនាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងមហាផ្ទៃជាដើម។ លទ្ធផលរំពឹងទុកនានានៃការកសាងសមត្ថភាពស្ថាប័ន មានអធិប្បាយនៅក្នុង សមាសធាតុកម្មវិធីទី ៥។ នៅក្នុងដំណាក់កាលទី ២ស្ថាប័នទាំងនេះនឹងមានការទទួលខុសត្រូវកាន់តែច្រើននៅក្នុងការកំណត់ និងកសាងសមត្ថភាបុគ្គលិកនិងស្ថាប័ននានា។

៣. ក្នុងពេលវេលាមួយសមស្រប រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងទទួលខុសត្រូវក្នុងការកសាងសមត្ថភាពបុគ្គលិក និងស្ថាប័នរបស់ខ្លួន។ កសាងសមត្ថភាពបុគ្គលិក និងស្ថាប័ន គឺជាតួនាទីចម្បងរបស់ស្ថាប័ននានាទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ សមាសធាតុវិធីទីពីរ មានគូសបញ្ជាក់ពីលទ្ធភាពរង្វង់ទុក្ខនានាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវនេះ។ នៅក្នុងដំណាក់កាលទី២ រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ពីតម្រូវការ និងធានាឱ្យមានធនធានសម្រាប់ការកសាងសមត្ថភាព។

៤. មូលនិធិចាំបាច់សម្រាប់តម្រូវការផ្នែកមូលធន និងសម្ភារៈបរិក្ខារ ត្រូវបានផ្តល់ដើម្បីធានាដល់កិច្ចប្រតិបត្តិការនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការធ្វើបញ្ជីសារពើភ័ណ្ឌអំពីមូលធន និងសម្ភារៈបរិក្ខាររបស់រដ្ឋបាលនីមួយៗ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងកំណត់បានពេលតម្រូវការរបស់រដ្ឋបាលមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។[14]

- **ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅមូលដ្ឋាន**

[14] សៀវភៅ កម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩)បោះពុម្ពឆ្នាំ២០១៨ ទំព័រ២៧

ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋានការផ្តល់សេវាសាធារណៈត្រូវតែមានលក្ខណៈជាទុកចិត្តបាន ស្រួលទទួលយក និងព្យាករណ៍បាន ហើយដែលប្រជាពលរដ្ឋគ្រប់រូបមានលទ្ធភាពទទួលបាននូវសេវាសាធារណៈទាំងនោះសាកសមនិងសមត្ថភាពរបស់ខ្លួនដើម្បីបង្កើនលទ្ធភាព អនុវត្តសកម្មភាពរកប្រាក់ចំណូល ការគិតគូអំពីផលប្រយោជន៍នៃការអភិវឌ្ឍរបស់បុគ្គល និងអ្នកវិនិយោគឯកជនតែងតែមានគោលបំណងផ្សេងៗគ្នាដែលទាមទារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគិតគូដោះស្រាយតាមរយៈ ដំណើរការរៀបចំផែនការរៀបចំវិភាជន៍ថវិកា និងកំណត់វិធានដើម្បីកែលម្អលទ្ធភាពទទួលបានសេវាសាធារណៈ។

កម្មវិធីជាតិបង្ហាញអំពីមធ្យោបាយនានាដើម្បីសម្រេចនូវកិច្ចការខាងលើនេះ រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែទទួលបាននូវសិទ្ធិអំណាចក្នុងការជ្រើសរើសជំរើស ដែលមានលក្ខណៈល្អបំផុតសម្រាប់ខ្លួនជាមួយគ្នានេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែយកចិត្តទុកដាក់ពីចារណាទៅលើភាពជឿទុកចិត្តបានងាយស្រួលទទួលយក និងភាពអាចព្យាករណ៍បាននៃការផ្តល់សេវាសាធារណៈទាំងនេះតាមរយៈការផ្ទេរមុខងារ និងតាមរយៈការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធ្វើការងារជាមួយសហគម និងមន្ទីរការិយាល័យខ្សែបណ្តោយរបស់ក្រសួងស្ថាប័ន ដើម្បីកំណត់គោលដៅសំខាន់ៗ និងផែនការសកម្មភាពក្នុងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់ទៅលើមុខងារទាំងឡាយណាដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពអនុវត្តបានប្រកបដោយប្រសិទ្ធភាព នៅក្នុងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន រដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលបាននូវការទទួលខុសត្រូវ និងសិទ្ធិអំណាចក្នុងការរៀបចំ គ្រប់គ្រងសេវាសាធារណៈ និងធនធានទាំងឡាយពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចនានា។

### ១.៣.៤. ការធ្វើសណ្តាប់ធ្នាប់សាធារណៈ ឱ្យកាន់តែល្អប្រសើរ

នៅក្នុងស្រុកនិមួយៗតែងតែ មានសណ្តាប់ធ្នាប់សាធារណៈល្អ ដូច្នេះហើយដើម្បីអោយសណ្តាប់ធ្នាប់សាធារណៈការន់តែល្អប្រសើ រដ្ឋបាលស្រុកក៏បានចាត់វិធានការមួយចំនួនដូចជាៈ

- ជួសជុលលូរទឹកកខ្វក់
- ជួសជុលនិង រៀបចំនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់
- ពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម
- ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់បម្រើដល់សកម្មភាពសេដ្ឋកិច្ចការវិនិយោគការធ្វើពាណិជ្ជកម្ម កសិកម្ម។

#### ការងារសន្តិសុខ

ដើម្បីឱ្យសភាពការណ៍សន្តិសុខក្នុងភូមិសាស្ត្រស្រុកមានលក្ខណៈល្អប្រសើ និងសកម្មភាពសេដ្ឋកិច្ចសង្គមមានការអភិវឌ្ឍ។ កំលាំងនគរបាលគ្រប់ថ្នាក់ត្រូវយកចិត្តទុកដាក់ លើកកម្ពស់ស្មារតីប្រុងប្រយ័ត្ន

គ្រប់គ្រងសភាពការណ៍ សន្តិសុខរួមក្នុងភូមិសាស្ត្រទាំងសន្តិសុខមូលដ្ឋាន និងកិច្ចការពារការចាត់តាំងប្រារព្ធពិធីរបស់ ស្រុក ថ្នាក់ខេត្ត ថ្នាក់ជាតិ និងបណ្តាឥស្សរជនជាតិអន្តរជាតិសំខាន់ៗឱ្យបានដំណើរការទៅប្រកបដោយសុវត្ថិភាព។

- **ការបង្ការទប់ស្កាត់ភេរវកម្ម**

ការអនុវត្តតាមគោលការណែនាំរបស់ស្នងការនគបាលខេត្ត អធិការកិច្ចនគបាលស្រុកបានកសាងផែនការជាក់ស្តែងដើម្បីទប់ស្កាត់អំពើល្មើសផ្សេងៗ ក្នុងភូមិសាស្ត្រស្រុកក្នុងនោះបានគ្រប់គ្រងមុសញ្ញាគ្រប់ប្រភេទ និងកសាងបណ្តាញព័ត៌មានមូលដ្ឋានសំដៅបំរើការងារទប់ស្កាត់ និងបង្ក្រាបទាន់ពេលវេលា។

**១.៤. បេសកម្ម**

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើនេះ ស្រុកសណ្តាន់ត្រូវផ្តោតជាសំខាន់ទៅលើការពង្រឹង និងការកែលម្អរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលរួមមានដូចខាងក្រោម៖

- ការកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របទៅនឹងចរិតលក្ខណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗ រួមមានការកែសម្រួលរដ្ឋបាលរាជធានីភ្នំពេញឱ្យមានរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារតាមចរិតលក្ខណៈជារដ្ឋបាលក្រុងមេត្រូប៉ូលីតែនរដ្ឋបាលខេត្តឱ្យមានរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ និងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ឱ្យមានរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងារតាមចរិតលក្ខណៈជារដ្ឋបាលមូលដ្ឋាន។
- ការលើកកម្ពស់សមត្ថភាពគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការពង្រឹង និងការកែលម្អប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការរៀបចំ និងការដាក់ឱ្យអនុវត្តតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (អភិបាលកិច្ចឌីជីថល)សាធារណៈ និងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គមដែលរួមចំណែកសម្រេចឱ្យបាននូវគោលបំណងដ៏ទូលំទូលាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ រួមទាំងប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០"។

# ជំពូកទី២

# ការគ្រប់គ្រងរបស់រដ្ឋបាលស្រុក សណ្ដាន់ ខេត្តកំពង់ធំ

# ជំពូកទី២

# ការគ្រប់គ្រងរបស់រដ្ឋបាលស្រុកសណ្ដាន់ ខេត្តកំពង់ធំ

## ២.១.សញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាលសាធារណៈ

ដើម្បីយល់កាន់តែស៊ីជម្រៅទៅលើការគ្រប់គ្រង់រដ្ឋបាលសាធារណៈ ជាបឋមយើងគួរស្វែងយល់អ្វីទៅជាសញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាលសារធារណៈ ក៏ដូចជាអត្ថន័យនៃរដ្ឋបាលសាធារណៈជាមុនសិន។

ការកកើតរដ្ឋបាលសាធារណៈដំបូងផ្ដើមចេញពី "រដ្ឋ" អ្នកខ្លះយល់ថា ការលេចឡើងនូវកម្មសិទ្ធិឯកជន និងការដណ្ដើមយកកម្មសិទ្ធិឯកជន ការបែងចែកវណ្ណៈ និងការជិះជាន់កម្លាំងពលកម្មជាហេតុដែលនាំឱ្យបង្កើតរដ្ឋឡើង។ ការវាយប្រហារដណ្ដើមប្រជាជនជាតិមួយមកលើប្រជាជាតិមួយទៀតដើម្បីដណ្ដើមយកដែនដីមកគ្រប់គ្រងជាហេតុដែលនាំឱ្យ បង្កើតរដ្ឋដែលក្នុងនោះអ្នកឈ្នះជាអ្នកត្រួតត្រាលើអ្នកចាញ់។

បើផ្អែកលើទិដ្ឋភាពប្រវត្តិសាស្ត្រ រដ្ឋត្រូវបានបង្កើតឡើងដោយសារតែតម្រូវការរបស់ក្រុមមនុស្សដែលមានពូជអំបូរតែមួយ រស់នៅលើដែនដីណាមួយជាក់លាក់ បានទាមទារឱ្យបង្កើតស្ថាប័នមួយសម្រាប់ដោះស្រាយសម្របសម្រួលវិវាទផ្សេងៗដែលកើតមានឡើងនៅក្នុងសង្គមរបស់ពួកគេ។ ទស្សនៈមានន័យថា រដ្ឋជាស្ថាប័នអំណាចមួយដែលត្រូវបានបង្កើតឡើងក្នុងគោលបំណង ដើម្បីទប់ស្កាត់នូវរាល់ការបង្កាត់ពូជសាសន៍ពីក្រុមមួយទៅក្រុមមួយផ្សេងទៀត។ ដូចនេះយើងអាចនិយាយបានថា កំណើតដំបូងរបស់រដ្ឋ គឺជាផលិតផលនៃដំណើរការរីកលូតលាស់របស់កត្តាជាជីវសាស្ត្រ សេដ្ឋកិច្ច វប្បធម៌ នយោបាយ និងសាសនា។ល។ ឧ ការចាប់កំណើតបុរីរដ្ឋក្រិកនៅឆ្នាំ៨០០ដល់ឆ្នាំ១៦៨ មុនគ្រីស្តសករាជ។ ការចាប់កំណើតអាណាចក្ររដ្ឋរ៉ូម៉ាំងក្នុងតំបន់ទ្វីបលោកខាងលិចនៅ២៧ឆ្នាំមុនគ្រីស្តសករាជ និងនៅកម្ពុជាដូចជាការកកើតទឹកដីនៅសម័យព្រះនាងលីវយី ដែលមានឈ្មោះថានគរគោកធ្លកនាសតវត្សរ៍នៃគ្រឹស្តសករាជ។តែទោះជាយ៉ាង មានអ្នកប្រាជ្ញជាច្រើនដែលឱ្យអត្ថន័យទៅលើរដ្ឋដូចជាលោក អារីស្តូតយល់ថា រដ្ឋជាទំរង់ម្យ៉ាងក្នុងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមករបស់មនុស្សដើម្បីទទួលបាននូវភាពប្រសើរនៃជីវិត។ ចំណែកលោកកាល់ម៉ាក្សយល់ថា រដ្ឋគឺជាក្បាម៉ាស៊ីនគ្របដណ្ដប់លើសង្គម និងជាឧបករណ៍ជិះជាន់ពីវណ្ណៈមួយទៅលើវណ្ណៈមួយទៀត។ បើតាមទស្សនៈកង់យល់ថា រដ្ឋ គឺជាអង្គការបង្រួបបង្រួមចូលគ្នានៃកន្សោមមនុស្សដ៏ច្រើនកុះករក្រោមសំណាញ់ច្បាប់នៃរដ្ឋធម្មនុញ្ញតែមួយ។ មានទស្សនៈជាច្រើនដែលមានលើកឡើង និងពន្យល់យ៉ាងច្បាស់លាស់ក្នុងអត្ថន័យនយោបាយប្រវត្តិសាស្ត្រដែលបានលើកនូវហេតុផលសំខាន់ៗខុសគ្នានៃការកកើតឡើងរបស់រដ្ឋ។ គេអាចឱ្យនិយមន័យជារួមបានថាៈ

រដ្ឋ គឺជាសង្គមមនុស្សដែលរស់នៅជាប់លាប់លើទឹកដីមួយ ដោយមានអំណាចនយោបាយមួយគ្រប់គ្រងយ៉ាងទៀតទាត់។ ក្នុងន័យនេះដើម្បីក្លាយជារដ្ឋមួយត្រូវមានធាតុផ្សំរបស់វា ទឹកដី ប្រជាជន និងអំណាចនយោបាយ។

រដ្ឋគឺជាការប្រកាន់យករបបនយោបាយមួយ ហើយរដ្ឋនីមួយៗដែលកើតមានឡើង អាស្រ័យដោយការប្រមូលផ្តុំនៃប្រជាពលរដ្ឋ "**ប្រជាជន**" ដែលមានភាសា វប្បធម៌ ប្រពៃណីទំនៀមទំលាប់ និងរបបសេដ្ឋកិច្ចរួមគ្នា ដូចនេះហើយរដ្ឋកើតឡើងពីការប្រមូលផ្តុំរបស់ប្រជាជនដោយប្រកាន់យករបបនយោបាយតែមួយដូចគ្នា។[15]

## ២.១.១. និយមន័យ

ពាក្យថា**រដ្ឋបាល**(Administration) មានអត្ថន័យទូលំទូលាយណាស់ហើយក៏មានអត្ថន័យជាច្រើនផ្សេងៗគ្នា ប៉ុន្តែយើងសូមលើកយកអត្ថន័យសំខាន់ៗមកបង្ហាញដូចតទៅៈ

- **អត្ថន័យបែបអក្សរសាស្ត្រៈ** តាមវចនានុក្រមសម្តេចសង្ឃរាជ **ជួន ណាត** ពាក្យ រដ្ឋបាលត្រូវបានពន្យល់ដោយញែកពាក្យនេះជាពីរ គឺពាក្យ **រដ្ឋ** និងពាក្យ **បាល**។[16] រដ្ឋ មានន័យថា នគរប្រទេសឬដែនស៊ុំ រដ្ឋបាលមានន័យថា គ្រប់គ្រងថែរក្សាការពារប្រទេស...។ តាមន័យសាមញ្ញមានន័យថាៈ ការថែរក្សា ការគ្រប់គ្រង។ កិច្ចការងាររដ្ឋបាល គឺជាការងារចាត់ចែង ការដឹកនាំ កិច្ចការទំនាក់ទំនងដោយរាប់បញ្ចូលទាំងការងារ សណ្តាប់ធ្នាប់ និងវិន័យផងដែរ។

ដូច្នេះ រដ្ឋបាល មានន័យថា ការគ្រប់គ្រង ថែរក្សា ការពារប្រទេសឬនគរ។ ការគ្រប់គ្រងថែរក្សា គឺត្រូវធ្វើឡើងក្នុងន័យឱ្យមានភាពគង់វង្ស សន្តិភាព របៀបរៀបរយ សណ្តាប់ធ្លាប់ សុខមាលភាព ការអភិវឌ្ឍ និងភាពសុខក្សេមក្សាន្តដល់ប្រជាពលរដ្ឋ និងសង្គមជាតិទាំងមូល។

**រដ្ឋបាល** គឺជាយន្តការដែលប្រមូលផ្តុំគ្នា រួមទាំងគោលនយោបាយ លិខិតបទដ្ឋាន នីតិវិធី ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ អង្គការចាត់តាំងបុគ្គលិក.. ហើយយន្តការនេះមានការទទួលខុសត្រូវក្នុងការគ្រប់គ្រងការងារទាំងឡាយរបស់រដ្ឋាភិបាលដោយធ្វើទំនាក់ទំនងគ្នាទៅវិញទៅមកជាមួយរដ្ឋ សង្គមនិងបរិស្ថានខាងក្រៅ ដទៃទៀត។ រដ្ឋបាល គឺជារបៀបចាត់ចែងការងារ បម្រើបុគ្គលឬសមូហភាពណាមួយ ដើម្បីសម្របសម្រួលឋានានុក្រមការងារនោះជូនបុគ្គលឬសមូហភាពដែលខ្លួនកំពុងស្ថិតនៅ។ រដ្ឋបាល គឺជាដំណើរនៃការអនុវត្តនូវសេចក្តីសម្រេច និងគោលនយោបាយ។ **សាធារណៈ** តាមវចនាក្រមសម្តេចសង្ឃ ជួន ណាត មានន័យថា ជាទូទៅមិនចំពោះនណាម្នាក់ឬអ្វីមួយដែលប្រើសម្រាប់ទាំងអស់គ្នា។

- **ន័យទូលាយបែបបច្ចេកទេស** រដ្ឋបាលមានន័យពីរៈ ដែលអាចប្រើប្រាស់បានទាំងវិស័យសាធារណៈ និងវិស័យឯកជន។ តាមន័យទី១ រដ្ឋបាល សំដៅដល់**សកម្មភាព**គ្រប់គ្រងកិច្ចការគ្រប់គ្រងរដ្ឋបាលឬកិច្ចការរដ្ឋបាលដោយទំនាក់ទំនតាមលិខិតស្នាមផ្សេងៗ ការបញ្ជូនលិខិត ការទទួលលិខិត ការទុកដាក់ឯកសារ

[15] សៀវភៅសេចក្តីផ្តើម រដបាលសាធារណៈរបស់ បណ្ឌិត សឿន សោភ័ណ

[16] វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត

ការរៀបចំប្រជុំ និងការងារពិធីការជាដើម។ តាមន័យទី២ រដ្ឋបាលសំដៅដល់ **អង្គការ** ដែលគ្រប់គ្រង (រចនាសម្ព័ន្ធរដ្ឋបាលឬអង្គការលេខ ដែលជាអង្គការដឹកនាំរបស់ក្រសួងឬក្រុមហ៊ុននីមួយៗ) ដែលមានតួនាទីបម្រើផលប្រយោជន៍ទូទៅ។

- **ន័យចង្អៀតបែបបច្ចេកទេស** ពាក្យថារដ្ឋបាល គឺសំដៅដល់រដ្ឋបាលសាធារណៈ ដោយយើងអាចប្រើពាក្យថា រដ្ឋការដែលមិននាំឱ្យមានការភាន់ច្រឡំជាមួយនឹងពាក្យ រដ្ឋបាលក្នុងវិស័យឯកជន។ ដោយពាក្យរាជការគឺសំដៅដល់ក្រសួង ស្ថាប័ន អង្គភាពនិមួយៗរបស់រដ្ឋ ដែលមានមន្ត្រីរាជការស្ថិតក្នុងក្របខណ្ឌរដ្ឋ មានមុខដំណែង តួនាទី និងទទួលប្រាក់បៀវត្សពីរដ្ឋ។ គេអាចឱ្យនិយមន័យជាសង្ខេបបានថា៖

រដ្ឋបាលគឺជារចនាសម្ព័ន្ធនៃការគ្រប់គ្រងមួយដែលប្រមូលផ្ដុំចូលគ្នា នៅគោលនយោបាយសាធារណៈ លិខិតបទដ្ឋានគតិយុត្ត នីតិវិធី ប្រព័ន្ធនៃការដឹកនាំស្ថាប័នប្រព័ន្ធ នៃការគ្រប់គ្រងដែនដី ការចាត់តាំងនិងរូបមន្តឃុំឃុំត្រូវ ដោនឡូតហើយមានការទទួលខុសត្រូវក្នុងការគ្រប់គ្រង និងគោលដៅច្បាស់លាស់ក្នុងការឆ្ពោះទៅអនុវត្តន៍ការងារទាំងឡាយរបស់រដ្ឋាភិបាលដែលការធ្វើឱ្យប្រាក់សុខានភាពជាមួយភ្នាក់ងារអរភន្តទៅតាមវិស័យឃើញក្នុងនីតិបុគ្គលនិងបក្សពួកឋានក្រៅពីនីតិបុគ្គល។

ចំណែកឯពាក្យ **រដ្ឋបាលសាធារណៈ** មានន័យដូចខាងក្រោម៖

តាមទស្សនៈរបស់លោក Russell and Shalfritz ឆ្នាំ១៩៩៧ ក្នុងការកំណត់និយមន័យរដ្ឋបាលសាធារណៈ វាគឺជាការលំបាកក្នុងការផ្ដល់និយមន័យរដ្ឋបាលសាធារណៈមួយដែលអាចទទួលយកបានដោយគ្រប់ភាគី។ អាស្រ័យហេតុនេះ លោកទាំងពីរបានផ្ដល់និយមន័យមួយចំនួនដោយផ្អែកទៅលើជំនាញបួនគឺ៖ **វិទ្យាសាស្ត្រនយោបាយ វិទ្យាសាស្ត្រច្បាប់ វិទ្យាសាស្ត្រការគ្រប់គ្រង និងផ្នែកវិជ្ជាជីវៈ មានដូចតទៅ៖**

- **និយមន័យដោយផ្អែកលើវិទ្យាសាស្ត្រនយោបាយ រដ្ឋបាលសាធារណៈ** គឺជាអ្វីដែលរដ្ឋាភិបាលធ្វើ ជាដំណាក់កាលមួយក្នុងខួបនៃការបង្កើតគោលនយោបាយសាធារណៈ និងការអនុវត្តផលប្រយោជន៍សាធារណៈ (មានលក្ខណៈជារួមដែលបុគ្គលតែម្នាក់ឯងមិនអាចអនុវត្តបាន)។
- **និយមន័យផ្អែកលើច្បាប់** បានកំណត់ថា រដ្ឋបាលសាធារណៈ គឺជាការអនុវត្តច្បាប់-អនុវត្តបទបញ្ញាឬជាការសម្របសម្រួល និងជាសកម្មភាពរបស់អ្នកគ្រប់គ្រងឬព្រះរាជាក្នុងការផ្ដល់ឬប្រទានអ្វីមួយដល់ប្រជាពលរដ្ឋ។
- **និយមន័យផ្អែកលើការគ្រប់គ្រង** រដ្ឋបាលសាធារណៈ គឺជាសិល្បៈតែមិនមែនវិទ្យាសាស្ត្រទេ។

- **និយមន័យផ្អែកលើវិជ្ជាជីវៈបានកំណត់ថា៖** រដ្ឋបាលសាធារណៈ គឺជាប្រភេទនៃវិជ្ជាជីវៈមួយ ដែលចាប់ផ្តើមតាំងពីអ្នកបោសសំរាមរហូតដល់អ្នកជំនាញ ជាអនុវត្តឧត្តមគតិនិយម និងជាផ្នែកសិក្សាមួយដែលតែងតែសិក្សាអំពីសិល្បៈ និងវិទ្យាសាស្រ្តគ្រប់គ្រងសម្រាប់យកទៅអនុវត្តនៅក្នុងផ្នែកសាធារណៈ។

យោងតាមនិយមន័យខាងលើ លោក T.Keban(2004) បានធ្វើការសំយោគដូចខាងក្រោម៖

- រដ្ឋបាលសាធារណៈទៅនឹងផ្នែកនីតិប្រតិបត្តិច្រើនជាងផ្នែកនីតិប្បញ្ញត្តិ និងតុលាការ
- រដ្ឋបាលសាធារណៈ មានទំនាក់ទំនងជាមួយបញ្ហាមនុស្ស និងសហការគ្នាដើម្បីដំណើរការងាររដ្ឋាភិបាល
- ទោះបីរដ្ឋបាលសាធារណៈ មានភាពខុសគ្នាជាមួយនឹងរដ្ឋបាលឯកជន ប៉ុន្តែវាមានឥទ្ធិពលគ្របដណ្តប់ទៅលើរដ្ឋបាលឯកជន
- រដ្ឋបាលសាធារណៈមានលក្ខណៈតម្រង់ទិសផលិតកម្ម។

ជាទូទៅគេសង្កេតឃើញនៅគ្រប់អង្គការសង្គមឬក្រុមហ៊ុនឯកជន ដើម្បីរៀបចំដំណើរការទៅបានល្អលុះត្រាតែអង្គការរដ្ឋឬក្រុមហ៊ុននោះត្រូវរៀបចំនិងពង្រីករដ្ឋបាលជាមុនសិន។ ឧទាហរណ៍ ប្រសិនគេបង្កើតក្រុមហ៊ុនមួយ ជាដំបូងគេត្រូវបង្កើតរដ្ឋបាលបណ្តោះអាសន្នមួយជាមុនសិន ដូចជាការរៀបចំទីកន្លែង សម្ភារៈ និងរៀបចំសំណុំលិខិតបទដ្ឋានគតិយុត្តិក្នុងគោលបំណងសុំបើកក្រុមហ៊ុនឱ្យដំណើរការទៅបាន។ ជារួម តាមន័យទូលាយពាក្យថា រដ្ឋបាល ជួលកាលសំដៅលើ "**សកម្មភាពគ្រប់គ្រង**" ឧទារហរណ៍ កិច្ចការរដ្ឋបាលរបស់ក្រុមហ៊ុនកាត់ដេរ(វិស័យឯកជន) កិច្ចការរដ្ឋបាលរបស់ក្រសួងពាណិជ្ជកម្ម(វិស័យរដ្ឋឬវិស័យឯកជន) ជួលកាលសំដៅលើ "**អង្គភាព**" ដែលគ្រប់គ្រង ដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនអាហារ៍ណែ(វិស័យឯកជន) ក្រសួងពាណិជ្ជកម្ម(វិស័យ រដ្ឋឬសាធារណៈ)។ ន័យទាំងពីរនេះ គឺមានប្រើខាងវិស័យឯកជន ទាំងវិស័យរដ្ឋឬសាធារណៈ។

បើពិនិត្យមើលតាមន័យទូលាយខាងលើនេះ សកម្មភាពរដ្ឋបាលរបស់ពួកឯកជនក៏មានរបស់រដ្ឋក៏មាន ប៉ុន្តែការរកផលប្រយោជន៍នៃវិស័យឯកជន និងវិស័យរដ្ឋឬសាធារណៈមិនដូចគ្នាទេ។ វិស័យ **ឯកជនរកប្រយោជន៍ចំណេញផ្ទាល់ខ្លួន ឯរដ្ឋបម្រើប្រយោជន៍សាធារណៈមនុស្សទូទៅ**។ ដូចនេះ រដ្ឋត្រូវមានវិធានការគ្រប់គ្រងរដ្ឋបាលផ្សេងពីឯកជន។ រដ្ឋបាលក្នុងន័យនេះ គឺសំដៅលើរដ្ឋបាលសាធារណៈដែលគេនិយមហៅថា **រាជការ ឬរដ្ឋការ**។ រដ្ឋបាលសាធារណៈ គឺជាស្ថាប័នទាំងឡាយណាដែលមាននៅក្នុងរដ្ឋនីមួយៗមានតួនាទីបម្រើផលប្រយោជន៍សាធារណៈ ឬ បម្រើផលប្រយោជន៍រួមទូទៅ ដែលជាទូទៅរដ្ឋបាលសាធារណៈស្ថិតនៅក្រោមការដឹកនាំរបស់**អង្គការនីតិប្រត្តិបត្តិ** ហើយរដ្ឋបាលសារណៈមានបេសកកម្មគិតគូរបម្រើផលប្រយោជន៍ទូទៅក្នុងការរស់នៅ ឬផ្តល់តម្រូវការជាប្រចាំរាល់ថ្ងៃដល់ប្រជាជនគ្រប់រូបឱ្យបានកាន់តែប្រសើរ ដូចជា ការផ្តល់លិខិតអនុញ្ញាត បញ្ជីអត្រានុកូលដ្ឋាន សុំបុត្រកំណើត ប័ណ្ណកម្មសិទ្ធិ អត្តសញ្ញាណប័ណ្ណ

ប្រជាពលរដ្ឋ ការរក្សាសណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសន្តិសុខសង្គម ការដោះស្រាយវិវាទផ្សេងៗតាមរយៈប្រព័ន្ធតុលាការ ការផ្តល់ការអប់រំ ការផ្គត់ផ្គង់សេវាសុខាភិបាលដល់មូលដ្ឋាន ការកសាងប្រព័ន្ធផ្លូវគមនាគមន៍ដឹកជញ្ជូន មន្ទីរពេទ្យ សាលារៀន ប្រព័ន្ធទឹកស្អាត ប្រព័ន្ធធារា សាស្ត្រ អគ្គីសនី ទូរគមនាគមន៍។ល។

**២.១.២. គោលការណ៍នៃការគ្រប់គ្រង**

គោលការណ៍នៃការគ្រប់គ្រងរដ្ឋបាលគឺជា ផ្នែកមួយដ៏សំខាន់សម្រាប់ការអនុវត្តនូវរាល់សកម្មភាពរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍនិងពង្រឹងបន្ថែមទៅលើវិស័យណាមួយឱ្យកាន់តែល្អប្រើសើថែមទៀត។

គោលការណ៍នៃការគ្រប់គ្រងរដ្ឋបាលសាធារណៈមានដូចជា៖

- គោលការណ៍និរន្តភាពនៃរដ្ឋបាលសាធារណៈ
- គោលការណ៍និត្យានុកូលភាព
- គោលការណ៍សមភាពចំពោះអ្នកប្រើប្រាស់សេវាសាធារណៈ
- គោលការណ៍អាព្យាក្រឹតភាព
- គោលការណ៍ក្នុងការផ្លាស់ប្តូរមន្ត្រីរាជការតាមតម្រូវការចាំបាច់របស់រដ្ឋបាលសាធារណៈ
- គោលការណ៍តម្លាភាព
- គោលការណ៍សមាតភាពពិត
- គោលការណ៍បរិសុទ្ធភាព
- គោលការណ៍ទទួលខុសត្រូវ
- គោលការណ៍យត្តិធម៌។[17]

នៅក្នុងគោលការណ៍ការគ្រប់គ្រង់រដ្ឋបាលក៏ត្រូវបានបែងចែកជាប្រព័ន្ធផ្សេងទៀតដូចខាងក្រោមរួមមាន៖

**ក. ប្រព័ន្ធមជ្ឈការ និងនិយមន័យ**

ប្រព័ន្ធមជ្ឈការ គឺជាការគ្រប់គ្រងរដ្ឋមួយប្រភេទ ដែលរដ្ឋាភិបាលដឹកនាំរដ្ឋដោយផ្ទាល់ហើយអាជ្ញាដែនដីគ្រាន់តែជាស្ពានប៉ុណ្ណោះ។ បើគេនិយាយ ពីមជ្ឈការ គឺគេនិយាយអំពីអំណាចកណ្តាល គឺអំណាចរដ្ឋបាលរបស់រដ្ឋាភិបាល ដែល កាន់កាប់ដោយ នាយករដ្ឋបន្ត្រី និង រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន ទាំងឡាយ។ ប្រព័ន្ធការមជ្ឈការមានគោលបំណងធំ បី គឺ៖

- និតិបុគ្គលសាធារណៈមានតែរដ្ឋ
- អំណាចសំរេចសេចក្តី និងបញ្ជាស្ថិតនៅរដ្ឋបាលកណ្តាលទាំងអស់

[17] សៀវភៅសេចក្តីផ្តើម រដបាលសាធរណៈ, បណ្ឌិត សឿន សោភ័ណ ទំព័រ ១៣០

➢ រដ្ឋបាលទាំងអស់ត្រូវរៀបចំតាមឋានានុក្រម។[18]

**ចរិកលក្ខណៈ៖** ការគ្រប់គ្រង់រដ្ឋបាល តាមប្រព័ន្ធនេះ គឺគេធ្វើការគ្រប់គ្រង់តាម តារាងសាជីជ្រុង ដោយអំណាចក្នុងការសម្រេចទាំងអស់ជារបស់រដ្ឋបាលកណ្តាល។ ដូចនេះហើយរាល់ការបង្កើត និងការសម្រេច ការកែប្រែអ្វីៗមួយ គឺធ្វើដោយរដ្ឋបាលកណ្តាលទាំងអស់។ ឧទាហរណ៍ ៖ លោក "ក" ជាអភិបាលនៃខេត្តណាមួយ គាត់មិនមានសិទ្ធក្នុង ការចេញលិខិតឆ្លងដែនឱ្យប្រជាពលរដ្ឋ ប្រទេសជិតខាងនោះទេ។ផ្ទុយទៅវិញប្រជាពលរដ្ឋត្រូវមកធ្វើការសុំធ្វើលិខិត ឆ្លងដែនដែនពីរដ្ឋបាលកណ្តាល។

❖ **គុណសម្បត្តិ**

➢ អំណាចកណ្តាលជួយខេត្តបាន

➢ អំណាចកណ្តាលតែងតាំងទាំងសុទ្ធតែជាមនុស្សមានសមត្ថភាព

➢ មានឯករាជភាពជាតិ (មានន័យថារដ្ឋកំណត់ធ្វើអ្វីមួយដូចគ្នាទាំងអស់នាំឱ្យមាន ឯកភាពខាង ទស្សនៈ ហើយឯកភាពនៃប្រទេសជាតិមានភាពរឹងមាំ។)

❖ **គុណវិបត្តិ**

➢ យឺតយ៉ាវខាងសាហ៊ុយ (រដ្ឋបាលសម្រេចតែម្នាក់ឯងដោយអត្តនោម័ត)

➢ ខ្វះលទ្ធភាពប្រជាធិតេយ្យ(អាជ្ញាធរតែងតាំង)

➢ សម្រេចកិច្ចការដោយមិនយល់សភាពការណ៍ (សម្រេចលើកិច្ចការដែលខ្លួនស្តាប់មិនបាន) រដ្ឋការមិនបានដឹងពីតម្រូវការ របស់ពលរដ្ឋមូលដ្ឋាន ហើយមិនឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋ។

**ខ. ប្រព័ន្ធវិមជ្ឈការ និងនិយមន័យ**

គឺជាប្រព័ន្ធមួយដែលអាជ្ញាធររដ្ឋបាលកណ្តាល ទទួលស្គាល់នូវសិទ្ធ អំណាច ក្នុងការសម្រេច របស់អាជ្ញាធររដ្ឋបាល មូលដ្ឋាន ដោយមានចែង នៅក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់នានា។ វិមជ្ឈការជាប្រព័ន្ធ រដ្ឋបាលមួយដែលអនុញ្ញាត អោយសមូហភាពដែនដី ឬសេវាសាធារណៈធ្វើការគ្រប់គ្រង ដោយខ្លួនឯង ក្នុងក្របខ័ណ្ឌនៃកាគោរពគោលការណ៍ និត្យានុកូលភាព។

❖ ន័យម្យ៉ាងទៀត **វិមជ្ឈការ** មានន័យថា រាជរដ្ឋាភិបាល **ប្រគល់នូវភាពជាម្ចាស់** លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឱ្យទៅក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ដូចជា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុម

[18] សៀវភៅសេចក្តីផ្តើម រដបាលសាធរណៈ, បណ្ឌិត សឿន សោភ័ណ ទំព័រ ១៣១

ប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន។**ឧទាហរណ៍៖** រាជរដ្ឋាភិបាលបានផ្ទេរថវិកាចំនួន ៤០លានរៀល សម្រាប់ជាថវិការបស់រដ្ឋបាលស្រុកមួយក្នុងគោលដៅនៃ ការអភិវឌ្ឍ។ ក្រុមប្រឹក្សាស្រុកនោះមានភាពជាម្ចាស់ក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិកានោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ស្រុក ដោយផ្អែកតាមកម្មវិធីវិនិយោគ និងផែនការអភិវឌ្ឍស្រុក ដែលបានអនុម័តដោយក្រុមប្រឹក្សាដូចជា សម្រាប់ជីកអណ្តូងទឹកស្អាត ជួសជុលផ្លូវលំ និងផ្សព្វផ្សាយ អំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនៅក្នុងសហគមន៍តាមតម្រូវការរបស់ប្រជាពលរដ្ឋជាដើម។ ក្នុងន័យនេះ ថវិកា៤០លានរៀល រដ្ឋាភិបាលបានផ្តល់នូវភាពជាម្ចាស់ក្នុងការគ្រប់គ្រងដល់ក្រុមប្រឹក្សាហើយក្រុមប្រឹក្សាមានភាពម្ចាស់ក្នុងការជ្រើសរើសគម្រោងមួយចំនួនដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋដោយប្រើប្រាស់ថវិកានេះ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការប្រើប្រាស់ថវិកាទាំងនេះ ក្រុមប្រឹក្សាត្រូវតែអនុវត្តតាមនីតិវិធីដែលបានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានស្តីពីថវិកាស្រុក។

**ចរិកលក្ខណៈ**ទោះបីទម្រង់នៃការរៀបចំ នេះបានប្រគល់អោយសមូហភាពដែនដីនូវសិទ្ធអំណាច ក្នុងការសម្រេចប្រកបដោយស្វ័យភាពក៏ដោយ ក៏នៅមានកិច្ចការធំៗមួយចំនួន អជ្ញាធរកណ្តាលអោប ក្រសោបតែម្នាក់ឯងនោះគឺ៖

- កិច្ចការពារជាតិ(កងទ័ព)
- កិច្ចការសន្តិសុខ(នគរបាល)
- កិច្ចការពាណិជ្ជកម្មក្រៅប្រទេស
- កិច្ចការតុលាការ
- កិច្ចបោះពុម្ពប្រាក់
- កិច្ចការធ្វើច្បាប់
- កិច្ចការកទូត
- កិច្ចការអត្រានុកូលដ្ឋាន
- ធនធានធម្មជាតិ។

រដ្ឋបាលកណ្តាលផ្តល់សមូហភាពដែនដីអោយទៅ រដ្ឋបាលមូលដ្ឋានភាគ ច្រើន គឺផ្នែក សេដ្ឋកិច្ច វប្បធម៌ និង ការងារអភិវឌ្ឍ។

❖ **គុណសម្បត្តិ**

- ចំណាយពេលវេលាតិចក្នុងការ ទទួលសេវានាំអោយមានការអភិវឌ្ឍ ហើយប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការរស់នៅ
- ស្វ័យភាពការងារនាំអោយមានកម្លាំងចិត្ត ជាគ្រឹះនៃប្រជាធិបតេយ្យតាមមូលដ្ឋាន
- មានលទ្ធិប្រជាធិបតេយ្យស៊ីជម្រៅ ព្រោះមានការចូលពីប្រជាពលរដ្ឋក្នុងការ សម្រេចនូវអ្វីៗ ដែលជាប្រយោជន៍រាស្ត្រ។

❖ **គុណវិបត្តិ**

- អាចបែកបាក់សាមគ្គីរវាងសមូហភាព និងសមូហភាព
- ធ្វើឱ្យអាជ្ញាធរកណ្តាលមានការទន់ខ្សោយ
- ការអភិវឌ្ឍអាចតាមរបៀបអាណាធិបតេយ្យព្រោះ ការអភិវឌ្ឍមានការ ប្រកួតប្រជែងនាំឱ្យមានការប៉ះពាល់ ដល់សមូហភាពរៀងៗខ្លួន។
- ប្រព័ន្ធមជ្ឈការគ្មានអំណាច ឋានានុក្រមទេ ព្រោះអជ្ញាធរនីមួយៗ មានសិទ្ធសម្រេចរៀងៗ ខ្លួនតាមច្បាប់កំណត់។

**គ. វិសហមជ្ឈការ និងនិយមន័យ**

គឺជាបច្ចេកទេសរដ្ឋបាលមួយ ដែលអាជ្ញាធររដ្ឋបាល កណ្តាល រំលែកអំណាច ឬកិច្ចការមួយចំនួនឱ្យទៅរដ្ឋបាលមូលដ្ឋាន ធ្វើការសម្រេច ដោយខ្លួនឯងផ្ទាល់ មានន័យថា បច្ចេកទេស មួយក្នុងការៀបចំរដ្ឋ ដើម្បីជួយសម្រួល ដល់ប្រព័ន្ធមជ្ឈការ ហើយបានផ្តល់ឱ្យនៅអំណាចខ្លះៗ ដែរពីមុនវាជាអំណាចរបស់រដ្ឋបាលកណ្តាល។ ឯន័យម្យ៉ាងទៀត **វិសហមជ្ឈការ** មានន័យថា រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន **ធ្វើប្រតិភូកម្ម** មុខងារ សិទ្ធិអំណាច និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តមុខងារនេះ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័ននោះ។ ក្នុងន័យនេះ ភាពជាម្ចាស់មិនបានផ្តល់ជូនអង្គភាពក្រោមបង្គាប់ ឬក្រុមប្រឹក្សាឡើយ។ រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលបានរក្សាភាពជាម្ចាស់នោះ។

**ឧទាហរណ៍១៖**ក្រសួងកសិកម្ម ធ្វើប្រតិភូកម្មមុខងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មឱ្យទៅមន្ទីរកសិកម្មខេត្ត ព្រមទាំងផ្តល់ធនធាន និងបច្ចេកទេសឱ្យមន្ទីរកសិកម្មខេត្ត ដើម្បីផ្សព្វផ្សាយដល់ប្រជាកសិករនៅក្នុងខេត្តរបស់ខ្លួន។ មន្ទីរកសិកម្មខេត្តធ្វើការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម តាមការណែនាំរបស់ក្រសួងកសិកម្មក្នុងនាមជាតំណាងឱ្យក្រសួងកសិកម្ម។

**ចរិកលក្ខណៈ** ៖ ក្នុងការគ្រាប់គ្រង់រដ្ឋបាលតាមបច្ចេកទេសនេះ គឺគ្រប់គ្រង់តាម ឋានានុក្រម រដ្ឋបាលដែរ រដ្ឋបាល កណ្តាលបានផ្តល់ ឱ្យសម្រេច តាមលំដាប់ ថ្នាក់រៀងខ្លួន។ រាល់ប្រព័ន្ធការងារ គឺតាំងតំណាង រដ្ឋបាល កណ្តាល ដោយគ្មាន ការបោះឆ្នោត ជ្រើសតាំងអ្វីទេពោលគឺ អាជ្ញាធរមូលដ្ឋាន កើតមានឡើងនូវ សិទ្ធក្នុងការ សម្រេច អាស្រ័យដោយសប្បុរសធម៌របស់ អាជ្ញាធររដ្ឋបាលកណ្តាល ប៉ុណ្ណោះ។ អាជ្ញាធរ មូលដ្ឋានគ្មានថវិកា ផ្ទាល់ខ្លួនទេ គឺប្រើថវិការបស់ជាតិ ហើយក៏គ្មានសិទ្ធក្នុងការជ្រើស រើសបុគ្គលិកដែរ។

- **គុណសម្បត្តិ**
  - កាត់បន្ថយការប្រើប្រាស់អំណាចហួសហេតុរបស់អាជ្ញាធរកណ្តាល
  - អាជ្ញាធរមូលដ្ឋានសម្រេចបញ្ហានៅនឹងកន្លែង
  - ការងារឆាប់រហ័យចំនេញពេលវេលា និង ថវិកា
- **គុណវិបត្តិ**
  - ខ្វះលទ្ធិប្រជាធិបតេយ្យ (រាល់ការសម្រេចស្ថិតនៅលើអំណាចកណ្តាល)។
  - អាចបែកបាក់សាមគ្គីរវាងសមូហភាព និងសមូហភាព
  - ធ្វើឱ្យអាជ្ញាធកណ្តាលមានការទន់ខ្សោយ
  - ការអភិវឌ្ឍអាចតាមរបៀបអាណាធិបតេយ្យ ព្រោះការអភិវឌ្ឍមានការប្រគួតប្រជែង នាំឱ្យមានការប៉ះពាល់ដល់សមូហភាពរៀងៗ ខ្លួន។
  - ប្រព័ន្ធមជ្ឈការគ្មានអំណាចឋានានុក្រមទេ ព្រោះអជ្ញាធរនីមួយៗមានសិទ្ធិសម្រេចរៀងៗ ខ្លួនតាមច្បាប់កំណត់។

### ២.១.៣. មុខងាររដ្ឋបាល

សាលាស្រុកគឺជា ការិយាល័យធ្វើការរបស់ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុកដែលត្រូវបានធ្វើការ ឱ្យបានទៀងទាត់តាមពេលវេលាម៉ោងធ្វើការរបស់រដ្ឋ។[19] រដ្ឋបាលស្រុកនីមួយៗត្រូវធ្វើជាម្ចាស់ហើយ នឹងទទួល ខុសត្រូវរាល់ការចាត់ចែងលើលិខិតស្នាម ឯកសារទាំងអស់ដែលបានទទួលត្រឹមត្រូវឱ្យបានស្របតាមច្បាប់ជាធរមាន។

រដ្ឋបាលស្រុកត្រូវបំពេញមុខងារតាមការកំណត់នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមុខងារដែលបានផ្ទេរពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។ មុខងារ ពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងវិស័យនីមួយៗត្រូវបានប្រគល់និងប្រតិភូកម្មទ

[19] សៀវភៅណែនាំ ស្តីពី តួនាទី និងរបៀបបែបការងាររបស់រដ្ឋបាលស្រុកឆ្នាំ ២០១០

ឱ្យរដ្ឋបាលស្រុកដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ១៨៤ អនក្រ.បកចុះ ថ្ងៃទី២ ខែធ្នូ ឆ្នាំ ២០១៩ លើកលែងតែមុខងារក្នុងវិស័យអប់រំយុវជននិងកីឡារបស់រដ្ឋបាលស្រុកនានាដែលមានចែងក្នុងជំពូកទី ៧ នៃអនុក្រឹត្យនេះ។ មុខងារសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលស្រុករួមមានមុខងារជាកាតព្វកិច្ចនិងមុខងារជាជម្រើស។ ការត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងចែកចាយ និងការអនុវត្តមុខងារជាកាតព្វកិច្ចនានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយផ្អែកតាម គោលការណ៍នីតិវិធីស្តង់ដារសេវា និងធនធានដែលបានផ្ទេរ មានភ្ជាប់លក្ខខណ្ឌ ព្រមទាំងអាចប្រើប្រាស់ធនធានរបស់ខ្លួនឬធនធានដែលគៀគរបានពីប្រភពស្របច្បាប់ផ្សេងទៀតដើម្បី អនុវត្តមុខងារជាកាតព្វកិច្ចទាំងអស់នោះឱ្យកាន់តែមានប្រសិទ្ធភាព។[20] គោលការណ៍នីតិវិធី និងស្តង់ដារសេវាសម្រាប់គ្រប់គ្រងចាត់ចែងនិងការអនុវត្តមុខងារកត្តាប្រកាសរៀបចំ និងកំណត់ដោយក្រសួងស្ថាប័ននៃវិស័យនីមួយៗ។[21]

រដ្ឋបាលស្រុកមានវិស័យភាពក្នុងការសម្រេចជ្រើសរើស ឬមិនជ្រើសយកមុខងារជាជម្រើសណាមួយមកអនុវត្តផ្អែកតាមតម្រូវការជាអតិភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋបាលស្រុកមានសិទ្ធសម្រេចអំពី របៀបគ្រប់គ្រងចាត់ចែងនិងអនុវត្តមុខងារជាជម្រើសដោយអនុលោមតាមបទដ្ឋាន និងនីតិវិធីដែលមានចែងក្នុងច្បាប់ឬព្រះរាជក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្រសួងស្ថាប័ននិងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវត្រួតពិនិត្យមើលឡើងវិញនូវមុខងាររបស់ខ្លួន ដើម្បីបន្តផ្ទេរមុខងារសមស្របទៅឱ្យរដ្ឋបាលថ្នាក់ស្រុកស្របទៅតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជ រដ្ឋាភិបាល។

[20] មាត្រា៤ នៃអនុក្រឹត្ត ស្តីពី មុខងាររបស់រដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥

[21] អនុក្រឹត្ត ស្តីពី មុខងារ និងរចនាសម្ព័នរដ្ឋបាលស្រុក ២០១៩

## ២.២. រចនាសម្ព័ន្ធ និងតួនាទីរដ្ឋបាល ស្រុក

រចនាសម្ព័ន្ធរដ្ឋបាលស្រុកសណ្ដាន់




បច្ចុប្បន្ននេះនៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុកនីមួយៗត្រូវបានគ្រប់គ្រងដោយ ក្រុមប្រឹក្សាគណៈអភិបាល គណៈកម្មាធិការ៤ គណៈអភិបាល ការិយាល័យជំនាញ នាយករដ្ឋបាល និងការិយាល័យរដ្ឋបាល។ ស្រុក គឺជារដ្ឋបាលស្រុកដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុក នៅក្នុងនោះផងដែររចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ លើការផ្ទេរសិទ្ធិអំណាច ផ្ទេរមុខងារ និងធនធាន នៅកៀកជាមួយប្រជាពលរដ្ឋជាគោលដៅដល់មុតស្រួច ក្នុងការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋតាមបែបលទ្ធិប្រជាធិបតេយ្យ។ មិនតែប៉ុណ្ណោះ ក្នុងនោះដែលរាជរដ្ឋាភិបាលក៏បានដាក់ចេញនូវរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលស្រុក ដែលក្នុងនោះក្រុមប្រឹក្សាស្រុកជាអ្នកចាត់ចែកអនុវត្តតាម នូវរាល់នីតិវិធីរបស់រដ្ឋបាលស្រុកដែលចេញដោយក្រសួងមហាផ្ទៃ។

ក្រុមប្រឹក្សាស្រុក-ក្រុង និងគណៈអភិបាលស្រុក-ក្រុងត្រូវមាននាយករដ្ឋបាលមួយរូប ហៅថានាយករដ្ឋបាលសាលាស្រុក-ក្រុង។ នាយករដ្ឋបាលសាលាស្រុក-ក្រុងត្រូវមាននាយករងរដ្ឋបាលសាលាស្រុក-ក្រុងយ៉ាងច្រើនពីររូបជាជំនួយការ។

ជាជំនួយការដល់ក្រុមប្រឹក្សាស្រុក-ក្រុង គណៈអភិបាលស្រុក ក្រុង និងអភិបាលស្រុក-ក្រុងក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងការធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាស្រុក-ក្រុង។ ក្នុងការអនុវត្តតួនាទីនេះ នាយករដ្ឋបាលសាលាស្រុក ក្រុងត្រូវ ៖

- ធ្វើរបាយការណ៍ និងត្រូវមានគណនេយ្យភាពចំពោះគណៈអភិបាលស្រុក-ក្រុង អភិបាលស្រុក-ក្រុង និងក្រុមប្រឹក្សាស្រុក ក្រុងរបស់ខ្លួន
- រៀបចំ និងដាក់ជូនគណៈអភិបាលស្រុក-ក្រុងពិនិត្យ សម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាស្រុក-ក្រុង ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់គណៈអភិបាលស្រុក-ក្រុង ហើយត្រូវធានាថា កិច្ចការទាំងនោះត្រូវបានរៀបចំឡើងស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងទម្រង់បែបបទនៃលិខិតស្នាមរដ្ឋបាល
- រៀបចំ និងដាក់ជូនគណៈអភិបាលស្រុក-ក្រុងនូវវិធានការ និងគោលការណ៍ក្នុងការអនុវត្តដីកា និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុក-ក្រុង
- ធ្វើជាសេនាធិការជូនអភិបាលស្រុក-ក្រុង និងប្រធានក្រុមប្រឹក្សាស្រុក-ក្រុង ក្នុងការត្រៀមរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្រុក-ក្រុង រួមទាំងការសម្របសម្រួលក្នុងការរៀបចំឯកសារ និងខ្លឹមសារសម្រាប់របៀបវារៈនីមួយៗនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្រុក-ក្រុង ស្របតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សារបស់ខ្លួន។ សេចក្តីព្រាងរបៀបវារៈ ឯកសារ និងខ្លឹមសារទាំងអស់ ដែលនាយករដ្ឋបាលសាលាស្រុក-ក្រុងបានរៀបចំ សម្រាប់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាស្រុក-ក្រុង ត្រូវដាក់ជូនគណៈអភិបាលស្រុក-ក្រុង ដើម្បី ពិនិត្យ និងផ្តល់យោបល់ជាមុន លើកលែងតែមានការកំណត់ផ្សេងដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

- ធ្វើជាសេនាធិការជូនក្រុមប្រឹក្សាស្រុក-ក្រុងក្នុងការរៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំ និងកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្រុក-ក្រុង
- ត្រៀមរៀបចំកិច្ចការនានា សម្រាប់បម្រើឱ្យកិច្ចប្រជុំទាំងអស់របស់គណៈអភិបាលស្រុក-ក្រុង តាមការណែនាំរបស់អភិបាលស្រុក-ក្រុង
- ធានាក្នុងការទទួល និងបែងចែកលិខិតស្នាម ឯកសារនានាឱ្យបានត្រឹមត្រូវដល់សមាជិកក្រុមប្រឹក្សាស្រុក-ក្រុង អភិបាលស្រុក-ក្រុង និងអភិបាលរងស្រុក-ក្រុង ព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ការិយាល័យ និងអ្នកពាក់ព័ន្ធនានា
- គ្រប់គ្រង និងប្រើប្រាស់ត្រារដ្ឋបាលស្រុក-ក្រុងឱ្យបានត្រឹមត្រូវតាមការកំណត់

➢ ធានារក្សាទុកដាក់ឱ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារ លិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សាស្រុក-ក្រុង និងគណៈអភិបាលស្រុក-ក្រុង និងរដ្ឋបាលរបស់ខ្លួន

➢ បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សាស្រុក-ក្រុង គណៈអភិបាលស្រុក-ក្រុង អភិបាលស្រុក-ក្រុង ឬដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

➢ មានសិទ្ធិចូលរួម និងបញ្ចេញយោបល់ក្នុងគ្រប់កិច្ចប្រជុំក្រុមប្រឹក្សាស្រុក-ក្រុង កិច្ចប្រជុំគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាស្រុក-ក្រុង និងក្នុងកិច្ចប្រជុំគណៈអភិបាលស្រុក-ក្រុង ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ លើកលែងតែនាយករដ្ឋបាលសាលាស្រុក-ក្រុងជាសមាជិកគណកម្មាធិការ ឬអនុគណៈកម្មាធិការ ឬ ក្រុមការងារណាមួយនោះ

➢ ក្នុងការចូលរួមក្នុងកិច្ចប្រជុំ និងការអនុវត្តការងារប្រចាំថ្ងៃ នាយករដ្ឋបាលសាលាស្រុក-ក្រុងអាចផ្តល់យោបល់ដល់ក្រុមប្រឹក្សាស្រុក-ក្រុង គណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាស្រុក-ក្រុង និងគណៈអភិបាលស្រុក-ក្រុងរបស់ខ្លួន អំពីបញ្ហាច្បាប់ និងបច្ចេកទេស ដើម្បីធានាថាសេចក្តីសម្រេច និងសកម្មភាពនានារបស់ក្រុមប្រឹក្សាស្រុក-ក្រុង គណៈអភិបាលស្រុក-ក្រុង និងអភិបាលស្រុក-ក្រុងមានលក្ខណៈសមស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបទដ្ឋានជាតិ សម្រាប់សុវត្ថិភាព និងគុណភាពដែលបានកំណត់ ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងសាលាស្រុក-ក្រុង

➢ ត្រូវធានាឱ្យការិយាល័យ មន្ត្រី បុគ្គលិកទាំងអស់អនុវត្តការងារបានត្រឹមត្រូវទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីនានា និងតាមការសម្រេចរបស់ក្រុមប្រឹក្សាស្រុក-ក្រុង និងគណៈអភិបាលស្រុក-ក្រុងរបស់ខ្លួន។

➢ គណៈអភិបាលស្រុក-ក្រុង និងអភិបាលស្រុក-ក្រុង អាចធ្វើប្រតិភូកម្មដល់ នាយករដ្ឋបាលសាលាស្រុក-ក្រុង ឱ្យលើកយោបល់លើកិច្ចការណាមួយ ដែលស្ថិតក្នុងវិសាលភាពនៃតួនាទីភារកិច្ចរបស់ខ្លួន ដើម្បីគណៈអភិបាលស្រុក-ក្រុង ឬអភិបាលស្រុក-ក្រុង ពិនិត្យ សម្រេចតាមការចាំបាច់។

### ២.២.១. ក្រុមប្រឹក្សា និងគណៈអភិបាល

#### ក. ក្រុមប្រឹក្សា

ក្រុមប្រឹក្សាក្រុង ស្រុក ដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[22] ជាគោលការណ៍ច្បាប់, រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើស

[22] អនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក, លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩

រើសឡើង តាមការបោះឆ្នោតអសកលស្របតាមនីតិវិធីដែលកំណត់ ដោយច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅកាត់ថា « ក្រុមប្រឹក្សា »។

ក្រុមប្រឹក្សាមានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មី ចូលកាន់តំណែងហើយអាណត្តិនោះត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់។ ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ដោយប្រធានគឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេ នៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេនៅក្នុងក្រុមប្រឹក្សា។ ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជន ដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិច១២០ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា។ ក្នុងករណីគ្មានអនុក្រឹត្យចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុបចុងក្រោយ នៃក្រុមប្រឹក្សាអាណត្តិចាស់។

ក្រុមប្រឹក្សានីមួយៗ ត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមជាប្រជាពលរដ្ឋទាំងអស់ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សានីមួយៗ ត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានាដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើតការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។[23]

### ខ. សិទ្ធិអំណាចក្រុមប្រឹក្សា

ក្រុមប្រឹក្សា អាចប្រើប្រាស់សិទ្ធិអំណាចប្រតិបត្តិរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេច នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា។ រៀងរាល់កិច្ចប្រជុំរបស់ខ្លួនក្រុមប្រឹក្សាត្រូវធ្វើសេចក្តីសម្រេច ឬដីកាតាមការចាំបាច់ទាក់ទិនទៅនឹងមុខងារសំខាន់ៗដូចខាងក្រោម៖

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្របតាមច្បាប់នេះ
- មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា
- មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា

[23] ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ.លេខ នស/រកម/០៥០៨/០១៧ ២៤ ឧសភា ២០០៨,មាត្រា១៤

- កម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ (៥)ឆ្នាំ រួមទាំងសមាសភាពនៃផែនការនោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា
- គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយចំណាយរយៈពេលមធ្យម
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀត
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាពនិងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុម ប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ
- កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដែលបានធ្វើឡើងស្របតាមច្បាប់នេះ។

**គ. គណៈអភិបាល**

គណៈអភិបាលរួមមាន ប្រធានមួយរូប ដែលហៅថា អភិបាល និងអភិបាលរងមួយចំនួន។អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវធ្វើការជ្រើសរើសពីក្នុង ចំណោមមន្ត្រីទាំងពីរភេទដែលស្ថិត ក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម ៖

មានឋានន្តរសក្តិចាប់ពីអនុមន្ត្រីឡើងមានអាយុ ចាប់ពីសាមសិប(៣០)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈ យ៉ាងតិចចំនួនប្រាំ (០៥) ឆ្នាំ ឬនិងមានសញ្ញាបត្របរិញ្ញាបត្រ ដែលទទួលស្គាល់ ដោយក្រសួងអប់រំយុវជន និងកីឡាមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ។[24] អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវធ្វើការជ្រើសរើសក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានឋានន្តរសក្តិចាប់ពីនាយក្រមការឡើង
- មានអាយុចាប់ពីម្ភៃប្រាំ(២៥) ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

[24]ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ , លេខនស/ រកម/០៥០៨/០១៧ចុះថ្ងៃទី២២ ឧសភា ឆ្នាំ២០០៨,មាត្រា១៤៤

- មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនបី(០៣)ឆ្នាំ ឬ និងមានសញ្ញាបត្របរិញ្ញាបត្ររងដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជននិងកីឡា
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ។[25]

អភិបាល មានតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីណែនាំ សម្របសម្រួល តម្រង់ទិសមន្ទីរ អង្គភាព ខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានារបស់និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ អភិបាល ត្រូវធ្វើតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការងារ សន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្សក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ត្រូវមានគណនេយ្យភាព ចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចស្នើរាជរដ្ឋាភិបាលចេញអនុក្រឹត្យដើម្បី កំណត់តួនាទី សិទ្ធិអំណាចរបស់អភិបាលក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា តាមការចាំបាច់។[26]

គណៈអភិបាល ត្រូវផ្តល់យោបល់ជូនក្រុមប្រឹក្សា រាយការណ៍ជូនក្រុមប្រឹក្សា និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ គណៈអភិបាល ត្រូវជួយក្រុមប្រឹក្សា ដើម្បីឱ្យក្រុមប្រឹក្សាសម្រេចបាននូវការអនុវត្ត។[27]

**ឃ. សិទ្ធិអំណាច និងភារកិច្ចរបស់គណៈអភិបាល**

គណៈអភិបាល ត្រូវជួយក្រុមប្រឹក្សាក្នុងការពិនិត្យមើលមុខងារ ភារកិច្ច និងធនធានទាំងអស់ ដែលបានបែងចែក ឬ បានផ្ទេរទៅឱ្យ រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយច្បាប់នេះ ឬ ដែលស្របតាមច្បាប់នេះរួចហើយត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សា អំពីរបៀបបំពេញមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ[28]។ ក្រុមប្រឹក្សាត្រូវត្រួតពិនិត្យសកម្មភាព និងការអនុវត្តរបស់គណៈអភិបាល និងអភិបាល។ ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចកោះអញ្ជើញគណៈអភិបាល ឬ អភិបាល និងបុគ្គលដែលពាក់ព័ន្ធមកសាកសួរបំភ្លឺក្នុងកិច្ចប្រជុំសាមញ្ញ ឬ វិសាមញ្ញរបស់ក្រុមប្រឹក្សា។

គណៈអភិបាល ឬ អភិបាលដែលបានសម្រេច ឬ បានអនុវត្តកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សា ការសម្រេច ឬ សកម្មភាពនោះ ពុំមានសុពលភាព

[25] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ , លេខនស/ រកម/០៥០៨/០១៧ចុះថ្ងៃទី២២ ឧសភា ឆ្នាំ២០០៨, មត្រា១៤៥
[26] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ , លេខនស/ រកម/០៥០៨/០១៧ចុះថ្ងៃទី២២ ឧសភា ឆ្នាំ២០០៨, មាត្រា១៥៤
[27] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ , លេខនស/ រកម/០៥០៨/០១៧ចុះថ្ងៃទី២២ ឧសភា ឆ្នាំ២០០៨,មាត្រា ១៥៥
[28] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ , លេខនស/ រកម/០៥០៨/០១៧ចុះថ្ងៃទី២២ ឧសភា ឆ្នាំ២០០៨, មាត្រា១៥៦

បានឡើយ។ [29]គណៈអភិបាល ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាអំពីការអនុវត្តសេចក្ដីសម្រេចរបស់ ក្រុមប្រឹក្សា និងសកម្មភាពដែលបានអនុវត្តដោយគណៈអភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ក្នុងចន្លោះអង្គប្រជុំសាមញ្ញមួយទៅអង្គប្រជុំសាមញ្ញមួយទៀតរបស់ក្រុមប្រឹក្សា។[30] គណៈអភិបាលត្រូវផ្ដល់យោបល់ និងរាយការណ៍ជូនក្រុមប្រឹក្សាពីការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានរបស់ក្រុមប្រឹក្សា។ គណៈអភិបាល ក្នុងនាមក្រុមប្រឹក្សា ត្រូវមានវិធានការដើម្បីធានាឱ្យ មន្ត្រី អង្គភាពនិងបុគ្គលិករបស់ក្រុមប្រឹក្សាបំពេញតួនាទី ភារកិច្ចរបស់ខ្លួន និងបំពេញការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា ព្រមទាំងអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាប្រកបដោយប្រសិទ្ធភាព។គណៈអភិបាលត្រូវផ្ដល់អនុសាសន៍ និងដាក់ជូនក្រុមប្រឹក្សា ដើម្បីពិភាក្សាសម្រេចអំពី៖

- ការបង្កើត ឬ រំសាយអង្គភាព
- ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក
- ការតែងតាំង ការដំឡើងឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិក ដោយផ្អែកតាមបទប្បញ្ញត្តិនៃការគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើសការតែងតាំង ការកំណត់ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗទៀតនៃបុគ្គលិករបស់ក្រុមប្រឹក្សា
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុ សម្រាប់អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករបស់ខ្លួន។[31]

### ង. ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក

អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាស្រុកបានសម្រេចរួចហើយ គណៈអភិបាលស្រុកត្រូវទទួលខុសត្រូវ ចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សាស្រុករបស់ខ្លួន។ ដូច្នេះគណៈអភិបាលស្រុក គឺជាអ្នកអនុវត្តទាំងសេចក្ដីសម្រេចខាងបញ្ញត្តិ និងសេចក្ដីសម្រេចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សាស្រុក៖[32]

- ក្រុមប្រឹក្សាស្រុក ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលស្រុក ដើម្បីធានាថាគណៈអភិបាលស្រុកអនុវត្តកិច្ចការទាំងនោះ បានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋាន

[29] ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ , លេខនស/ រកម/០៥០៨/០១៧ចុះថ្ងៃទី២២ ឧសភា ឆ្នាំ២០០៨,មាត្រា១៥៩

[30] ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ , លេខនស/ រកម/០៥០៨/០១៧ចុះថ្ងៃទី២២ ឧសភា ឆ្នាំ២០០៨,មាត្រា១៦០

[31] ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ , លេខនស/ រកម/០៥០៨/០១៧ចុះថ្ងៃទី២២ ឧសភា ឆ្នាំ២០០៨ ,មាត្រា១៦២

[32] សៀវភៅណែនាំស្ដីពី តួនាទី និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក ឆ្នាំ២០១០

គតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សាស្រុក

- គណៈអភិបាលស្រុក ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាស្រុករបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សាស្រុក
- គណៈអភិបាលស្រុក ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាស្រុករបស់ខ្លួន អំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុក និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល អំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា
- អភិបាលស្រុក ដោយមាននាយករដ្ឋបាលសាលាស្រុកជាជំនួយការ ត្រូវរៀបចំសេចក្តីរាយការណ៍អំពីសកម្មភាព និងលទ្ធផលនៃការអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័ននានា ព្រមទាំងស្ថានភាពនៃការងារទាំងនោះក្នុងរបាយការណ៍ប្រចាំខែ ត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាស្រុករបស់ខ្លួន
- ក្នុងករណីមានបញ្ហាណាមួយដែលពាក់ព័ន្ធដល់ការអនុវត្តតួនាទីរបស់អភិបាលស្រុកក្នុងនាមជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬមានការទាមទារតវ៉ាពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាស្រុកអាចតម្រូវឱ្យអភិបាលស្រុកធ្វើសេចក្តីរាយការណ៍ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សាស្រុក
- ក្រុមប្រឹក្សាស្រុកអាចផ្តល់អនុសាសន៍ និងការណែនាំដល់អភិបាលស្រុក អំពីការអនុវត្តតួនាទីខាងលើនេះ ដើម្បីឆ្លើយតបតម្រូវការជាអាទិភាព និងបញ្ហាប្រឈមនានារបស់មូលដ្ឋាន។ អភិបាលស្រុកត្រូវទទួលយកអនុសាសន៍ និងការណែនាំពីក្រុមប្រឹក្សាស្រុករបស់ខ្លួន ដើម្បីធ្វើការណែនាំ សម្របសម្រួល និងតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំនៅស្រុកក្នុងការឆ្លើយតបតម្រូវការទាំងនោះ ហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សាស្រុករបស់ខ្លួនវិញ។

ក្រៅពីទំនាក់ទំនងនានាដូចបានរៀបរាប់ខាងលើ ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក ក៏បានកំណត់ក្នុងតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុកផងដែរ។[33]

### ២.២.២. ការគាំទ្រនិងទំនាក់ទំនងរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ជាមួយក្រសួង ស្ថាប័ន

ក្រុមប្រឹក្សាខេត្ត ខេត្តក្រុមប្រឹក្សាក្រុងក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាសង្កាត់ មានសិទ្ធិអំណាចនៃរាងរាងខ្លួនក្នុងការធ្វើសេចក្តីសម្រេចនិងចាត់ចែងមុខងារភារកិច្ច និងធនធាននានាដែលបានប្រគល់ឬបានធ្វើប្រតិភូកម្ម

[33] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក.លេខ ២១៥ អនក្រ.បក,មាត្រា

ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ក្រុង ស្រុក ខាល លើសច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងធានាធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្នុងដែនសមត្ថកិច្ចរាងរាងខ្លួន គណៈអភិបាលខេត្ត គណៈអភិបាលក្រុង អភិបាលស្រុក មេឃុំ ចៅសង្កាត់មានភារកិច្ចអនុវត្តកិច្ចការប្រចាំថ្ងៃ ក្នុងការទំនាក់ទំនងទៅវិញទៅមករវាងខេត្ត ក្រុង ស្រុក ឃុំនិងសង្កាត់ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។[34]

ដើម្បីធានាឱ្យក្រុមប្រឹក្សក្រុងលើកកម្ពស់ក្នុងការបង្កើត ការជំរុញនិងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្រុមប្រឹក្សាសង្កាត់ក្នុងក្រុងត្រូវទទួលខុសត្រូវដូចជា៖

- ក្នុងការផ្តល់យោបល់និង ពាក្យគ្រោះយោបល់ ជាមួយក្រុមប្រឹក្សាក្រុង ដើម្បីធានា ក្រុមប្រឹក្សាក្រុមនៅតែឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់ដែលមានក្នុងដែនសមត្ថកិច្ច ក្រុងនិងតាមសង្កាត់នីមួយៗក្នុងក្រុង
- ផ្តលអនុសាសន៍ដល់ក្រុមប្រឹក្សាក្រុង អំពីតម្រូវការនានារបស់ប្រជាពលរដ្ឋ ផ្លែក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបានដោយសមត្ថភាពនិងធនធានដែលខ្លួនមាន
- អនុវត្តមុខងារភារកិច្ចទាំងឡាយដែលបានធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាក្រុង។[35]

ក្រុមប្រឹក្សាក្រុងត្រូវរៀបចំឱ្យមានការពិគ្រោះយោបល់សមស្របជាមួយក្រុមប្រឹក្សាសង្កាត់ក្នុងក្រុងដើម្បី៖

- ✓ ធ្វើការសម្របសម្រួលឱ្យមានកិច្ចសហប្រតិបត្តិការ ក្នុងចំណោមសង្កាត់នានាក្នុងក្រុងដើម្បីលើកកម្ពស់ការឆ្លើយតប តម្រូវការរបស់ប្រជាពលរដ្ឋ
- ✓ ប្រមូលផ្តុំសេចក្តីត្រូវការនានារបស់ប្រជាពលរដ្ឋ ដែលលើកឡើងដោយក្រុមប្រឹក្សាសង្កាត់ ហើយដែលក្រុមប្រឹក្សាសង្កាត់មិនអាចឆ្លើយតបបានដើម្បីពិគ្រោះ ពិភាសាជាមួយក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធនឹងខិតខំឆ្លើយតបតម្រូវការទាំងអស់
- ✓ គាំទ្រសមត្ថភាពចាំបាច់ដល់ក្រុមប្រឹក្សាសង្កាត់ដើម្បីក្រុមប្រឹក្សាសង្កាត់ក្នុងក្រុងមានសមត្ថភាពទទួលបាននូវមុខងារភារកិច្ចដែលត្រូវធ្វើប្រតិភូកម្ម កាន់តែច្រើនថែមទៀតពីក្រុមប្រឹក្សាក្រុង។[36]

---

[34] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក.លេខ ២១៥ អនក្រ.បក,មាត្រា១៧៤

[35] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក.លេខ ២១៥ អនក្រ.បក,មាត្រា១៧៩

[36] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក.លេខ ២១៥ អនក្រ.បក,មាត្រា១៨០

ក្រុមប្រឹក្សាស្រុកត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងស្រុក អំពីជម្រើសសេចក្តីសម្រេចនិងការអនុវត្តរបស់ខ្លួនព្រមទាំងផលប៉ះពាល់នៃចំរើនសេចកីសម្រេចនិងការអនុវត្តសេចក្តីសម្រេចទាំងនោះ។

ផ្អែកលើគោលការណ៍ខាងលើនេះក្រុមប្រឹក្សាស្រុកទៅរៀបចំទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការឱ្យបានសមស្របជាមួយក្រុមប្រឹក្សាឃុំក្រុមប្រឹក្សាសង្កាត់ក្នុងស្រុករបស់ខ្លួន ស្របតាមបញ្ញត្តិនៃអនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក។

ក្រុមប្រឹក្សាខេត្តត្រូវសហការជាមួយនឹងក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុកក្នុងខេត្តរបស់ខ្លួនដើម្បីពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំនិងក្រុមប្រឹក្សាសង្កាត់ក្នុងខេត្តរបស់ខ្លួនក្នុងគោលបំណងឆ្លើយតបតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាឃុំមនុស្សក្រុមប្រឹក្សាសង្កាត់។

ក្នុងទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការខាងលើនេះ ក្រុមប្រឹក្សាឃុំនិងក្រុមប្រឹក្សាសង្កាត់ក្នុងខៃត្រូវទទួលខុសត្រូវះ

- ផ្តល់យោបល់ ពិគ្រោះយោបល់និងត្រួតពិនិត្យដើម្បីធានាថាក្រុមប្រឹក្សាខេត្តក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាក្រុងនៅតែឆ្លើយតបទៅនឹងសេចក្តីត្រូវការ របស់ប្រជាពលរដ្ឋដែលមូលដ្ឋាននិងគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងខេត្ត។
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុងក្រុមប្រឹក្សាស្រុកអំពី តម្រូវការនានារបស់ប្រជាពលរដ្ឋនិងក្រុមប្រឹក្សាឃុំនិងក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបានដោយសមត្ថភាព និងធនធានដែលខ្លួនមាន។
- ធ្វើសហប្រតិបត្តិការអត់បានបងពេញលេញជាមួយក្រុមប្រឹក្សាខេត្តក្រុមប្រឹក្សា ក្រុងនិងក្រុមប្រឹក្សាស្រុកក្នុងករណី លើកកម្ពស់ ការផ្តល់សេវានិងអភិវឌ្ឍនៅមូលដ្ឋាន។[37]

### ២.២.៣.គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាស្រុក និងនាយករដ្ឋបាលសាលាស្រុក

ក្រុមប្រឹក្សាស្រុកមានកាតព្វកិច្ចបង្កើតគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបីគឺៈ

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

[37] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក.លេខ ២១៥ អនក្រ.បក,មាត្រា១៨៥

➢ គណៈកម្មាធិការលទ្ធកម្ម

ក្រៅពីគណៈកម្មាធិការជាកាតព្វកិច្ចទាំងបីខាងលើនេះ ក្រុមប្រឹក្សាស្រុកអាចបង្កើតគណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់។ គណៈកម្មាធិការដែលបង្កើតបន្ថែមនេះមិនត្រូវមានតួនាទី និងភារកិច្ចត្រួតគ្នាជាមួយនឹងតួនាទី ភារកិច្ចរបស់គណៈកម្មាធិការជាកាតព្វកិច្ចទាំងបីខាងលើឡើយ។ ជាមួយគ្នានេះដែរ ក្រុមប្រឹក្សាស្រុកអាចបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារផ្សេងៗទៀតតាមការស្នើសុំរបស់គណៈកម្មាធិការនានា ឬគណៈអភិបាលស្រុក។ អនុគណៈកម្មាធិការ ឬក្រុមការងារខាងលើនេះ ត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការ ឬគណៈអភិបាលស្រុក។[38]

ការរៀបចំបង្កើតគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាស្រុកត្រូវពិនិត្យ ពិចារណាលើចំណុចមួយចំនួន ដូចខាងក្រោមៈ

➢ ក្រុមប្រឹក្សាស្រុកអាចតែងតាំងសមាជិកក្រុមប្រឹក្សាស្រុក អភិបាលស្រុក អភិបាលរងស្រុក តំណាងក្រុមប្រឹក្សាឃុំ តំណាងក្រុមប្រឹក្សាសង្កាត់ បុគ្គលិករបស់ក្រុមប្រឹក្សាស្រុក តំណាងសហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់ សម្រាប់ជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង

➢ ក្រុមប្រឹក្សាស្រុកត្រូវសម្រេចពីចំនួនសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ការតែងតាំង ប្រធាន អនុប្រធាន និងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាដែលខ្លួនបានបង្កើត

➢ គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ត្រូវមានតំណាងស្ត្រីសមស្រប រួមទាំងតំណែងប្រធាន ឬអនុប្រធានគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារផង

➢ ក្រុមប្រឹក្សាស្រុកអាចរំសាយគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើងតាមការចាំបាច់ ឬតាមសំណើរបស់គណៈកម្មាធិការ ឬគណៈអភិបាលស្រុក

➢ គណៈអភិបាលស្រុកអាចស្នើសុំក្រុមប្រឹក្សាស្រុក ដើម្បីឱ្យគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយដែលក្រុមប្រឹក្សាស្រុកបានបង្កើតឡើង រួមទាំងគណៈកម្មាធិការជាកាតព្វកិច្ចទាំងបីខាងលើជួយសិក្សាផ្តល់យោបល់លើបញ្ហាណាមួយ ឬមួយចំនួនដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈ

[38] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក.លេខ ២១៥ អនក្រ.បក,មាត្រា១៣៦

អភិបាលស្រុក

- ក្រុមប្រឹក្សាស្រុកត្រូវទទួលខុសត្រូវរាល់ការសម្រេច និងសកម្មភាពរបស់គណៈកម្មាធិការនានា និងទទួលខុសត្រូវចំពោះផលវិបាកនានាដែលកើតចេញពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ
- ក្រុមប្រឹក្សាស្រុក ត្រូវណែនាំឱ្យគណៈអភិបាលស្រុកផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន ការគាំទ្រផ្នែកច្បាប់ និងបច្ចេកទេស ព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការជាកាតព្វកិច្ចទាំងបី ឬដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលក្រុមប្រឹក្សាស្រុកបានបង្កើតឡើង
- គណៈកម្មាធិការដែលបានបង្កើតឡើង ត្រូវមានសេចក្តីរាយការណ៍ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ និងតាមតម្រូវការចាំបាច់នានា។ សេចក្តីរាយការណ៍នេះ ត្រូវចម្លងជូនគណៈអភិបាលស្រុក ដើម្បីបូកសរុប និងរាយការណ៍ជូនក្រុមប្រឹក្សាស្រុក
- ក្រុមប្រឹក្សាស្រុក អាចតម្រូវឱ្យគណៈកម្មាធិការណាមួយរាយការណ៍ដោយផ្ទាល់អំពីកិច្ចការពិសេស និងបន្ទាន់ណាមួយ ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុកតាមការចាំបាច់។[39]

### ២.២.៤. ការិយាល័យទាំង១៣ក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុក

នៅក្នុងរចនាសម្ព័ន្ធថ្មីរដ្ឋបាលស្រុកត្រូវបានរៀបចំឱ្យមាន ១៣ការិយាល័យរួមមាន៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- ការិយាល័យគ្រប់គ្រងធនធានមនុស្ស
- ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង
- ការិយាល័យ អប់រំយុវជន និងកីឡា
- ការិយាល័យ រៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល
- ការិយាល័យ លេខាធិការក្រុមប្រឹក្សា
- ការិយាល័យ នីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
- ការិយាល័យ កសិកម្មធនធានធម្មជាតិ និងបរិស្ថាន
- ការិយាល័យ សេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
- ការិយាល័យ សង្គមកិច្ច និងសុខុមាលភាពសង្គម
- ការិយាល័យ ច្រកចេញចូលតែមួយ

[39] សៀវភៅណែនាំស្តីពី តួនាទី និងភារៈកិច្ច និងរបៀបរបបគ្រប់គ្រងរបស់រដ្ឋបាលស្រុក(ទំព័ ២៧)

- អង្គភាពលទ្ធកម្ម
- ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់[40]

ការិយាល័យនីមួយៗ ត្រូវដឹកនាំដោយប្រធានការិយាល័យមួយរូប និងមានអនុប្រធានការិយាល័យមួយរូបជាជំនួយការ។ ប្រធានការិយាល័យនីមួយៗ ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាលសាលាស្រុក-ក្រុង។ រដ្ឋបាលនីមួយៗត្រូវមានាការិយាល័យ និង អង្គភាពមួយចំនួនជាចំណុះ ។ ហើយការិយាល័យ និងអង្គភាពចំណុះទាំងនោះមានតួនាទី និង ភារកិច្ចដូចខាងក្រោម៖

❖ **ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ**

ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃសាលាស្រុក-ក្រុង គឺជាសេនាធិការឱ្យក្រុមប្រឹក្សាស្រុក-ក្រុង និងគណៈអភិបាលស្រុក-ក្រុងលើកិច្ចការសំខាន់ៗដូចខាងក្រោម ៖

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ទំនាក់ទំនងសាធារណៈ និងការងារពិធីការ
- គ្រប់គ្រង និងថែរក្សាត្រារដ្ឋបាលស្រុក-ក្រុង តាមការកំណត់
- ការងារស្ថិតិប្រជាពលរដ្ឋ និងការងារអត្រានុកូលដ្ឋាន
- ការងារបុគ្គលិក ក្របខ័ណ្ឌ បៀវត្ស និងកម្រៃផ្សេងៗរបស់មន្ត្រី បុគ្គលិកសាលាស្រុក-ក្រុង
- សហការរៀបចំនីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងល័ក្ខខ័ណ្ឌការងាររបស់មន្ត្រី បុគ្គលិកសាលាស្រុក-ក្រុង
- ការបណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រី បុគ្គលិកសាលាស្រុក-ក្រុង
- សិក្សា និងលើកយោបល់លើការបង្កើត ការកែសម្រួល និងការរំសាយការិយាល័យចំណុះសាលាស្រុក-ក្រុង
- រៀបចំសេចក្តីព្រាងរបៀបវារៈ ខ្លឹមសារសម្រាប់របៀបវារៈនីមួយៗ និងឯកសារនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក-ក្រុង និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាស្រុក-ក្រុង
- រៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំ និងកំណត់ហេតុគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក-ក្រុង គណៈអភិបាលស្រុក-ក្រុង និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាស្រុក-ក្រុង

[40] អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥

- ទទួល និងបែងចែកលិខិតស្នាម ឯកសារនានាឱ្យបានត្រឹមត្រូវដល់សមាជិកក្រុមប្រឹក្សាស្រុក-ក្រុង អភិបាលស្រុក-ក្រុង និងអភិបាលរងស្រុក-ក្រុង ព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ការិយាល័យជំនាញ និងអ្នកពាក់ព័ន្ធ
- រក្សាទុកដាក់ឱ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារ លិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សាស្រុក-ក្រុង គណៈអភិបាលស្រុក-ក្រុង និងរដ្ឋបាលស្រុក-ក្រុង
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- រៀបចំ និងបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានា ជូនប្រជាពលរដ្ឋនៅក្នុងស្រុក-ក្រុងរបស់ខ្លួន
- សហការក្នុងការត្រៀមរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ តាមសាលាឃុំ និងសង្កាត់នានាក្នុងស្រុក-ក្រុង
- សិក្សា និងលើកយោបល់ទាក់ទងនឹងការពិនិត្យនីត្យានុកូលភាព នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ និងសង្កាត់នានាក្នុងស្រុក-ក្រុង
- ការងារហិរញ្ញវត្ថុ ថវិកា និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលស្រុក-ក្រុង
- គ្រប់គ្រងបេឡារបស់សាលាស្រុក-ក្រុង
- សហការត្រួតពិនិត្យ និងទូទាត់រាល់ការចំណាយ
- ការងារលទ្ធកម្ម សវនកម្ម និងរបាយការណ៍ហិរញ្ញវត្ថុរបស់ស្រុក-ក្រុង។[41]

### ❖ ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់

ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់នៃសាលាស្រុក-ក្រុង គឺជាសេនាធិការឱ្យក្រុមប្រឹក្សាស្រុក-ក្រុង និងគណៈអភិបាលស្រុក-ក្រុង លើកិច្ចការសំខាន់ៗ ដូចខាងក្រោម ៖

- សិក្សា និងរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ស្រុក-ក្រុង រួមទាំងសមាសភាគនៃផែនការ ដែលស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន មន្ទីរ ឬការិយាល័យ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ

[41] អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥,មាត្រា១៥

- អនុវត្តគម្រោង កម្មវិធីអភិវឌ្ឍ សម្របសម្រួលកិច្ចសហប្រតិបត្តិ ការអភិវឌ្ឍ និងការផ្តល់សេវារវាងឃុំ សង្កាត់នានាក្នុងស្រុក-ក្រុង
- ជួយដល់ក្រុមប្រឹក្សាឃុំ និងសង្កាត់ដើម្បីវិភាគវាយតម្លៃដំណើរការអភិវឌ្ឍរបស់ឃុំ និងសង្កាត់ក្នុងស្រុក-ក្រុង
- សហការគាំទ្រដល់ក្រុមប្រឹក្សាឃុំ និងសង្កាត់ ក្នុងការរៀបចំថវិកាឃុំ និងសង្កាត់ក្នុងស្រុក-ក្រុង
- សហការពិនិត្យ និងលើកអនុសាសន៍ជូនអភិបាលខេត្តអំពីការធ្វើអនុលោមភាពថវិកាឃុំ និងសង្កាត់
- សិក្សា វាយតម្លៃ និងលើកយោបល់អំពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ និងសង្កាត់ និងតម្រូវការគាំទ្រ
- ដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ និងសង្កាត់
- គាំទ្រដល់ក្រុមប្រឹក្សាឃុំ និងសង្កាត់ក្នុងការកសាង និងការអនុវត្តផែនការអភិវឌ្ឍរបស់ឃុំ និងសង្កាត់
- ទំនាក់ទំនង សហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធស្តីពីការកែសម្រួលទិន្នន័យ ផែនទី សេចក្តីត្រូវការជាអាទិភាពរបស់ស្រុក-ក្រុង ឃុំ និងសង្កាត់
- បញ្ចូល និងធ្វើបច្ចុប្បន្នភាពទិន្នន័យដែលពាក់ព័ន្ធស្រុក-ក្រុង ឃុំ និងសង្កាត់
- ពិនិត្យរបាយការណ៍អនុវត្តផែនការអភិវឌ្ឍន៍របស់ស្រុក-ក្រុង ឃុំ និងសង្កាត់
- កៀរគរធនធានសម្រាប់អភិវឌ្ឍស្រុក-ក្រុង និងគាំទ្រ ឃុំ និងសង្កាត់
- គាំទ្រឃុំ និងសង្កាត់ក្នុងស្រុក-ក្រុង ដើម្បីអាចទទួលបាននូវមុខងារ និងធនធានកាន់តែច្រើនឡើង
- ពិនិត្យមើលអំពីលក្ខខណ្ឌរបស់ឃុំ សង្កាត់ ដើម្បីទទួលបានមុខងារ និងធនធាន
- ពិនិត្យ និងវាយតម្លៃការប្រើប្រាស់មូលនិធិវិនិយោគស្រុក-ក្រុង ឃុំ និងសង្កាត់។[42]

❖ **អង្គភាពលទ្ធកម្ម**

អង្គភាពលទ្ធកម្ម របស់រដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ និងផែនការលទ្ធកម្មកែតម្រូវការ ក្នុងករណីចាំបាច់
- រៀបចំឯកសារ ផ្សារដេញថ្លៃសម្រាប់ប្រភេទលទ្ធកម្មនីមួយៗហើយតាមគំរូឯកសារដេញថ្លៃដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំនិងផ្សព្វផ្សាយសេចក្តីជូនដំណឹងអំពីកិច្ចលិតកម្មនីមួយៗ
- លក់ឬផ្តល់ឯកសារអើថ្លៃជូនអ្នកមានបំណងចូលរួមក្នុងកិច្ចលទ្ធកម្ម

[42] អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥,មាត្រា១៨

- ទទួលសំណើរដេញថ្លៃនឹងបកស្រាយបំភ្លឺចំពោះអ្នកដេញថ្លៃក្នុងករណីមានសំណួរពាក់ព័ន្ធនិងដេញថ្លៃ
- រៀបចំទុកដាក់សំណើ ដេញថ្លៃដែលបានទទួលឱ្យបានត្រឹមត្រូវ មានសុវត្ថិភាព ត្រូវគ្រប់គ្រងឯកសារឬលិខិតស្នាមពាក់ព័ន្ធទាំងអស់មុនពេលបើកសំណើរដេញថ្លៃ
- រៀបចំសំណើដេញថ្លៃជាសាធារណៈដោយមានការដឹកនាំត្រួតពិនិត្យពីគណៈកម្មការ ការពិការលទ្ធកម្មរបស់ រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- រៀបចំធ្វើរបាយការណ៍ ឬកំណត់ហេតុស្តីពីការបានសំណើរដេញថ្លៃ
- ជួយសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើរដេញថ្លៃ
- ឆ្លើយតបចំពោះសំណួរពាក់ព័ន្ធនឹងរបាយការណ៍វាយតម្លៃលើសំណើរដេញថ្លៃ
- ផ្ញើលិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យាទៅអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់
- ផ្ញើលិខិតជូនដំណឹងស្តីពីការប្រគល់សន្យាឯកសារកិច្ចសន្យាដែលបានកំណត់
- ផ្សព្វផ្សាយលទ្ធកម្មនៃការដេញថ្លៃជាសាធារណៈ ការអនុវត្តកិច្ចសន្យា ដោយសហការជាមួយមន្ត្រីបច្ចេកទេស និងមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀត
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស។[43]

❖ **ការិយាល័យគ្រប់គ្រងធនធានមនុស្ស**

ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកកកាងារគ្រប់គ្រង់ធនធានមនុស្ស និង មានភារកិច្ចចាត់ចែងលើការងារខាងក្រោម៖

- ការគ្រប់គ្រង់ការចាត់ចែង និង ការប្រើប្រាស់បុគ្គលិករដ្ឋបាលស្រុក
- ការបណ្តុះបណ្តាល និង ការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលស្រុក
- ការគ្រប់គ្រងបុគ្គលិកផ្សេងទៀតការផ្ទេរសិទ្ធិអំណាចពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។[44]

❖ **ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង**

ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការត្រួតពិនិត្យការបំពេញការងាររបស់ការិយាល័យ និង អង្គភាពនានាចំណុះរដ្ឋបាលស្រុក និង មានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

[43] អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥,មាត្រា១៦

[44] អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥,មាត្រា១៧

- ការត្រួតពិនត្យលើការអនុវត្តតាមច្បាប់ ដីកា លិខិតបទដ្ឋានគតិយុត្ត និង ស្តង់សេវានានាដែលបានកំណត់ជាធរមាន
- ត្រួតលើការងាររដ្ឋបាលការងារ បុគ្គលិកការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលស្រុក
- ការត្រួតពិនិត្យការអនុវត្តវិន័យបទបញ្ជាផ្ទៃក្នុងក្រមសីលធម៌ និងម៉ោងបំពេញការងាររបស់បុគ្គករដ្ឋបាលស្រុក
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក ។[45]

❖ **ការិយាល័យលេខាធិការក្រុមប្រឹក្សា**

ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារលេខាធិការដ្ឋានជូនក្រុមប្រឹក្សាស្រុក និង មានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំកិច្ចប្រជុំសាមញ្ញ និង វិសាមញ្ញរបស់ក្រុមប្រឹក្សា
- ការរៀបចំកំណត់ហេតុនៃកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា
- ការរៀបចំវេទិកាផ្សព្វផ្សាយ និង ពិគ្រោះយោបល់នានារបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រងការថែរក្សា និង ផ្សព្វផ្សាយនូវសេចក្តីសម្រេច និង ឯកសារនានាក្រុមប្រឹក្សា។[46]

❖ **ការិយាល័យអប់រំ យុវជន និង កីឡា**

ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការអប់រំ យុវជន និង កីឡា និង មានភារកិច្ចគ្រប់គ្រងគាំទ្រសម្របសម្រួល និង តាមដានត្រួតពិនិត្យវាយតម្លៃលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការអប់រំកុមារតូច
- ការអប់រំបឋមសិក្សា
- ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
- ការអប់រំក្រៅប្រព័ន្ធ
- ការអភិវឌ្ឍយុវជន
- ការអប់រំកាយនិងកីឡា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។[47]

[45] អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥,មាត្រា១៩
[46] អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥,មាត្រា២០
[47] អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥,មាត្រា២១

❖ **ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និង ភូមិបាល**

ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការរៀបចំដែនដី នគរបនីយកម្ម សំណង់ និង ភូមិបាលមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោមៈ

- ការងាររៀបចំដែនដី និង នគរូបនីកម្ម
- ការងារភូមិបាល
- ការងារសំណង់
- កាងារសំនៅឋាន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។[48]

❖ **ការិយាល័យនីតិកម្ម និង សម្រុះសម្រួលវិវាទមូលដ្ឋាន**

មានតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារនីតិកម្ម និង ការសម្រុះសម្រួលវិវាទមូលដ្ឋានក្រៅប្រពន្ធតុលាការ និង មានភារកិច្ចចាត់ចែងលើការមួយចំនួនដូចខាងក្រោមៈ

- ការសិក្សាស្រាវជ្រាវ ការរៀបចំ និង ការផ្តល់យោបល់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋបាលស្រុក
- ការផ្សព្វផ្សាយច្បាប់ និង លិខិតបទដ្ឋានគតិយុត្តនានាដល់មន្ត្រី បុគ្គលិក និង ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលស្រុក
- កាផ្តល់ប្រក្សាយោបល់ផ្លូវច្បាប់ដល់ប្រជាពលរដ្ឋ
- ការរៀបចំការបណ្តុះបណ្តាលជំនាញសម្រុះសម្រួល និង ច្បាប់ដល់រដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក
- កាទទួលពាក្យបណ្តឹង និង ការសម្រុះសម្រួលវិវាទនៅមូលដ្ឋានដែលស្ថិក្នុងដែលសមត្ថកិច្ចរបស់រដ្ឋបាលស្រុកស្របតាមកំណត់
- ការពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្តីសម្រេចនានារបស់រដ្ឋបាលឃុំ សង្កាត់ក្នុងស្រុកតាមគោលការណ៍កំណត់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។[49]

[48] អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥,មាត្រា២២

[49] អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥,មាត្រា២៣

❖ **ការិយាល័យរិយាល័យកសិកម្ម ធនធានធម្មជាតិ និង បរិស្ថាន**

មានទួនាទីធ្វើជាសេនាធិការឱ្យរដ្ឋបាលស្រុកបើការងារកសិកម្ម ធនធានធម្មាជាតិ និងបរិស្ថាន និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារកសិកម្មរុក្ខប្រម៉ាញ់និងនេសាទ
- ការងារធនធានទឹក
- ការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- ការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន
- ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។[50]

❖ **ការិយាល័យសេដកិច្ច និងអភិវឌ្ឍន៍សហគមន៍**

ត្រូវបំពេញទួនាទីជាសេនាធិកឱ្យរដ្ឋបាលស្រុកលើការអភិវឌ្ឍសេដ្ឋកិច្ច ការផ្ដល់សេវាសាធារណៈនិងការអភិវឌ្ឍសហគមន៍និងមានភារកិច្ចចាត់ចែងមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារសាថារណការ និងដឹកជញ្ជូន
- ការងារឧស្សាហកម្ម និងសិប្បកម្ម
- ការងាររ៉ែ និងថាមពល
- ការងារទេសចរណ៍
- ការងារអភិវឌ្ឍជនបទ
- ការងារពាណិជ្ជកម្ម
- ការងារប្រៃសណីយ៍ និងទូរគមនាគមន៍
- ការងារអភិវឌ្ឍសហគមន៍
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។[51]

❖ **ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម**

ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារសង្គមកិច្ច និងសុខុមាលភាពសង្គមនិងមាន

[50] អនុក្រឹត្យស្ដីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥,មាត្រា២៤
[51] អនុក្រឹត្យស្ដីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥,មាត្រា២៥

ភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ការងារសុខាភិបាល
- ការងារកិច្ចការនារី
- ការងារធម្មការ និងសាសនា
- ការងារ និងការបណ្តុះបណ្តាលវិជ្ជជីវៈ
- ការងារវប្បធម៌ និងវិចិត្រសិល្បៈ
- ការងារគ្រោះមហន្តរាយ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។[52]

❖ **ការិល័យច្រកចេញចូលតែមួយ**

ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារសង្គមកិច្ច និងសុខុមាលភាពសង្គមនិងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការទទួល និងការផ្តល់រដ្ឋបាលនានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលស្រុក
- ការប្រមូល និងការបង់កម្រៃសេវារដ្ឋបាលតាមគោលការណ៍ និងនីតិវិធីកំណត់
- ការផ្តល់ពត៌មាននានា និងការផ្សព្វផ្សាយជាសាធារណៈពាក់ណ័ន្ធ និងការផ្តល់សេវារដ្ឋបាលការទុកដាក់ ការថែរក្សា និងការគ្រប់គ្រងឯកសានានាពាក់ព័ន្ធនិងការផ្តល់សេវារដ្ឋបាល
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អធិបាលស្រុក។[53]

ក្រៅពីតួនាទី និងភារកិច្ចខាងលើនេះការិយាល័យនីមួយៗអាចទទួលភារកិច្ចជាអចិន្ត្រៃយ៍បន្ថែមទៀតតាមការចាំបាច់។ នាយករដ្ឋបាលត្រូវស្នើទៅគណៈអភិបាលស្រុក ដើម្បីសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន ក្នុងការប្រគល់ភារកិច្ចជាអចិន្ត្រៃយ៍បន្ថែមដល់ការិយាល័យណាមួយ។ ក្នុងការអនុវត្តកិច្ចការប្រចាំថ្ងៃ ករណីមានកិច្ចការថ្មីៗបន្ទាន់ ចាំបាច់ណាមួយ ដែលមិនបានកំណត់ជាតួនាទី និងភារកិច្ចរបស់ការិយាល័យជាក់លាក់ណាមួយ នាយករដ្ឋបាលត្រូវសុំយោបល់ជាបន្ទាន់ពីអភិបាលស្រុក ដើម្បីប្រគល់កិច្ចការនោះដល់ការិយាល័យជាក់លាក់ណាមួយ ឱ្យធ្វើការចាត់ចែងស្របតាមនីតិវិធី រួចហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សាស្រុក។ បន្ទាប់ពីអនុវត្ត ក្នុងករណីពិនិត្យឃើញថាកិច្ចការនោះ មានលក្ខណៈជាកិច្ចការអចិន្ត្រៃយ៍ នាយករដ្ឋបាលត្រូវស្នើទៅគណៈអភិបាល

---

[52] អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥,មាត្រា២៦

[53] អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥,មាត្រា២៧

ស្រុកដើម្បីសុំការសម្រេចពីក្រុមប្រឹក្សាស្រុក-ក្រុងរបស់ខ្លួន ក្នុងការប្រគល់ភារកិច្ច អចិន្ត្រៃយ៍បន្ថែមដល់ការិយាល័យណាមួយនោះ។

ក្រៅពីការិយាល័យខាងលើ គណៈអភិបាលស្រុក-ក្រុងអាចស្នើទៅក្រុមប្រឹក្សាស្រុក-ក្រុង ដើម្បីបង្កើត ឬកែសម្រួល ឬរំសាយការិយាល័យណាមួយ ឬមួយចំនួន តាមការចាំបាច់។ ក្នុងករណីមានតម្រូវការបង្កើតការិយាល័យបន្ថែម ការិយាល័យនោះមិនត្រូវមានតួនាទី និងភារកិច្ចត្រួតគ្នាជាមួយការិយាល័យទាំង១៣ខាងលើឡើយ។ ផ្អែកតាមការសម្រេចពីក្រុមប្រឹក្សាស្រុក-ក្រុងរបស់ខ្លួន អភិបាលស្រុក-ក្រុង ត្រូវលើកសំណើមកអភិបាលខេត្ត ដើម្បីស្នើសុំមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពិនិត្យ សម្រេចក្នុងការបង្កើត ឬការរំសាយ ឬការកែសម្រួលការិយាល័យខាងលើនេះ។

### ២.២.៥. របៀបរបបធ្វើការងាររបស់ការិយាល័យចំណុះសាលាស្រុក-ក្រុង

សាលាស្រុកត្រូវមានអង្គដឹកនាំ និងរបៀបរបបការងារជាក់លាក់មួយនៅក្នុងរដ្ឋបាល តាមបតប្បញ្ញាត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨។ ដើម្បីងាយស្រួលដំណើរការការងារ និងការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលឱ្យកាន់តែមានភាពងាយស្រួល និងឆាប់រហ័សជូនដល់ប្រជាពលរដ្ឋប្រើប្រាស់ក្នុងប្រការណាមួយ។ អាស្រ័យដូចនេះទើបបានជាបង្កើតឱ្យមាន របៀបរបបការងារនៃការិយាល័យ និងអង្គភាពចំណុះរដ្ឋបាលស្រុកដូចតទៅ។

- ការិយាល័យនិងអង្គភាពនីមួយៗត្រូវបំពេញមុខងារស្រប់តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ រដ្ឋបាលស្រុកត្រូវរៀបចំឱ្យមានលក្ខខណ្ឌការងារជាក់លាក់សម្រាប់បុគ្គលិកម្នាក់ៗ ដោយផ្អែកតាមតួនាទីភារកិច្ចរបស់ការិយាល័យនិងអង្គភាពនីមួយៗ នឹងគោលការណ៍ណែនាំជាធរមាន។ បុគ្គលិកម្នាក់ៗនៃការិយាល័យ និងអង្គភាព នីមួយៗត្រូវបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនស្របតាមលក្ខខណ្ឌការងារដែលបានកំណត់។
- ក្នុងករណីចាំបាច់ក្រសួងមហាផ្ទៃសហការជាមួយក្រសួងសាធារណការ និងក្រសួងស្ថាប័នពាក់ព័ន្ធអាចផ្តល់ការណែនាំបន្ថែមពីការរៀបចំលក្ខខណ្ឌការងារខាងលើនេះ។
- រដ្ឋបាលស្រុកអាចរៀបចំឱ្យមានភ្នាក់ងារតាមការិយាល័យ នីមួយៗសម្រាប់ទទួលបន្ទុកកិច្ចការ ឬវិស័យជាក់លាក់ណាមួយ ឬមួយចំនួនទៀតតាមស្ថានភាពនៃស្រុកនីមួយៗ ។
- ការរៀបចំការងារទទួលបន្ទុកតាមកិច្ចការ ឬវិស័យជាក់លាក់ណាមួយ ឬមួយចំនួនត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋបាលស្រុក។
- ការិយាល័យ និងអង្គភាពនីមួយៗត្រូវរៀបចំផែនការសកម្មភាព និងរបាយការណ៍ទៀងទាត់ តាម

គោលការណ៍កំណត់ ព្រមទាំងត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់ ដើម្បីត្រួតពិនិត្យលើការងារដែលបានអនុវត្ត កំណត់បញ្ហាប្រឈមនានាដែលត្រូវបានដោះស្រាយ និងកំណត់ទិសដៅដែលត្រូវអនុវត្តបន្ត។

- ប្រធានការិយាល័យ និងអង្គភាពនីមួយៗត្រូវធានាថាបុគ្គលិកក្នុងការិយាល័យ និងអង្គភាពរបស់ខ្លួនមកបំពេញការងារជាទៀងទាត់ អនុវត្តតួនាទី ភារកិច្ចតាមលក្ខខណ្ឌការងារគោរពតាមបទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌វិជ្ជាជីវៈដែលបានកំណត់ ។
- រដ្ឋបាលស្រុកត្រូវរៀបចំការចុះ វត្តមានបុគ្គលិកប្រចាំថ្ងៃ និងកំណត់អំពីបទបញ្ជីផ្ទៃក្នុងនិងក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់បុគ្គលិករបស់រដ្ឋបាលស្រុក។
- ប្រធានការិយាល័យ និងអង្គភាពនីមួយៗត្រូវគ្រប់គ្រងចាត់ចែង និងអនុវត្តការងារពាក់ព័ន្ធនឹងបុគ្គលិហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងការងាររដ្ឋបាលស្របតាមនិតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងលក្ខណៈ ការងារដែលបានកំណត់ ។
- រដ្ឋបាលស្រុក ទៅរៀបចំរបៀបរបបធ្វើការងារលម្អិតសម្រាប់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាល ដើម្បីធានាដល់ប្រសិទ្ធិភាពនៃការគ្រប់គ្រងការចាត់ចែង និងអនុវត្តមុខងាររបស់ខ្លួនដោយផ្អែកតាមគោលការណ៍នានាដែលបានកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៃអនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ជាធរមាន។[54]

## ២.៣. យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍ

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក្រុងបានឆ្លងកាត់នូវការវិវឌ្ឍន៍ និងផ្លាស់ប្តូរជាច្រើនទាំងក្នុងទិដ្ឋភាពនយោបាយ សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ ក៏ដូចជាក្នុងទិដ្ឋភាពសេដ្ឋកិច្ចសង្គម ជាពិសេសគឺសុខសន្តិភាពសុវត្ថិភាពនិងស្ថិរភាពនយោបាយចាប់ពីឆ្នាំ១៩៩៨មកម្លេះ។ កត្តាទាំងនោះបានបង្កជាល័ក្ខខ័ណ្ឌចាំបាច់នានាសម្រាប់ការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំក្រុង ស្រុក ស្ថាប័នពាក់ព័ន្ធ មន្ត្រីរាជការ ព្រមទាំង អង្គការជាតិ អន្តរជាតិនានាដើម្បីធ្វើឱ្យសម្រេចបាននូវ សមិទ្ធផលផ្នែកសេដ្ឋកិច្ច-សង្គម ក្នុងក្រុងទាំងមូលក៏ទទួលបាន លទ្ធផលជាផ្លែផ្កាគួជាទីមោទនៈ។

ក្រុមប្រឹក្សាក្រុង ស្រុក បានដាក់ចេញនូវផែនការអភិវឌ្ឍនេះឡើង ដោយផ្តោតការយកចិត្តទុកដាក់ដែលសំដៅតម្រង់ទិសបណ្តាសកម្មភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ក្នុងក្រុង ស្រុកទាំងមូលស្របតាមចក្ខុវិស័យដែលបានកំណត់ដើម្បីឆ្ពោះទៅសម្រេចគោលដៅ និងគោលបំណងនៃការអភិវឌ្ឍដោយមានការចែករំលែក

[54] អនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥,(មាត្រា២៩-មាត្រា៣៤)

ព័ត៌មាន តម្លាភាព គណនេយ្យភាព សង្គតិភាពនិង សុខុដុមនីយកម្ម តាមបែប ប្រជាធិបតេយ្យ និងឱ្យមាន ប្រសិទ្ធភាពនិងសុក្រឹតភាពសេដ្ឋកិច្ចនិងសង្គម និងការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន ព្រមទាំងការធានាឱ្យមានសមធម៌ និងយុត្តិធម៌ក្នុងសង្គម។ ដើម្បីឱ្យផែនការអភិវឌ្ឍន៍នៅក្នុងស្រុកស្រប់ទៅតាមក្របខ័ណ្ឌអភិវឌ្ឍន៍រដ្ឋបាលខេត្ត បានពង្រឹងបន្ថែមទៅលើយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖[55]

❖ **យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច៖**

- ការបង្កើនទិន្នផលស្រូវតាមរយៈការបង្កើនចំណេះបច្ចេកទេសដាំដុះដល់កសិករ រួមទាំងផ្សព្វផ្សាយការប្រើប្រាស់ ពូជផ្តល់ទិន្នផលខ្ពស់និងសុំាទៅនឹងអាកាសធាតុ
- ពង្រីកផ្ទៃដីស្រោចស្រពដោយ ប្រព័ន្ធធារាសាស្ត្រតាមរយៈ សាងសង់សំណង់ធារាសាស្ត្រ ស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់
- បង្កើនការដាំដុះដំណាំរយៈ ពេលខ្លី ដំណាំរយៈពេលវែង និង ដំណាំរួមផ្សំផ្សេងទៀតតាមរយៈ បណ្តុះបណ្តាលនិងផ្សព្វផ្សាយបច្ចេកទេសដាំដុះ ផ្សព្វផ្សាយពីការប្រើប្រាស់ពូជផ្តល់ទិន្នភលខ្ពស់ បណ្តុះបណ្តាលពីសាលារៀនទីផ្សាកសិករ និងផ្តល់ចំណេះដឹងពីការកែច្នៃ វេចខ្ចប់ ទុកដាកឱផលិតផល។
- ជំរុញកំណើនការចិញ្ចឹមសត្វ ជាលក្ខណៈកសិដ្ឋាននិងជាលក្ខណគ្រួសារដោយបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វបង្កើនសមត្ថភាព នឹងប្រសិទ្ធភាពក្នុងការផ្តល់សេវាសុខភាពសត្វ។
- ជំរុញការអភិវឌ្ឍវិស័យឯកជននិងការងារដោយ បង្កលក្ខណៈងាយស្រួលសម្រាប់ការវិនិយោគបង្កើតទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធរវាងវិស័យឯកជននិងស្ថាប័នរដ្ឋ ពង្រីកបណ្តាញអគ្គិសនី និងទឹកស្អាត
- បង្កើនសមត្ថភាពវិជ្ជាជីវៈ ដើម្បីបង្កើតមុខរបរនិងការងារតាមរយៈ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈរយៈពេលខ្លី ពង្រីកថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈផ្តល់ឱកាសដល់យុវជនបានចូលសិក្សានៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ
- ជំរុញការអភិវឌ្ឍតំបន់ទេសចរណ៍ដោយ អភិវឌ្ឍតំបន់ទេសចរណ៍ ពង្រីកការផ្សព្វផ្សាយពីសក្តដានុពលទេសចរណ៍កែលម្អគុណភាពសេវាកម្មសម្រាប់បម្រើឱ្យភ្ញៀវទេសចរ ជំរុញគុណភាពសោភ័ណភាពផល្លិតកម្មវត្ថុអនុស្សាវរីយ៍ និងបង្កើនសមត្ថភាពមគ្គុទេសទេសចរណ៍

❖ **យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច៖**

[55] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំរបស់ស្រុកសណ្តាន់ ២០១៩-២០២៤

- ពង្រឹងនិងពង្រីកកម្មវិធីអប់រំកុមារតូចដោយ បង្កើតមត្តេយ្យសិក្សារដ្ឋគាំទ្រដំណើរការមត្តេយ្យសហគមន៍ដែលមានស្រាប់ និងអប់រំមាតាបិតាឱ្យយល់ពីអត្ថប្រយោជន៍នៃការសិក្សាថ្នាក់ដំបូងរបស់កុមារ
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការសិក្សានៅគ្រប់កម្រិតដោយ បង្កើតសាលារៀនឱ្យគ្រប់កម្រិតថ្នាក់ស្របតាមភូមិសាស្ត្រជាក់ស្តែង កែលម្អគុណភាពនៃការបង្រៀននិងរៀនគ្រប់កម្រិតសិក្សា ផ្តល់លទ្ធភាពដល់សិស្ស ក្នុងគ្រួសារក្រីក្របានបន្តការសិក្សា ផ្តល់លទ្ធភាពដល់សិស្សមកពីឆ្ងាយស្នាក់នៅសាលា
- លើកកម្ពស់សុខភាពមាតានិងទារកដោយ ពង្រឹងនិងពង្រីកសេវាសុខភាពសាធារណៈ អប់រំពីសុខភាពបន្តពូជ អប់រំពីការថែទាំសុខភាពមាតា និងទារកអប់រំការយល់ដឹងពីបញ្ហាអាហារូបត្ថម្ភផ្តល់សេវាដោយមិនគិតថ្លៃដល់គ្រួសារក្រីក្រ
- ពង្រឹងរាជធានីការការពារទប់ស្កាត់ជំងឺឆ្លោតនឹងជំងឺរាំរ៉ៃផ្សេងៗទៀតដោយ អប់រំឱ្យមានការចូលរួមធ្វើអនាម័យជាប្រចាំ អប់រំផ្សព្វផ្សាយវិធីការ ការទប់ស្កាត់ជំងឺឆ្លងគ្រប់ប្រភេទ អប់រំឱ្យស្វែងរកសេវាពិគ្រោះនិងព្យាបាលពេលមានជំងឺ ផ្តល់សេវាថែទាំព្យាបាលដោយឥតគិតថ្លៃដល់គ្រួសារក្រីក្រ
- លើកកម្ពស់សុខភាពប្រជាពលរដ្ឋតាមរយៈការប្រើប្រាស់ទឹកស្អាតនិងបង្គន់អនាម័យដោយ សាងសង់ប្រពន្ធផ្គត់ផ្គង់ទឹកស្អាត ជួសជុលអណ្តូងដែល មានស្រាប់ផ្តល់នយោបាយចម្រុះទឹកស្អាត សាងសង់បង្គន់អនាម័យ និងផ្តល់ការអប់រំដល់ប្រជាពលរដ្ឋឱ្យមានការយល់ដឹងពីសុខភាពនិងអនាម័យ
- យកចិត្តទុកដាក់ចំពោះជនងាយរងគ្រោះឱ្យមានជីវភាពរស់នៅសមរម្យដោយ ផ្តល់ឱកាសស្មើភាពដោយជនពិការបានចូលរួមពីគ្រោះយោបល់ ក្នុងការអភិវឌ្ឍ និងការងារសង្គមយកចិត្តទុកដាក់ចំពោះជនរងគ្រោះ គាំទ្រដល់ជនពិការឱ្យទទួលបានផលប្រយោជន៍ពីការងារដោយសីលធម៌ បណ្តុះបណ្តាលជំនាញវិជ្ជាជីវ វត្ថុគាំទ្រសម្រាប់ការបង្កើតមុខ របរ ផ្សេងៗ
- បង្កើនការយល់ដឹងអំពីការបញ្ជ្រាបយេនឌ័រនិងការចូលរួមក្នុងឆាកនយោបាយរបស់ស្ត្រីដោយ ពង្រីកបណ្តាញការងារយេនឌ័រ ជំរុញការគាំទ្រពីសហគមន៍និងគ្រួសារស្ត្រីចូលរួមក្នុងឆាកនយោបាយលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពសង្គម។[56]

[56] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំរបស់ស្រុកសណ្តាន់ ២០១៩-២០២៤

### ២.៣.១.គោលការណ៍សំខាន់ៗនៃការកសាងផែនការអភិវឌ្ឍ

ក្រុមប្រឹក្សាក្រុង ស្រុក បានដាក់ចេញនូវផែនការអភិវឌ្ឍនេះឡើង ដោយផ្ដោតការ យកចិត្តទុកដាក់ដែលសំដៅតម្រង់ទិសបណ្ដាសកម្មភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ក្នុងក្រុង ទាំងមូលស្របតាមចក្ខុវិស័យដែលបានកំណត់ ដើម្បីឆ្ពោះទៅសម្រេចគោលដៅ និងគោលបំណងនៃការអភិវឌ្ឍដោយមានការចែករំលែកព័ត៌មាន តម្លាភាព គណនេយ្យភាព សង្គតិភាពនិង សុខុដុមនីយកម្ម តាមបែប ប្រជាធិបតេយ្យ និងឱ្យមានប្រសិទ្ធភាពនិងសុក្រឹតភាពសេដ្ឋកិច្ចនិងសង្គម និងការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន ព្រមទាំងការធានាឱ្យមានសមធម៌ និងយុត្តិធម៌ក្នុងសង្គម។ តាមច្បាប់ស្ដីពីគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្ដីពីការគ្រប់រដ្ឋបាលឃុំ សង្កាត់ បានកំណត់នៃអាណត្តិក្រុមប្រឹក្សានីមួយៗដោយរៀបចំ និងអនុម័តផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំតាមរយៈការរៀបចំកម្មវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ ជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិផ្ដោតលើតម្រូវការអភិវឌ្ឍសំខាន់ៗដូចជា៖

- តម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ទទួលមុខងារ និងធនធានថ្មី។
- សេវាមធ្យោបាយ សម្ភារ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋានចាំបាច់។
- ការកាត់បន្ថយភាពក្រីក្រ។
- តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ និងក្រុមជនងាយរងគ្រោះ។

ក្នុងសេចក្ដីណែនាំបំពេញបន្ថែម លើសេចក្ដីណែនាំបច្ចេកទេស ស្ដីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ បានផ្ដោតលើការរៀបចំយុទ្ធសាស្ត្រថវិកាជាតិ ស្របតាមក្របខណ្ឌពេលវេលារៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមបណ្ដាឆ្នាំនីមួយៗ ក្នុងរយៈពេលបីឆ្នាំ នឹងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម(បីឆ្នាំ)របស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ឱ្យកាន់តែមានតម្លាភាព និងប្រសិទ្ធភាព។

### ២.៣.២. កម្មវិធីវិនិយោគស្រុក ឃុំសង្កាត់

កម្មវិធីវិនិយោគនេះ ជាសមិទ្ធផលរួមដ៏មានតម្លៃ ដែលបានមកពីការពិគ្រោះយោបល់ច្រើនលើកច្រើនសារវាងបណ្ដាភាគីពាក់ព័ន្ធ ដោយផ្អែកលើការវិភាគយ៉ាងលម្អិតនូវស្ថានភាពបច្ចុប្បន្នរបស់ក្រុង ស្រុក ជាពិសេសការស្វែងយល់អំពីសក្ដានុពលធនធានធម្មជាតិ ព្រមទាំងបញ្ហាប្រឈម និងតម្រូវការនានា ដើម្បីកំណត់បាននូវវិធានការសម្រាប់ដោះស្រាយ និងឆ្លើយតបនូវតម្រូវការរបស់ប្រជាពលរដ្ឋយ៉ាងពិតប្រាកដ។ ដើម្បីអនុវត្តនូវផែនការអភិវឌ្ឍន៍នេះឱ្យសម្រេចបានលទ្ធផលជាផ្លែផ្កាទាមទារឱ្យមានការពង្រឹងបរិស្ថាន គ្របដណ្ដប់មួយដោយយក

អភិបាលកិច្ចល្អជាស្នូលដូចដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាល ទី៣ របស់រាជរដ្ឋាភិបាលកម្ពុជាគម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល។[57]

ម្យ៉ាងវិញទៀតកម្មវិធីវិនិយោគ៣ឆ្នាំរំកិលនេះ ត្រូវបានធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់ភាគីពាក់ព័ន្ធនានា និងប្រជាជនគ្រប់មូលដ្ឋានដើម្បីរួមគ្នាអនុវត្តនិងត្រួតពិនិត្យវាយតម្លៃលទ្ធផលនានា។ ក្នុងដំណើរការ អនុវត្តនេះបញ្ហាប្រឈមនិងតម្រូវការថ្មីៗជាច្រើនទៀតនឹងលេចចេញឡើងដែលតម្រូវឱ្យមានការធ្វើបច្ចុប្បន្នកម្មវិធីវិនិយោគ និងផែនការអភិវឌ្ឍន៍ជាបន្តបន្ទាប់ដើម្បីឆ្លើយតបទៅនឹងបញ្ហានិងតម្រូវការថ្មីៗទាំងនោះឱ្យបានទាន់ពេលវេលា។ ទន្ទឹមនេះកម្មវិធីជាតិនេះក៏ត្រូវបានរៀបចំឡើងក្នុងបរិបទដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋបាលគ្រប់លំដាប់ថ្នាក់ សំដៅលើកកម្ពស់អភិបាលកិច្ចល្អ ការលើកស្ទួយការអភិវឌ្ឍនិងការកាត់បន្ថយភាពក្រីក្របន្ថែមទៀត។

ដើម្បីសម្រេចបាននូវគោលបំណងនេះ ចាំបាច់ត្រូវរៀបចំឱ្យមានការសហការដ៏មានប្រសិទ្ធភាពរវាងកិច្ចខិតខំប្រឹងប្រែងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដំណើរការនេះ ទាមទារឱ្យប្រជាពលរដ្ឋគ្រប់រូបមានឱកាសស្មើគ្នា ដើម្បីចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន និងទាមទារឱ្យមានការផ្តល់សេវាសាធារណៈដែលមានគុណភាព និងទូលំទូលាយជាងមុន ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងការកាត់បន្ថយភាពក្រីក្រដោយផ្តោតការយកចិត្តទុកដាក់ទៅលើក្រុមជនងាយរងគ្រោះ ជាពិសេសជនជាតិដើមភាគតិច ស្ត្រី និងកុមារ។ ដូច្នេះ គោលបំណងដ៏ទូលំទូលាយរបស់រាជរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិគឺដើម្បី ៖

- បង្កើតវប្បធម៌ប្រជាធិបតេយ្យដោយមានការចូលរួមពីប្រជាពលរដ្ឋនិងប្រកបដោយការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ
- កែលម្អការផ្តល់សេវាសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធ
- នាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចចូលរួមកាត់បន្ថយភាពក្រីក្រ។

## ២.៤.សមិទ្ធិផល និងការតាមដានវាយតម្លៃនៃការអនុវត្តផែនការអភិវឌ្ឍស្រុក

ការត្រួតពិនិត្យវាយតម្លៃគឺជាការងារមួយចាំបាច់ដែលមិនអាចខ្វះបាន ចំពោះការអនុវត្តផែនការសកម្មភាពនីមួយៗ ផែនការសកម្មភាពអភិវឌ្ឍជាការងារមានទំហំធំធេងគ្របដណ្តប់លើគ្រប់វិស័យ មានដៃគូអភិវឌ្ឍមកពីគ្រប់វិស័យ និងគ្រប់មជ្ឈដ្ឋានបានយកចិត្តទុកដាក់វិនិយោគយ៉ាងច្រើន ដើម្បីមកចូលរួមចំណែកអភិវឌ្ឍនៅទូ

[57] អនុក្រឹត្យស្តីពី ផែនការអភិវឌ្ឍន៍ នឹងវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ,លេខ ២១៩.អនក្រ.បក,ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩

ទាំងខេត្ត។ សក្ខមភាពនិងទុនដ៏សន្ទឹកសន្ធាប់ទាំងនេះ វានឹងអាចបង្ការជាបញ្ហាយ៉ាងច្រើន ដែលជះឥទ្ធិពលមកលើការគ្រប់គ្រង និងការប្រែការគ្រប់គ្រងនេះក៏មានការពិនិត្យវាយតម្លៃទេនោះ។

គោលបំណងចម្បងក្នុងការត្រួតពិនិត្យវាយតម្លៃគឺ ការរកឱ្យឃើញនូវចំណុចសកម្ម/អសកម្ម និងផលប៉ះពាល់ផ្សេងៗក្នុងសកម្មភាពអភិវឌ្ឍដើម្បីបានជាមូលដ្ឋានសម្រាប់ត្រះរិះពិចារណាំ និងដោះស្រាយសំដៅកែសម្រួលការអនុវត្តសកម្មភាពអភិវឌ្ឍទៅអនាគតឱ្យបានល្អប្រសើរជាងនេះ។

ដើម្បីការងារត្រួតពិនិត្យវាយតម្លៃប្រព្រឹត្តទៅបានដោយរលូននិងមានប្រសិទ្ធភាពការងារត្រួតពិនិត្យវាយតម្លៃត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើកិច្ចការចាំបាច់មួយចំនួនគឺៈ[58]

- ក្រុមប្រឹក្សាខេត្តប្រគល់ភារកិច្ច និងបង្កលក្ខណៈទីចាត់ការផែនការនិងវិនិយោគមានលទ្ធភាពគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យ ការអនុវត្តផែនការវិនិយោគរបស់មន្ត្រីមន្ទីរអង្គភាពប្រចាំឆ្នាំនីមួយៗ
- គ្រប់មន្ទីរអង្គភាពពាក់ព័ន្ធទាំងអស់ត្រូវបង្កលក្ខណៈងាយស្រួលសម្រាប់សកម្មភាពត្រួតពិនិត្យនេះ។
- ត្រូវកសាងសកម្មភាពផែនទី តាមដានវាយតម្លៃអនុវត្ត ផែនការដល់មេត្រី ទទួលបន្ទុក។
- ត្រូវមានកម្មវិធីការងារប្រចាំត្រីមាស ឆមាស និងឆ្នាំជាក់លាក់។
- ត្រូវធ្វើរបាយការណ៍រីកចំរើនប្រចាំត្រីមាស ឆ្នាំផ្ញើមកក្រុមប្រឹក្សាខេត្ត.គណៈអភិបាលខេត្ត.មន្ទីរផែនការខេត្ត តាមការកំណត់របស់ក្រុមប្រឹក្សាខេត្ត។
- ត្រូវបង្កលក្ខណៈឱ្យមានការចូលរួមពីដៃគូអភិវឌ្ឍ ( មន្ទីរជំនាញអង្គភាពនានាផ្នែកឯកជន,នឹងមូលដ្ឋាន ) តាមរយៈការផ្តល់កិច្ចសហការនិងការធ្វើរបាយការណ៍ជូនគណៈអភិបាលខេត្ត។
- តាមរយៈការត្រួតពិនិត្យសុខភាពការងារនេះចាត់ការផែនការនិងវិនិយោគត្រូវធ្វើការបូកសរុបលទ្ធផលជូនគណៈអភិបាលខេត្តក្រុមប្រឹក្សាខេត្តឱ្យបានទៀងទាត់ជាប្រចាំ។

## ២.៥.បញ្ហាប្រឈម និងដំណោះស្រាយ

### ២.៥.១.បញ្ហាប្រឈម

ស្រុកសណ្តាន់ ជាស្រុកមានផ្ទៃដីធំទូលាយថែមទាំងមានធនធានធម្មជាតិដូចជាព្រៃឈើ(ព្រៃឡង់គ្របដណ្តប់ជាង១២ម៉ឺនហិកតា) និងព្រៃផ្សេងៗ។ ការទន្ទ្រានកាន់កាប់ដីព្រៃ ដែនជម្រកសត្វព្រៃ ព្រៃលិចទឹក ដីបម្រុងទុករបស់រដ្ឋនៅតែបន្តកើតមានលំហូរចូលនៃការវិនិយោគ និងប្រជាជនពីក្រៅខេត្តបានធ្វើឱ្យប្រជាជននៅនឹងកន្លែងមានការព្រួយបារម្ភខ្លាចបាត់បង់ដីព្រៃឈើដែលខ្លួនធ្លាប់រស់នៅ និងប្រកបមុខរបរ។ ឆ្នាំ២០១៩ បាន

[58] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំរបស់ស្រុកសណ្តាន់ ២០១៩-២០២៤

បង្ហាញឱ្យឃើញថាការធ្វើចំណាកស្រុករបស់ប្រជាជន បានចេញទៅប្រកបមុខរបរផ្សេងៗទាំងក្នុងនិងក្រៅប្រទេសដើម្បីទៅរកស៊ីឬធ្វើជាកម្មករក្រុមហ៊ុន-រោងចក្រ។

**២.៥.២. ដំណោះស្រាយ**

ដោយសារព្រៃឈើកាន់តែរេចរិលប៉ុន្តែមានអត្ថប្រយោជន៍ ជាសកលទើបបានជាកន្លងមកនេះក្រសួងកសិកម្មបានសម្រេចបង្កើតតំបន់ព្រៃសហគមន៍ក្នុងស្រុកចំនួន៣១ កន្លែងមានផ្ទៃដីព្រៃ សរុប ៥០៨.១៣៦ហត។ ជាមួយគ្នានេះដែរដើម្បីកាត់បន្ថយចំណាកស្រុករបស់ប្រជាពលរដ្ឋ គឺមានក្រុមហ៊ុនវិនិយោគជាច្រើនដែលកំពុងតែមើលឃើញអំពីសក្តានុពលទៅលើដំណាំកសិ-ឧស្សាហកម្មជាពិសេសកៅស៊ូ ដំឡូងមី ស្វាយចន្ទីក៏កំពុងពង្រីកវិសាលភាព និងបង្កើតជាមុខរបរសម្រាប់ប្រជាពលរដ្ឋនៅក្នុងស្រុក។

- ដោយឡែកផ្នែករដ្ឋបាលព្រៃឈើស្រុកសណ្តាន់មានថ្នាលបណ្តុះកូនឈើចំនួន ៣ កន្លែងបានបណ្តុះកូនឈើ ឈើហូបផ្លែសម្រាប់ដាំ និងចែកជូនប្រជាជនជាលក្ខណៈគ្រួសារ។ មានក្រុមការងារផ្សព្វផ្សាយរដ្ឋបាលព្រៃឈើ បានសហការណ៍ជាមួយមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងមានការរៀបចំការផ្សព្វផ្សាយអប់រំ លើកកម្ពស់ការយល់ដឹងអំពីគុណប្រយោជន៍ទូទៅនៃជីវចម្រុះរបស់ព្រៃឈើជាសាធារណៈ និងបច្ចេកទេសដាំដុះព្រៃឈើឡើងវិញដល់ប្រជាពលរដ្ឋដើម្បីរួមចំណែកក្នុងការងារថែរក្សាការពារព្រៃឈើឱ្យបានយូរអង្វែង។
- ម្យ៉ាងវិញទៀតអ្វីដែលកាន់តែពិសេស គឺប្រព័ន្ធគមនាគម៍ និងប្រព័ន្ធធារាសាស្ត្រក៏កាន់តែមានការរីកចម្រើនគួរឱ្យកត់សំគាលផងដែរ។ ដើម្បីឱ្យប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការ ប្រកបមុខរបរធ្វើស្រែ និងចំការរដ្ឋបាលប្រព័ន្ធធារាសាស្ត្រអូរមាន ដែលបានកសាងដោយគម្រោងស្តារប្រព័ន្ធធារាសាស្ត្ររបស់មន្ទីរធនធានទឹកនិងឧតុនិយមខេត្តកំពង់ធំ។ បច្ចុប្បន្នអាជ្ញាធរខេត្ត និងមន្ទីរទេសចរណ៍បាននឹងកំពុងសិក្សាតំបន់នេះឱ្យក្លាយទៅជារមណីយដ្ឋានទេសចរណ៍កែច្នៃ សម្រាប់ទាក់ទាញភ្ញៀវទេសចរមកលេងកម្សាន្តសប្បាយ។ ទីតាំង ស្ថិតនៅភូមិរនាមឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ចម្ងាយ ៦០គ.ម ពីទីរួមខេត្តកំពង់ធំ (តាមផ្លូវជាតិលេខ៦២ ឆ្លងកាត់ស្រុកប្រាសាទសំបូរ) សក្តានុពលទេសចរណ៍ ៖ ទឹកហូរធ្លាក់ពីទំនប់បង្ហៀរ ជិះទូកកម្សាន្ត ក្នុងអំឡុងខែវស្សា សម្រាកលំហែកម្សាន្ត លេងទឹកទឹកហូរធ្លាក់ពីទំនប់បង្ហៀរ និងអាចបរិភោគអាហារ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជាបានតាំងចិត្តខ្ពស់ក្នុងការលើកកម្ពស់គុណភាពនៃការគ្រប់គ្រងរដ្ឋបាលសាធារណៈ ក្នុងគោលបំណងបម្រើសេវាជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើ។ ជាលទ្ធផលក៏ទទួលបានការជឿទុកចិត្ត និង ការគាំទ្រពីប្រជាពលរដ្ឋ សម្រាប់ការវិនិយោគក៏មានការកើនឡើង និងសេដ្ឋកិច្ចជាតិកាន់តែរីកចម្រើន ដើម្បីឆ្លើយ តបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងសម័យ សកលភាវូបនីយកម្ម។

ឆ្លងកាត់តាមរយៈការសិក្សាស្រាវជ្រាវអំពីការគ្រប់គ្រងរដ្ឋបាលក្នុងឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២១ នៅស្រុក សណ្តាន់ខេត្តកំពង់ធំ នាងខ្ញុំគិតថា ការគ្រប់គ្រងរដ្ឋបាលនៅក្នុងស្រុកសណ្តាន់មានដំណើរការប្រព្រឹត្តទៅបានល្អ ស្របទៅតាមគោលការណ៍ប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិដោយរដ្ឋបាលស្រុកនេះបានខិតខំជំនះ ពោះពាតែ រាល់ការលំបាកស្មុគស្មាញ និងអនុវត្តគ្រប់វិធានការទាំងអស់ដើម្បីធានាផ្តល់អោយ បាននូវសុខសុវត្ថិភាពជូន ដល់ប្រជាពលរដ្ឋរបស់ខ្លួន។ ម្យ៉ាងវិញទៀតការពង្រឹង ការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ជូនប្រជាពលរដ្ឋ ក៏បាន ធ្វើឱ្យមានការកាត់បន្ថយនូវតួលេខគ្រោះថ្នាក់ចរាចរណ៍បានច្រើន រួមទាំងការអនុវត្តច្បាប់ប្រព្រឹត្តទៅប្រកបដោយ ប្រសិទ្ធភាពផងដែរ។មិនតែប៉ុណ្ណោះ ការគ្រប់គ្រងរដ្ឋបាលស្រុកសណ្តាន់ ក៏បានផ្តល់ឱ្យប្រជាពលរដ្ឋរស់នៅ ប្រកបដោយសុខសុវត្ថភាពទាំងផ្លូវកាយ និងទាំងចិត្តដែលទទួលបាននូវ តម្លាភាព ប្រសិទ្ធភាព តាមរយៈការ ខិតខំប្រឹងប្រែងអនុវត្តគោលនយោបាយគ្រប់គ្រងរដ្ឋបាលនៅថ្នាក់មូលដ្ឋានរបស់រាជរដ្ឋាភិបាល ព្រមទាំងមន្ត្រី រាជការគ្រប់ជាន់ថ្នាក់ដែលបានបំរើការងារថ្នាក់មូលដ្ឋាន នៃការគ្រប់គ្រងត្រូវបានគូសជាផ្នែកមួយដែលចូលរួម ក្នុងការលើកទឹកចិត្ត កម្ពស់អភិបាលកិច្ចល្អនៅថ្នាក់មូលដ្ឋាន។ ការគ្រប់គ្រងរដ្ឋបាល ក្នុងឆ្នាំ ២០១៩ ដល់ បច្ចុប្បន្ន នៅស្រុកសណ្តាន់ខេត្តកំពង់ធំ បានទទួលផលវិជ្ជមានជាច្រើន ជាពិសេសគឺការបំពេញសេចកីត្រូវការ របស់ប្រជាពលរដ្ឋ និងផ្តល់ភាពកក់កៅដល់ប្រជាពលរដ្ឋនៅតាមដែនសមត្ថកិច្ច របស់ខ្លួនដោយការរស់នៅ ប្រកបដោយភាពស្ងប់សុខ និងមានការយកចិត្តទុកដាក់នូវការលើកកម្ពស់សុខុមាលភាពពីសំណាក់អាជ្ញាធ រមូលដ្ឋាន។

ម្យ៉ាងវិញទៀតចំពោះការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ រដ្ឋបាលស្រុកសណ្តាន់បានអនុវត្តតាម ផែនការណែនាំស្តីពីការចាត់តាំងគោលនយោបាយភូមិឃុំមានសុវត្ថិដើម្បីធានាបានធ្វើឱ្យសន្តិសុខសណ្តាប់ ធ្នាប់សាធារណៈ នៅក្នុងស្រុកទាំងមូលមានសភាពកាន់តែប្រសើរឡើងជាលំដាប់ ធ្វើឱ្យបទល្មើសមានការថយ ចុះបើប្រៀបធៀប និងរយៈពេលដូចគ្នា និងឆ្នាំកន្លងមក ដែលធ្វើឱ្យប្រជាពលរដ្ឋ មាន លំនឹងទាំង ផ្លូវកាយ និងផ្លូវ ចិត្តក្នុងការប្រកបមុខរបរ ចិញ្ចឹមជីវិតប្រចាំថ្ងៃកាន់តែល្អប្រសើ និងស្រុក ឃុំទាំងមូលមានរីកចម្រើនជាលំដាប់ ។

# អនុសាសន៍

# អនុសាសន៍

យោងតាមការពិនិត្យ និងការឆ្លងកាត់ការបកស្រាយ លើស្ថានភាពជាក់ស្តែង នៅក្នុងស្រុកសណ្តាន់ នាងខ្ញុំឃើញថាមានការអភិវឌ្ឍ នឹងការរីកចម្រើនគួរឱ្យកតសម្គាល់ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសំខាន់សំខាន់ជាច្រើន។ ម្យ៉ាងវិញទៀតដោយសារស្ថានភាពភូមិសាស្ត្រស្រុកសណ្តាន់មានលក្ខណៈអំណោយផលដល់ការដាំដំណាំកសិឧស្សាហកម្ម ប្រជាពលរដ្ឋ បានធ្វើការដាំដុះកៅស៊ូជាលក្ខណគ្រួសារ ដាំដំឡូងមី សណ្តែកសៀង សណ្តែកបាយ ដែលផល ដំណាំទាំងនេះបានជួយផ្គត់ផ្គង់ និងធ្វើឱ្យជីវភាពប្រចាំថ្ងៃមានការរីកចម្រើន ឡើងជាលំដាប់ថែមទាំងបានរួមចំណែកយ៉ាងសកម្ម ជាមួយរាជរដ្ឋាភិបាលក្នុងការកាត់បន្ថយ ភាពក្រីក្រ។

ជាការពិតណាស់ដូចដែលយើងបានដឹងហើយថា រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រនានា ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ប្រជាកសិករ និង អភិវឌ្ឍវិស័យកសិកម្ម ដោយផ្តោតការយកចិត្តទុកដាក់ខ្ពស់ចំពោះការកសាងប្រព័ន្ធធារាសាស្ត្រ និងការផ្តល់សេវាគាំទ្រនានា ព្រមទាំងគោលនយោបាយអភិវឌ្ឍជនបទ សំដៅបង្កើតឱកាសឱ្យកាន់តែប្រសើរជូនប្រជាពលរដ្ឋក្នុងការបង្កើនចំណូលប្រចាំគ្រួសារ ដូច្នេះនេះយើងគួរចាប់អារម្មណ៍ឱ្យបានខ្ពស់ចំពោះវិស័យនេះ។

ក៏ប៉ុន្តែមានបញ្ហាមួយចំនួនទៀតដែលអាជ្ញាធរស្រុក កំពុងតែអនុវត្តកែលម្អបន្ថែមប៉ុន្តែហាក់បីដូចជាមិនសូវទទួលបានប្រសិទ្ធិភាព នឹងទទួលបានផលល្អប្រសើរនៅឡើយ។ ជាកិច្ចសំណូមពរនាងខ្ញុំយល់ថា សាលាស្រុកសណ្តាន់ គួរតែពិនិត្យទៅលើចំណុចខ្វះខាត និងចំណុចដែលគួរសម្រប់សម្រួល កែលម្អឡើងវិញនូវចំណុចមួយចំនួនដូចជា៖

- ពិនិត្យលទ្ធភាពរៀបចំវគ្គបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិក និងមន្ត្រីរាជការ បង្កើនការត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពការងាររបស់មន្ត្រីតាមផ្នែកដើម្បី ធានាដល់ការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព។
- ការបង្កើតទំនាក់ទំនងល្អកាន់តែច្រើនជាមួយប្រជាពលរដ្ឋ និងស្វែងយល់ឱកាន់តែច្បាស់ពីតម្រូវការក្នុងមូលដ្ឋានរបស់ពួកគាត់
- រៀបចំជាកញ្ចប់រង្វាន់ប្រចាំឆ្នាំដូចជាថវិកាដើម្បីបន្តលើកទឹកចិត្តមន្ត្រី ដែលមានស្នាដៃល្អក្នុងការធ្វើការ
- ពង្រីកការផ្តល់សេវាច្រកចេញចូលតែមួយ និងការផ្តល់សេវាប្រកបដោយឆន្ទៈ ភាពជាម្ចាស់ការលើមុខនាទីរបស់ខ្លួនភក្តីភាពនិងមនសិការវិជ្ជាជីវៈរបស់មន្ត្រី ដែល បម្រើសេវា
- វិស័យសុខាភិបាល ថ្នាក់ដឹកនាំ គួរតែ បង្កើតបន្ទីពេទ្យបង្អែក នៅតាមឃុំ ជាមួយនឹងមួយសម្រាប់ប្រជាពលរដ្ឋដែលរស់នៅ តាមឃុំ ដែលមានជម្ងឺធ្ងន់ត្រូវទទួលសេវាសុខាភិបាលនៅមន្ទីរពេទ្យបង្អែកឱ្យទាន់ ពេលវេលា ព្រោះ ប្រជាពលរដ្ឋមួយចំនួនធំ មានការខ្វះខាតក្នុងការធ្វើ មធ្យោបាយ ធ្វើដំណើរ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ.លេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ២០០៨
- ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, លេខ ០៦៤/០០៤/២០០៤ កបធ.ច ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៤
- អនិក្រឹត្យស្តីពី ផែនការអភិវឌ្ឍន៍ នឹងវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ,លេខ ២១៩. អនក្រ.បក,ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩
- អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក.លេខ ២១៥ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆកា ឆ្នាំ២០០៩
- អនុក្រិត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក លេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩
- ប្រកាសលេខ ២១០៧ ប្រក កម្រងទិន្នន័យឈ្មោះ និងចំនួន ក្រុង ស្រុក ឃុំ សង្កាត់ និងភូមិ ក្នុងខេត្តកំពង់ធំ រដ្ឋបាលខេត្តកំពង់ធំ,ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩

## ២. សៀវភៅតែងនិពន្ធ

- សៀវភៅ សេចក្តីផ្តើមរដ្ឋបាលសាធារណៈ ឈុន ណារ៉េត ឆ្នាំ២០១៩
- សៀវភៅផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ស្រុកសណ្តាន់ ២០១៩-២០២៤
- សៀវភៅ សេចក្តីផ្តើម រដ្ឋបាលសាធារណៈរបស់ បណ្ឌិត សឿន សោភ័ណឆ្នាំ ២០១៩
- សៀវភៅណែនាំ ស្តីពី តួនាទី និងរបៀបរបបការងាររបស់រដ្ឋបាលស្រុកឆ្នាំ ២០១០
- សៀវភៅរដ្ឋបាលសាធារណៈ សាស្ត្រាចារ្យ ខាំ សុមករា ឆ្នាំ២០១៣
- សៀវភៅ កម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០~២០១៩) បោះពុម្ពឆ្នាំ២០១៨

## ៣. គេហទំព័រ

- គេហទំព័រ https://drive.google.com/file/d/12yoqsEPqAHxKsMeE1FW11g2/view?usp=E
- គេហទំព័រ https://kampongthom.gov.kh/15664/
- គេហទំព័រ https://gda.interior.gov.kh/commune-sangkat-management/
- គេហទំព័រhttps://opendevelopmentcambodia.net/km/topics/provincial-and-local- /

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័នទី១ ៖** ផែនទីរដ្ឋបាលខេត្តកំពង់ធំ និងផែនទីរដ្ឋបាលស្រុកសណ្តាន់

**ឧបសម្ព័នទី២ ៖** ទីតាំងសំខាន់ៗ នៅក្នុងស្រុកសណ្តាន់

**ឧបសម្ព័នទី៣ ៖** អគាររបស់សាលាស្រុកសណ្តាន់

**ឧបសម្ព័នទី៤ ៖** រចនាសម្ព័នរបស់រដ្ឋបាលស្រុកសណ្តាន់

**ឧបសម្ព័នទី៥ ៖** រចនាសម្ពន័ទាំង១៣ថ្មីរបស់រដ្ឋបាលស្រុក

## ២. ឧបសម្ព័ន្ធគតិយុត្តិ

**ឧបសម្ព័នទី១ ៖** ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៧/០១៧ បានអនុម័តកាលថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨

**ឧបសម្ព័នទី២ ៖** អនុក្រឹត្តស្តីពីមុខងារ និងរចនាសម្ព័នរបស់រដ្ឋបាលស្រុក, លេខ១៨៤ អនក្រ.បន ចុះថ្ងៃ ០២ ខែធ្នូ ឆ្នាំ២០១៩

**ឧបសម្ព័នទី៣៖** អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុម ប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៥ អនក្រ_បន ចុះថ្ងៃទី២០ ខែវិច្ឆកា ឆ្នាំ២០០៩

**ឧបសម្ព័នទី៤៖** អនុក្រឹត្យស្តីពី ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ,លេខ ២១៩ អនក្រ.បក,ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩

# ឧបសម្ព័ន្ធរូបភាព

## ឧបសម្ព័ន្ធទី១ ៖ ផែនទីរដ្ឋបាលខេត្តកំពង់ធំ និងផែនទីរដ្ឋបាលស្រុកសណ្តាន់






**ឧបសម្ព័ន្ធទី២ ៖** ទីតាំងសំខាន់ៗ នៅក្នុងស្រុកសណ្ដាន់

(ស្ពានស្ថិតនៅទីរួមស្រុកសណ្ដាន់)







## ឧបសម្ព័នទី៣ ៖ អគាររបស់សាលាស្រុកសណ្ដាន់





**ឧបសម្ព័នទី៤ ៖** រចនាសម្ព័នរបស់រដ្ឋបាលស្រុកសណ្ដាន់



**ឧបសម្ព័ន្ធទី៥ ៖** រចនាសម្ពន្ធ័ទាំង១៣ថ្មីរបស់រដ្ឋបាលស្រុក



# ឧបសម្ព័ន្ធគតិយុត្តិ

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន អនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងរដ្ឋបាល

# រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១

## អំពីបទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ២.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

**មាត្រា ៣.-**

ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ លើកលែងតែបញ្ហាទាំងឡាយណាដែលបានចែងក្នុងច្បាប់នេះ ។

**មាត្រា ៤.-**

ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ ចែកជាខណ្ឌ ។

ខណ្ឌ ចែកជាសង្កាត់ ។

**មាត្រា ៥.-**

ខេត្ត ចែកជាក្រុង និងជាស្រុក ។

ក្រុង ចែកជាសង្កាត់ ។

ស្រុក ចែកជាឃុំ និងជាសង្កាត់ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះខេត្ត ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ការកំណត់ព្រំប្រទល់រាជធានីភ្នំពេញ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.–**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៨.–**

ការបង្កើតរដ្ឋបាលឯកភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺសំដៅដល់ការពង្រឹងអង្គឯកភាពរបស់រដ្ឋ ដើម្បីសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន ។

**មាត្រា ៩.–**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជានីតិបុគ្គលនៃនីតិសាធារណៈ ។

**មាត្រា ១០.–**

នីតិបុគ្គលនីមួយៗ ត្រូវមានក្រុមប្រឹក្សាមួយជាតំណាងដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

**មាត្រា ១១.–**

នីតិបុគ្គលនីមួយៗត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១២.–**

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមាន :

-ភាពជាតំណាងសាធារណៈ

-ស្វ័យភាពរបស់មូលដ្ឋាន

-ការពិគ្រោះយោបល់ និងការចូលរួម

-ការឆ្លើយតប និងគណនេយ្យភាព

-ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន

-ការលើកស្ទួយសមធម៌

-តម្លាភាព និងសុចរិតភាព

-វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច ។

**មាត្រា ១៣.-**

នីតិបុគ្គលទទួលសិទ្ធិអំណាចរបស់ខ្លួន ដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដទៃទៀត ដែលស្របនឹងច្បាប់នេះ ។

## ជំពូកទី ២

## អំពីក្រុមប្រឹក្សា

### ផ្នែកទី ១

### ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**មាត្រា ១៤.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើង តាមការបោះឆ្នោតអសកល ស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅកាត់ថា "ក្រុមប្រឹក្សា" ។

**មាត្រា ១៥.-**

ក្រុមប្រឹក្សាមានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ១៦.-**

ក្នុងពេលរង់ចាំក្រុមប្រឹក្សាថ្មីចូលកាន់មុខតំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិមានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១៧.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ។

ប្រធានក្រុមប្រឹក្សា គឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេ នៅក្នុងក្រុមប្រឹក្សា ។

ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ ។

**មាត្រា ១៨.-**

ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រនិងកត្តាភូមិសាស្ត្រ ដូចខាងក្រោម :

-ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីប្រាំបួន(០៩)រូប ដល់ម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំ(១៥)រូប

-ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំបួន(១៩)រូប ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិចមួយរយម្ភៃ (១២០)ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា ។

ក្នុងករណីគ្មានអនុក្រឹត្យ ចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុបដដែលនៃក្រុមប្រឹក្សាអាណត្តិចាស់ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ១៩.-**

ក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋទាំងអស់ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២០.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២១.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបំពេញតាមលក្ខខណ្ឌ និងមានលក្ខណសម្បត្តិ ដូចខាងក្រោម :

-មានសញ្ជាតិខ្មែរពីកំណើត

-មានអាយុយ៉ាងតិចម្ភៃប្រាំ(២៥)ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោត

-មានសិទ្ធិបោះឆ្នោត និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

**មាត្រា ២២.-**

សមាជិកក្រុមប្រឹក្សាម្នាក់ ត្រូវបាត់បង់សមាជិកភាពពីសមាជិកក្រុមប្រឹក្សាក្នុងករណីណាមួយ ដូចខាងក្រោម :

-សាមីខ្លួនបាត់បង់លក្ខណសម្បត្តិ និងលក្ខខណ្ឌ សម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

-សាមីខ្លួនសុំលាឈប់ពីក្រុមប្រឹក្សា តាមការដាក់ពាក្យសុំលាឈប់ជាលាយលក្ខណ៍អក្សរទៅប្រធានក្រុមប្រឹក្សា

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនមិនបានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាប់ៗគ្នា ចាប់ពីពីរ(០២)ដងឡើងទៅ ដោយគ្មានច្បាប់អនុញ្ញាត

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

-សាមីខ្លួនត្រូវបណ្តេញចេញពីសមាជិកក្រុមប្រឹក្សា អនុលោមតាមច្បាប់ នីតិវិធី ឬបទបញ្ជាផ្ទៃក្នុង ឬ ក្រមសីលធម៌របស់ក្រុមប្រឹក្សា

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេច និងប្រកាសពីការបាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ក្នុងករណីដូចខាងលើនេះ ។

## មាត្រា ២៣.-

នៅពេលដែលមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវជ្រើសរើសបេក្ខជនលំដាប់លេខរៀងបន្ទាប់ ពីក្នុងបញ្ជីបេក្ខជនជាមួយមកជំនួស ក្នុងរយៈពេលយ៉ាងយូរដប់បួន(១៤)ថ្ងៃ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## មាត្រា ២៤.-

ប្រសិនបើក្រុមប្រឹក្សាណាមួយអនុវត្តផ្ទុយពីបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់ក្រុមប្រឹក្សានោះឱ្យគោរព និងអនុវត្តបទប្បញ្ញត្តិទាំងនោះ នៅក្នុងអំឡុងពេលជាក់លាក់ និងសមហេតុផល ។

ក្នុងករណីក្រុមប្រឹក្សានោះនៅតែមិនព្រមអនុវត្តតាមការណែនាំ រាជរដ្ឋាភិបាលត្រូវរំសាយក្រុមប្រឹក្សានោះដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## មាត្រា ២៥.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត “គ.ជ.ប” ត្រូវរៀបចំការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សា ក្នុងករណីណាមួយដូចខាងក្រោម :

-ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបង្កើតថ្មីដូចមានចែងក្នុងមាត្រា ៦ និងមាត្រា ៧ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរពីររយសែសិប (២៤០) ថ្ងៃ

-ក្រុមប្រឹក្សាដែលត្រូវរំសាយតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ(១២០) ថ្ងៃ ។

ក្រុមប្រឹក្សាដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សានោះ ។

**មាត្រា ២៦.-**

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាមានរយៈពេលមិនលើសពីមួយរយប៉ែតសិប(១៨០)ថ្ងៃ ។

**មាត្រា ២៧.-**

ក្នុងករណីដែលមានក្រុមប្រឹក្សាណាមួយត្រូវរំលាយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់វិធានការដើម្បីគ្រប់គ្រងជំនួសរហូតដល់មានក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

**មាត្រា ២៨.-**

សមាជិកក្រុមប្រឹក្សានៅក្នុងមុខតំណែង ត្រូវទទួលប្រាក់ឧបត្ថម្ភ ដែលត្រូវបើកចេញពីគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សានោះ ។

ប្រាក់ឧបត្ថម្ភខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២
## តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

**មាត្រា ២៩.-**

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់នេះ ឬ ដែលស្របតាមច្បាប់នេះ ។

**មាត្រា ៣០.-**

ក្រុមប្រឹក្សា មានសិទ្ធិអំណាចធ្វើសេចក្ដីសម្រេចខាងបញ្ញត្តិ និងសេចក្ដីសម្រេចខាងប្រតិបត្តិ ។

ROYAUME DU CAMBODGE — LE MINISTRE DU PALAIS ROYAL



4

**មាត្រា ៣១.-**

ក្រុមប្រឹក្សា ត្រូវបំពេញមុខងារ និងភារកិច្ច ដោយធ្វើសេចក្ដីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្ដីសម្រេចនោះត្រូវបានអនុវត្ត ។

**មាត្រា ៣២.-**

ក្រុមប្រឹក្សា ប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនដោយការធ្វើដីកា ស្របទៅតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី ៣ ជំពូកទី ២ នៃច្បាប់នេះ ។

**មាត្រា ៣៣.-**

ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចប្រតិបត្តិរបស់ខ្លួនដោយធ្វើសេចក្ដីសម្រេច នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា ។

**មាត្រា ៣៤.-**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្ដីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយណា ដែលខ្លួនយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះ រួចហើយត្រូវផ្ដល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាលនិងអភិបាល ។

**មាត្រា ៣៥.-**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា ។

**មាត្រា ៣៦.-**

រៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្ដីសម្រេច ឬ ដីកាតាមការចាំបាច់ទាក់ទិនទៅនឹង :

-ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្របតាមច្បាប់នេះ

-មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា

-មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា

-កម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ (៥) ឆ្នាំ រួមទាំងសមាសភាគនៃផែនការនោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា

-គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

-បញ្ហាហិរញ្ញវត្ថុផ្សេងទៀត

-ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា

-ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ

-ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ

-កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដែលបានធ្វើឡើងស្របតាមច្បាប់នេះ ។

**មាត្រា ៣៧.-**

ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍរយៈពេលប្រាំ(៥)ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមការរៀបចំកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ ។

**មាត្រា ៣៨.-**

ក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយ:

-ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ប្រភេទក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

នីតិវិធីនៃការពិគ្រោះយោបល់នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៣៩.-**

ក្រុមប្រឹក្សាត្រូវរៀបចំផែនការអភិវឌ្ឍ ដែលរួមមាន :

-ចក្ខុវិស័យរបស់ក្រុមប្រឹក្សា ដោយបង្ហាញពីគោលដៅ និងគោលបំណងសម្រាប់អភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

-ការប៉ាន់ប្រមាណពីកម្រិតនៃការអភិវឌ្ឍដែលមានស្រាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍសំខាន់ៗរួមមាន :

+ តម្រូវការរបស់ក្រុមប្រឹក្សានៅក្នុងការរៀបចំទទួលយកនូវការផ្ទេរមុខងារ ភារកិច្ច និងធនធានថ្មីៗ

+ សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់នានា

+ ការកាត់បន្ថយភាពក្រីក្រ

+ តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ក្រុមជនងាយរងគ្រោះ រួមទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

-ក្របខ័ណ្ឌអភិវឌ្ឍដែលត្រូវថែងអំពីគោលការណ៍ណែនាំជាមូលដ្ឋានក្នុងការប្រើប្រាស់ និងគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិនៅតំបន់នោះ

-ផែនការគ្រប់គ្រងគ្រោះមហន្តរាយ

-ផែនការហិរញ្ញវត្ថុ ដោយត្រូវរាប់បញ្ចូលទាំងផែនការអភិវឌ្ឍមូលធន ការគ្រោងថវិកាសម្រាប់រយៈពេលដប់ពីរ(១២)ខែ ចាប់ពីពេលរៀបចំផែនការ និងសម្រាប់រយៈពេលបី (៣)ឆ្នាំចាប់ពីពេលរៀបចំផែនការ ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ

-យុទ្ធសាស្ត្រអនុវត្តផែនការអភិវឌ្ឍ ដើម្បីធានាឱ្យមានតម្លាភាពនិងគណនេយ្យភាព ចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-សូចនាករបំពេញការងារសំខាន់ៗ និងគោលដៅនានាទាក់ទិននឹងអាទិភាព និងទិសដៅអភិវឌ្ឍនីមួយៗដូចមានចែងក្នុងផែនការអភិវឌ្ឍ

ក្រុមប្រឹក្សាត្រូវកំណត់ឱ្យដាច់ពីគ្នានៅក្នុងផែនការអភិវឌ្ឍ និងថវិកានូវមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ។

បែបបទ នីតិវិធីជាក់ស្តែងនៃការរៀបចំ ការគ្រប់គ្រង និងការអនុវត្តផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## មាត្រា ៤០.–

ក្រុមប្រឹក្សា ត្រូវតាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំ ទៅលើការអនុវត្តផែនការអភិវឌ្ឍរបស់ខ្លួន ដោយរាប់ទាំងផ្នែកនៃផែនការអភិវឌ្ឍដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ :

-ក្រុមប្រឹក្សាប្រភេទរួមគ្នា

-ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត

-ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា។

## មាត្រា ៤១.–

ក្រុមប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវផែនការអភិវឌ្ឍបន្ទាប់ពីបានអនុម័តរួចហើយភ្លាម ។

សាធារណជន អាចពិនិត្យឯកសារផែនការនេះ នៅការិយាល័យរបស់ក្រុមប្រឹក្សាដោយឥតគិតថ្លៃ ឬ អាចស្នើសុំជាវឯកសារផែនការនេះពីក្រុមប្រឹក្សា ដោយគិតត្រឹមតម្លៃដើម ។

## មាត្រា ៤២.–

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុសាធារណៈ ដើម្បីជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងដែលផ្តោតទៅលើតម្រូវការអភិវឌ្ឍសំខាន់ៗបំផុតរួមមាន :

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

-តម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំសម្រាប់ទទួលមុខងារ ភារកិច្ច និងធនធានថ្មីៗ

-សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់

-ការកាត់បន្ថយភាពក្រីក្រ

-តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ និងកុមារ ក្រុមជនងាយរងគ្រោះដោយរួមបញ្ចូលទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

**មាត្រា ៤៣.-**

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុ ឱ្យមានតម្លាភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន ។

**មាត្រា ៤៤.-**

រាជធានី ខេត្ត ក្រុង ស្រុក ត្រូវមានថវិកាផ្ទាល់របស់ខ្លួន ដែលហៅកាត់ថាថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ។

ខណ្ឌ និងសង្កាត់ចំណុះរាជធានី ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់រាជធានី ។

សង្កាត់ចំណុះក្រុង ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់ក្រុង ។

ក្រុមប្រឹក្សាត្រូវអនុម័តលើថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមនីតិវិធីនិងប្រតិទិននៃការកសាងថវិការដ្ឋជារៀងរាល់ឆ្នាំ ។

ក្រុមប្រឹក្សាត្រូវអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។

ការគ្រប់គ្រងនិងការអនុវត្តគម្រោងថវិកាប្រចាំឆ្នាំ ត្រូវផ្អែកតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

ថវិកាត្រូវរៀបចំឡើងដោយគោរពតាមគោលការណ៍សំខាន់ៗទាំងអស់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែមានតុល្យភាពរវាងចំណូល និងចំណាយ ។

**មាត្រា ៤៥.–**

ក្នុងការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុ ក្រុមប្រឹក្សាត្រូវធានាអនុវត្តតាមបទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធី ដែលបានកំណត់ទាក់ទិនទៅនឹង :

-ការរៀបចំ ការអនុម័ត និងការអនុវត្តថវិកា

-គណនេយ្យ និងរបាយការណ៍

-ទ្រព្យសកម្ម និងទ្រព្យអកម្ម

-តម្លាភាព និងគណនេយ្យភាព

-ការគ្រប់គ្រង :

+ ចំណូលផ្ទាល់

+ ចំណូលដែលចែករំលែក មូលនិធិផ្ទេរពីថវិកាជាតិ និងថ្លៃសេវាសម្រាប់អនុវត្តមុខងារជាភ្នាក់ងារក្នុងនាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល

+ ចំណូលពីប្រភពផ្សេងៗទៀត ។

-លទ្ធកម្មសាធារណៈ

-ការធ្វើសវនកម្មផ្ទៃក្នុង

-ការធ្វើសវនកម្មផ្ទៃក្រៅ

-តម្រូវការផ្នែកហិរញ្ញវត្ថុសាធារណៈផ្សេងៗទៀត ។

បទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធីសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៦.–**

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ព្រះបរមរាជវាំង

សម្បត្តិរដ្ឋដែលបានផ្ទេរមកឱ្យខ្លួន ឬ ដែលបានទទួលដោយមធ្យោបាយផ្ទាល់ខ្លួនផ្សេងទៀតឱ្យមានប្រសិទ្ធភាព ។

នីតិវិធីនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៧.-**

ក្នុងករណីដែលមានការរំលោភអំណាចកើតមានឡើង នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវមានភារកិច្ចរាយការណ៍ជាលាយល័ក្ខណ៍អក្សរជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ការរំលោភអំណាចកើតឡើងនៅពេលដែលអ្នកជាប់ឆ្នោតណាម្នាក់ ឬ អ្នកដែលបានទទួលការតែងតាំងនៅក្នុងក្រសួង ស្ថាប័ន ឬ ភ្នាក់ងាររបស់រដ្ឋ ឬ ក្នុងក្រុមប្រឹក្សាណាមួយ ឬ ជនណាម្នាក់ ដែលបានប្រព្រឹត្តអំពើដោយចេតនា ហើយដែលមិនអាចធ្វើយុត្តិកម្មបានដូចជា :

-ការប្រើប្រាស់តួនាទី ឬ អំណាចរបស់ខ្លួន ដើម្បីកេងប្រវ័ញ្ច ឬ ធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬ ក្រុមមនុស្ស ឬ ទ្រព្យសម្បត្តិសាធារណៈ ឬ ធនធានសាធារណៈណាមួយ

-ការមិនបានប្រើប្រាស់តួនាទី ឬ អំណាចរបស់ខ្លួន ដើម្បីទប់ស្កាត់ជនម្នាក់ទៀតដែលស្ថិតនៅក្រោមអំណាច ឬ ការត្រួតពិនិត្យរបស់ខ្លួន នៅពេលដែលខ្លួនបានដឹងអំពីកំហុសឆ្គងរបស់ជននោះ ដែលបានកេងប្រវ័ញ្ច ឬ ធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬ ក្រុមមនុស្ស ឬ ទ្រព្យសម្បត្តិសាធារណៈ ឬ ធនធានសាធារណៈ ។

**មាត្រា ៤៩.-**

ការរំលោភអំណាច រួមមានសកម្មភាពណាមួយ ដូចខាងក្រោម :

-ការរំលោភសិទ្ធិស្របច្បាប់ ឬ សិទ្ធិមនុស្សរបស់ជនណាម្នាក់

-ការកាន់កាប់ ឬ ការរឹបអូសទ្រព្យសម្បត្តិសាធារណៈ ឬ ទ្រព្យសម្បត្តិឯកជន និងធនធានធម្មជាតិមកធ្វើជារបស់ខ្លួនដោយខុសច្បាប់

-ការធ្វើឱ្យអន្តរាយដល់បរិស្ថាន ធនធានធម្មជាតិ

-ការដកយកថវិកា ឬ ទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់ ឬ ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមិនត្រឹមត្រូវ

-ការស្នើសុំ ឬ ការទទួលប្រាក់ ឬ រង្វាន់អ្វីមួយជាថ្នូរនឹងការធ្វើ ឬ មិនធ្វើកិច្ចការណាមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការរបស់ជននោះ ហើយដែលការចំណាយ ឬ រង្វាន់ នោះមិនបានកំណត់នៅក្នុងច្បាប់

-ភាពមិនប្រក្រតីនៅក្នុងការអនុវត្តច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬប្រកាស

-ភាពមិនប្រក្រតីនៅក្នុងការអនុវត្តដីការបស់ក្រុមប្រឹក្សា

-ការធ្វើសេចក្ដីសម្រេចនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ផលប្រយោជន៍គ្រួសាររបស់ខ្លួន ។

## មាត្រា ៥០.-

ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំដែលពាក់ព័ន្ធ :

-ដីកា និងសេចក្ដីសម្រេចនានាដែលបានដាក់ចេញ

-សកម្មភាពនានាដែលបានអនុវត្ត

-របាយការណ៍ហិរញ្ញវត្ថុ

-ការវាយតម្លៃការបំពេញការងាររបស់គណៈអភិបាល និងបុគ្គលិកក្រុមប្រឹក្សា

-លទ្ធផលនៃការតាមដាន និងវាយតម្លៃ ដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ

-វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សា

ក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំខាងលើនេះ មិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំ ។

## មាត្រា ៥១.-

ក្រុមប្រឹក្សា ត្រូវបង្កលក្ខណៈងាយស្រួលដល់សាធារណជនក្នុងការជូនព័ត៌មានជា

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

សាធារណៈអំពីរបាយការណ៍ របៀបវារៈប្រជុំ កំណត់ហេតុប្រជុំ ដីកា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសទាំងអស់ដែលពាក់ព័ន្ធនឹងក្រុមប្រឹក្សា និងឯកសារដទៃទៀតរបស់ក្រុមប្រឹក្សា ។

**មាត្រា ៥២.-**

ក្រុមប្រឹក្សានីមួយៗត្រូវមានក្តារព័ត៌មានជាសាធារណៈ ឬ មធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅការិយាល័យកណ្តាលរបស់ខ្លួន និងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈទាំងនោះ ។

## ផ្នែកទី ៣
## ដីការបស់ក្រុមប្រឹក្សា

**មាត្រា ៥៣.-**

ដីកា គឺជាវិធានខាងផ្លូវច្បាប់ដែលបានអនុម័តដោយក្រុមប្រឹក្សា ។

យោងតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួន តាមការធ្វើសេចក្តីសម្រេចដើម្បីដាក់ចេញនូវដីកាតាមការចាំបាច់ ។

**មាត្រា ៥៤.-**

ដីការបស់ក្រុមប្រឹក្សា មានវិសាលភាពដើម្បីកំណត់ ដើម្បីហាមឃាត់ ឬ ដើម្បីត្រួតពិនិត្យលើសកម្មភាព លើនីតិវិធី ឬ លើកិច្ចការណាមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ ភារកិច្ច និងធនធានរបស់ក្រុមប្រឹក្សារួមមាន :

-តួនាទី ភារកិច្ច សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

-មុខងារ ឬ ភារកិច្ច ដែលប្រគល់ឱ្យក្រុមប្រឹក្សា

-មុខងារ ឬ ភារកិច្ច ដែលបានធ្វើប្រតិភូកម្មទៅឱ្យក្រុមប្រឹក្សា ក្នុងករណីដែលការធ្វើប្រតិភូកម្មនោះ មិនបានដកចេញនូវសិទ្ធិអំណាចខ្លះ ឬ ទាំងអស់ដើម្បីដាក់ចេញដីកា ឬ កិច្ចការណាមួយដែលច្បាប់នេះ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសដទៃទៀត តម្រូវឱ្យក្រុមប្រឹក្សាដាក់ចេញដីកា ។

**មាត្រា ៥៥.–**

ដីកាដែលដាក់ចេញដោយក្រុមប្រឹក្សា ត្រូវប្រតិបត្តិ និងអនុវត្តនៅក្នុងដែនសមត្ថកិច្ចទាំងមូលរបស់ខ្លួន លើកលែងតែដីកាចែងផ្សេងពីនេះ ឬ លើកលែងតែច្បាប់ណាមួយបានតម្រូវឱ្យដកចេញពីដីកានូវតំបន់ដែលបានកំណត់ព្រំប្រទល់ច្បាស់លាស់ ។

**មាត្រា ៥៦.–**

ដីកាដែលក្រុមប្រឹក្សាបានអនុម័តរួច ត្រូវចូលជាធរមាននៅថ្ងៃដែលក្រុមប្រឹក្សាប្រកាសផ្សាយដីកានោះ ។

ដីកា អាចកំណត់យកកាលបរិច្ឆេទណាមួយនាពេលអនាគត សម្រាប់ការចូលជាធរមាននូវដីកាទាំងមូល ឬ ផ្នែកខ្លះនៃដីកា ។

ដីកា មិនអាចមានប្រតិសកម្ម និងមិនអាចចូលជាធរមានមុនពេលដែលដីកាត្រូវបានអនុម័ត និងប្រកាសផ្សាយនោះឡើយ ។

**មាត្រា ៥៧.–**

ដីកា ដែលចែងផ្ទុយពីបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ដីកានោះនឹងមិនមានសុពលភាពបានឡើយ ។

**មាត្រា ៥៨.–**

ដីកាណាមួយដែលធ្វើឡើងដោយមានការរើសអើងក្នុងន័យជាអវិជ្ជមាន ឬ អនុវត្តចំពោះតែបុគ្គលណាម្នាក់ ឬ ក្រុមមនុស្សណាមួយ ដោយផ្អែកលើកត្តាជាតិសាសន៍ សាសនា ភេទ អាយុ ពណ៌សម្បុរ ជាតិ ឬ ជាតិកំណើត ឬ អសមត្ថភាពខាងស្មារតី ឬ ខាងកាយសម្បទា ដីកានោះមិនមានសុពលភាពបានឡើយ ។

**មាត្រា ៥៩.–**

ដីកាអាចបង្កើតបទប្បញ្ញត្តិសម្រាប់ការពិន័យជាប្រាក់ចំពោះការប្រព្រឹត្តល្មើស ឬ ការមិនគោរពតាមបទប្បញ្ញត្តិមួយ ឬ ច្រើននៃដីកានោះបាន ។

បែបបទ នីតិវិធីនៃការរៀបចំបទប្បញ្ញត្តិ សម្រាប់ការពិន័យជាប្រាក់ដោយដីការបស់

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យឡើងវិញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីស្នើធ្វើវិសោធនកម្ម ឬ ដាក់ចេញនូវលិខិតបទដ្ឋានថ្មី ឱ្យសមស្របសម្រាប់ទ្រទ្រង់ដល់គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលចែងក្នុងច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៨៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៨៦.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០០៨

៣៧៧.០៥០៥.៥៩៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខៈ ៥៥៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៨៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅថ្នាក់ស្រុក។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីមុខងារ រចនាសម្ព័ន្ធ តួនាទី ភារកិច្ច ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលស្រុក។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរដ្ឋបាលស្រុកទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## មុខងាររបស់រដ្ឋបាលស្រុក

**មាត្រា ៤.-**

រដ្ឋបាលស្រុកត្រូវបំពេញមុខងារតាមការកំណត់នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមុខងារដែលបានផ្ទេរពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

មុខងារពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងវិស័យនីមួយៗត្រូវបានប្រគល់ និងប្រតិភូកម្មទៅឱ្យរដ្ឋបាលស្រុកដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ លើកលែងតែមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡារបស់រដ្ឋបាលស្រុកនានានៃខេត្តបាត់ដំបងមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យនេះ។

ក្រៅពីមុខងារដែលបានកំណត់ក្នុងវាក្យខ័ណ្ឌទី១ និងវាក្យខ័ណ្ឌទី២នៃមាត្រានេះ រដ្ឋបាលស្រុក បំពេញមុខងារជាភ្នាក់ងាររបស់ក្រសួង ស្ថាប័ន រដ្ឋបាលខេត្ត មន្ទីរ និងអង្គភាពនានាតាមការកំណត់ ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬតាមកិច្ចព្រមព្រៀងរវាងក្រសួង ស្ថាប័ន រដ្ឋបាលខេត្ត មន្ទីរ និង អង្គភាពនានាជាមួយរដ្ឋបាលស្រុក។

**មាត្រា ៥.-**

មុខងារផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលស្រុករួមមានមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស។

រដ្ឋបាលស្រុកត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាកាតព្វកិច្ច នានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយផ្អែកតាមគោលការណ៍ នីតិវិធី ស្តង់ដាសេវា និង ធនធានដែលបានផ្ទេរមានភ្ជាប់លក្ខខណ្ឌ ព្រមទាំងអាចប្រើប្រាស់ធនធានរបស់ខ្លួន ឬធនធានដែល កៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត ដើម្បីអនុវត្តមុខងារជាកាតព្វកិច្ចទាំងនោះឱ្យកាន់តែមាន ប្រសិទ្ធភាព។

គោលការណ៍ នីតិវិធី និងស្តង់ដាសេវាសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ច ត្រូវរៀបចំ និងកំណត់ដោយក្រសួង ស្ថាប័ននៃវិស័យនីមួយៗ។

**មាត្រា ៦.-**

រដ្ឋបាលស្រុកមានស្វ័យភាពក្នុងការសម្រេចជ្រើសរើស ឬមិនជ្រើសរើសយកមុខងារជាជម្រើស ណាមួយមកអនុវត្ត ផ្អែកតាមតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋបាលស្រុកត្រូវគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសក្នុងកម្រិតអតិបរមានៃលទ្ធភាព និងធនធានឆន្ទានុសិទ្ធិរបស់ខ្លួន និងធនធានដែលរដ្ឋបាលស្រុកកៀរគរបានពីប្រភពស្របច្បាប់។

រដ្ឋបាលស្រុកមានសិទ្ធិសម្រេចអំពីរបៀបគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើស ដោយអនុលោមតាមបទដ្ឋាន និងនីតិវិធីដែលមានចែងក្នុងច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស ឬ លិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងករណីដែលរដ្ឋបាលស្រុកសម្រេចក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជា ជម្រើសដែលមិនធ្លាប់បានគ្រប់គ្រង ចាត់ចែង និងអនុវត្តពីមុនមកដោយក្រសួង ស្ថាប័ន រដ្ឋបាលស្រុក មានសិទ្ធិសម្រេច ឬស្នើសុំមកក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់អំពីបទដ្ឋាន នីតិវិធី និងធនធាន សម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងនោះ។

ក្រសួង ស្ថាប័នអាចផ្តល់ការណែនាំ ការគាំទ្រ និងឬធនធានទៅឱ្យរដ្ឋបាលស្រុកសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើស។

**មាត្រា ៧.-**

ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវពិនិត្យមើលឡើងវិញនូវមុខងារនានារបស់ខ្លួន ដើម្បីបន្តផ្ទេរមុខងារសមស្របទៅឱ្យរដ្ឋបាលស្រុក ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។

**មាត្រា ៨.-**

ក្រសួងមហាផ្ទៃមានតួនាទី ភារកិច្ចដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល គាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃរដ្ឋបាលស្រុកដើម្បីធានាឱ្យរដ្ឋបាលស្រុកគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងាររបស់ខ្លួនបានត្រឹមត្រូវ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា និងអនុក្រឹត្យនេះ។

## ជំពូកទី៣

## ការបង្កើត តួនាទី ភារកិច្ច និងរបៀបរបបការងារនៃការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុក

### ផ្នែកទី១

### ការបង្កើតការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុក

**មាត្រា ៩.-**

រដ្ឋបាលស្រុកនីមួយៗត្រូវមានការិយាល័យ និងអង្គភាពមួយចំនួនជាចំណុះដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- អង្គភាពលទ្ធកម្ម
- ការិយាល័យគ្រប់គ្រងធនធានមនុស្ស
- ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់
- ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង
- ការិយាល័យលេខាធិការក្រុមប្រឹក្សា
- ការិយាល័យអប់រំ យុវជន និងកីឡា
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល
- ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
- ការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន
- ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម
- ការិយាល័យច្រកចេញចូលតែមួយ។

**មាត្រា ១០.-**

អង្គការលេខរបស់រដ្ឋបាលស្រុកមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា ១១.-**

ការិយាល័យ និងអង្គភាពនីមួយៗចំណុះរដ្ឋបាលស្រុកត្រូវដឹកនាំដោយប្រធានមួយ (០១)រូប និងមានអនុប្រធានយ៉ាងច្រើនចំនួនពីរ (០២)រូបជាជំនួយការ។

ការតែងតាំងប្រធាន និងអនុប្រធានការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុកត្រូវអនុវត្ត

តាមលក្ខខណ្ឌនានាដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ និងតាមគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិជាធរមាន។

ការតែងតាំងមុខតំណែងគ្រប់គ្រងខាងលើនេះត្រូវផ្ដល់អាទិភាពដល់បុគ្គលិកជាស្ត្រី។

**មាត្រា ១២.-**

រដ្ឋបាលស្រុកត្រូវមានចំនួនបុគ្គលិកសមស្របតាមការិយាល័យ និងអង្គភាពនីមួយៗ ដោយផ្អែកតាមស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ ទំហំការងារ និងធនធានរបស់រដ្ឋបាលស្រុកនីមួយៗ។

រដ្ឋបាលស្រុកត្រូវមានចំនួនបុគ្គលិកជាស្ត្រីសមស្រប ផ្អែកតាមតម្រូវការរបស់រដ្ឋបាលស្រុកនីមួយៗ និងផ្អែកតាមគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ព្រមទាំងលើកទឹកចិត្តដល់ជនពិការ។

ក្រសួងមុខងារសាធារណៈ សហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលស្រុក ក្រោមការដឹកនាំសម្របសម្រួលរបស់ គ.ជ.អ.ប. ត្រូវកំណត់ចំនួនបុគ្គលិកសម្រាប់រដ្ឋបាលស្រុកនីមួយៗ និងផ្ដល់ការគាំទ្រដល់រដ្ឋបាលស្រុកក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់រដ្ឋបាលស្រុក។

**មាត្រា ១៣.-**

ក្រសួងមុខងារសាធារណៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការដឹកនាំសម្របសម្រួលពី គ.ជ.អ.ប ត្រូវធានាថាបុគ្គលិកជាមន្ត្រីរាជការស៊ីវិលរបស់រដ្ឋបាលស្រុក ត្រូវបានដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈដោយឡែកនៃអង្គនីមួយៗ ដោយមានការលើកទឹកចិត្តទាំងមុខតំណែងគ្រប់គ្រង មុខតំណែងវិជ្ជាជីវៈ កម្រិតមុខតំណែង និងលាភការផ្សេងៗទៀតដល់បុគ្គលិករបស់រដ្ឋបាលស្រុក។

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលរបស់រដ្ឋបាលស្រុកត្រូវស្ថិតនៅក្នុងអង្គណាមួយស្របតាមមុខជំនាញវិជ្ជាជីវៈ និងបទពិសោធន៍ការងាររបស់បុគ្គលិកម្នាក់ៗដែលមានកំណត់នៅក្នុងលក្ខន្តិកៈដោយឡែកនៃអង្គនីមួយៗ។

**មាត្រា ១៤.-**

រដ្ឋបាលស្រុកអាចស្នើបង្កើត លុប និងកែសម្រួលការិយាល័យ និងអង្គភាពនានាផ្អែកតាមទំហំការងារ សក្ដានុពលសេដ្ឋកិច្ច និងឬតម្រូវការជាអាទិភាពរបស់រដ្ឋបាលស្រុកនីមួយៗ មកក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងលើកយោបល់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

ការស្នើបង្កើត លុប និងកែសម្រួលការិយាល័យ និងអង្គភាពនានាត្រូវផ្អែកតាមលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យដែលបានកំណត់ដោយក្រសួងមហាផ្ទៃ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

ការិយាល័យ និងអង្គភាពដែលបង្កើតបន្ថែមមិនត្រូវមានមុខងារ តួនាទី ភារកិច្ចត្រួតគ្នាជាមួយការិយាល័យ និងអង្គភាពដែលបានបង្កើតតាមមាត្រា៩នៃអនុក្រឹត្យនេះ។

ក្នុងករណីមានការបង្កើតការិយាល័យ និងអង្គភាពបន្ថែមដោយបំបែកចេញពីការិយាល័យ និងឬអង្គភាពណាមួយ មុខងារ តួនាទី ភារកិច្ចរបស់ការិយាល័យ និងអង្គភាពបង្កើតថ្មីនេះត្រូវផ្ទេរចេញពីការិយាល័យ និងអង្គភាពដើម។



ᴋ

## ផ្នែកទី២

## តួនាទី ភារកិច្ចរបស់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុក

**មាត្រា ១៥.-**

**ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងាររដ្ឋបាល និងហិរញ្ញវត្ថុ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ព័ត៌មាន ពិធីការ ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
- ការងារអគ្រានុកូលដ្ឋាន
- ការគ្រប់គ្រង និងការថែរក្សាត្រា ឯកសារ លិខិតបទដ្ឋាននានារបស់រដ្ឋបាលស្រុក
- ការពិនិត្យ និងការកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក
- ការរៀបចំនីតិវិធីរដ្ឋបាល និងនីតិវិធីហិរញ្ញវត្ថុសម្រាប់អង្គភាពរបស់រដ្ឋបាលស្រុកផ្អែកតាមគោលការណ៍ និងបទប្បញ្ញត្តិជាធរមាន
- ការងារហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិរបស់រដ្ឋបាលស្រុក
- ការងារសណ្តាប់ធ្នាប់សាធារណៈ
- ការងាររបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាលស្រុក
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

**មាត្រា ១៦.-**

**អង្គភាពលទ្ធកម្ម**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារលទ្ធកម្មសាធារណៈ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- ការរៀបចំឯកសារដេញថ្លៃ ការរៀបចំ និងការផ្សព្វផ្សាយអំពីកិច្ចលទ្ធកម្ម ការផ្តល់ឯកសារដេញថ្លៃ ការទទួលសំណើដេញថ្លៃ ការរៀបចំទុកដាក់ឯកសារសំណើដេញថ្លៃ ការរៀបចំទីកន្លែង និងការរៀបចំបើកសំណើដេញថ្លៃ
- ការរៀបចំរបាយការណ៍ និងកំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ
- ការរៀបចំ និងការសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ការរៀបចំកិច្ចសន្យា និងលិខិតជូនដំណឹងអំពីការប្រគល់កិច្ចសន្យា
- ការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ
- ការតាមដានការអនុវត្តកិច្ចសន្យា និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។



k

**មាត្រា ១៧.-**

**ការិយាល័យគ្រប់គ្រងធនធានមនុស្ស**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារគ្រប់គ្រងធនធានមនុស្ស និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់រដ្ឋបាលស្រុក
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលស្រុក
- ការគ្រប់គ្រងបុគ្គលិកផ្សេងទៀតតាមការផ្ទេរសិទ្ធិអំណាចពីរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

**មាត្រា ១៨.-**

**ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារផែនការ និងគាំទ្រឃុំ សង្កាត់ក្នុងស្រុក និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលស្រុក
- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលស្រុក
- ការងារស្ថិតិប្រជាជន
- ការគាំទ្រ ការសម្របសម្រួល និងការតាមដាន ត្រួតពិនិត្យ វាយតម្លៃរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុកលើការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល និងគម្រោងនានារបស់រដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក
- ការណែនាំ និងការជំរុញការប្រមូលទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងទិន្នន័យថ្នាក់ស្រុកតាមការកំណត់
- ការគ្រប់គ្រង និងការស្វែងរកការគាំទ្រការកែច្នៃទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងទិន្នន័យថ្នាក់ស្រុក
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងក្រុមប្រឹក្សាឃុំ សង្កាត់តាមតម្រូវការចាំបាច់
- ការគាំទ្របច្ចេកទេសលើការងាររដ្ឋបាល និងហិរញ្ញវត្ថុដល់រដ្ឋបាលឃុំ សង្កាត់
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់រដ្ឋបាលឃុំ សង្កាត់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

**មាត្រា ១៩.-**

**ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការត្រួតពិនិត្យការបំពេញការងាររបស់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុក និងមានភារកិច្ចចាត់ចែង

លើការងារដូចខាងក្រោម៖

- ការត្រួតពិនិត្យលើការអនុវត្តតាមច្បាប់ ដីកា លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវានានាដែលបានកំណត់ជាធរមាន
- ការត្រួតពិនិត្យលើការងាររដ្ឋបាល ការងារបុគ្គលិក ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលស្រុក
- ការត្រួតពិនិត្យការអនុវត្តវិន័យ បទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌ និងម៉ោងបំពេញការងាររបស់បុគ្គលិករដ្ឋបាលស្រុក
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

**មាត្រា ២០.-**

**ការិយាល័យលេខាធិការក្រុមប្រឹក្សា**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារលេខាធិការដ្ឋានជូនក្រុមប្រឹក្សាស្រុក និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សា
- ការរៀបចំកំណត់ហេតុនៃកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា
- ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នានារបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង ការថែរក្សា និងការទុកដាក់ឯកសារនានារបស់ក្រុមប្រឹក្សា
- ការបិទផ្សាយ និងការផ្សព្វផ្សាយនូវសេចក្តីសម្រេច និងឯកសារនានារបស់ក្រុមប្រឹក្សា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សា និងអភិបាលស្រុក។

**មាត្រា ២១.-**

**ការិយាល័យអប់រំ យុវជន និងកីឡា**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារអប់រំ យុវជន និងកីឡា និងមានភារកិច្ចគ្រប់គ្រង គាំទ្រ សម្របសម្រួល និងតាមដាន ត្រួតពិនិត្យវាយតម្លៃលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការអប់រំកុមារតូច
- ការអប់រំបឋមសិក្សា
- ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
- ការអប់រំក្រៅប្រព័ន្ធ
- ការអភិវឌ្ឍយុវជន
- ការអប់រំកាយ និងកីឡា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

**មាត្រា ២២.-**

**ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យ រដ្ឋបាលស្រុកលើការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល និងមានភារកិច្ចចាត់ចែង

លើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងាររៀបចំដែនដី និងនគរូបនីយកម្ម
- ការងារភូមិបាល
- ការងារសំណង់
- ការងារលំនៅឋាន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

**មាត្រា ២៣.-**

**ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន**មានតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារនីតិកម្ម និងការសម្រុះសម្រួលវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការ និងមានភារកិច្ចចាត់ចែងលើការងារមួយចំនួនដូចខាងក្រោម៖

- ការសិក្សាស្រាវជ្រាវ ការរៀបចំ និងការផ្តល់យោបល់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋបាលស្រុក
- ការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដល់មន្ត្រី បុគ្គលិក និងប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលស្រុក
- ការផ្តល់ប្រឹក្សាយោបល់ផ្លូវច្បាប់ដល់ប្រជាពលរដ្ឋ
- ការរៀបចំការបណ្តុះបណ្តាលជំនាញសម្រុះសម្រួល និងច្បាប់ដល់រដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក
- ការទទួលពាក្យបណ្តឹង និងការសម្រុះសម្រួលវិវាទនៅមូលដ្ឋានដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលស្រុកស្របតាមច្បាប់កំណត់
- ការពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្តីសម្រេចនានារបស់រដ្ឋបាលឃុំ សង្កាត់ក្នុងស្រុកតាមគោលការណ៍កំណត់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក ។

**មាត្រា ២៤.-**

**ការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន**មានតួនាទីធ្វើជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារកសិកម្ម រុក្ខប្រមាញ់ និងនេសាទ
- ការងារធនធានទឹក
- ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ
- ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

**មាត្រា ២៥.-**

**ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការអភិវឌ្ឍសេដ្ឋកិច្ច ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសហគមន៍ និងមានភារកិច្ចចាត់ចែងមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារសាធារណការ និងដឹកជញ្ជូន
- ការងារឧស្សាហកម្ម និងសិប្បកម្ម
- ការងាររ៉ែ និងថាមពល
- ការងារទេសចរណ៍
- ការងារអភិវឌ្ឍន៍ជនបទ
- ការងារពាណិជ្ជកម្ម
- ការងារប្រៃសណីយ៍ និងទូរគមនាគមន៍
- ការងារអភិវឌ្ឍន៍សហគមន៍
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

**មាត្រា ២៦.-**

**ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារសង្គមកិច្ច និងសុខុមាលភាពសង្គម និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ការងារសុខាភិបាល
- ការងារកិច្ចការនារី
- ការងារធម្មការ និងសាសនា
- ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការងារវប្បធម៌ និងវិចិត្រសិល្បៈ
- ការងារគ្រោះមហន្តរាយ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

**មាត្រា ២៧.-**

**ការិយាល័យច្រកចេញចូលតែមួយ**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារផ្តល់សេវារដ្ឋបាលនានា និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការទទួល និងការផ្តល់សេវារដ្ឋបាលនានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលស្រុក
- ការប្រមូល និងការបង់កម្រៃសេវារដ្ឋបាលតាមគោលការណ៍ និងនីតិវិធីកំណត់
- ការផ្តល់ព័ត៌មាននានា និងការផ្សព្វផ្សាយជាសាធារណៈពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាល

- ការទុកដាក់ ការថែរក្សា និងការគ្រប់គ្រងឯកសារនានាពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាល
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

**មាត្រា ២៨.-**

មុខងាររង ឬសកម្មភាពជាក់លាក់នៃមុខងារនីមួយៗរបស់រដ្ឋបាលស្រុកពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានតាមវិស័យនានាមានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ផ្នែកទី៣
## របៀបរបបការងាររបស់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុក

**មាត្រា ២៩.-**

ការិយាល័យ និងអង្គភាពនីមួយៗត្រូវបំពេញមុខងារស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

រដ្ឋបាលស្រុកត្រូវរៀបចំឱ្យមានលក្ខខណ្ឌការងារជាក់លាក់សម្រាប់បុគ្គលិកម្នាក់ៗ ដោយផ្អែកតាមតួនាទី ភារកិច្ចរបស់ការិយាល័យ និងអង្គភាពនីមួយៗ និងគោលការណ៍ណែនាំជាធរមាន។

បុគ្គលិកម្នាក់ៗនៃការិយាល័យ និងអង្គភាពនីមួយៗត្រូវបំពេញតួនាទី ភារកិច្ចរបស់ខ្លួនស្របតាមលក្ខខណ្ឌការងារដែលបានកំណត់។

ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃដោយសហការជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងស្ថាប័នពាក់ព័ន្ធអាចផ្តល់ការណែនាំបន្ថែមអំពីការរៀបចំលក្ខខណ្ឌការងារខាងលើនេះ។

**មាត្រា ៣០.-**

រដ្ឋបាលស្រុកអាចរៀបចំឱ្យមានភ្នាក់ងារតាមការិយាល័យ និងអង្គភាពនីមួយៗសម្រាប់ទទួលបន្ទុកតាមកិច្ចការ ឬវិស័យជាក់លាក់ណាមួយ ឬមួយចំនួនតាមស្ថានភាពនៃស្រុកនីមួយៗ។

ការរៀបចំភ្នាក់ងារទទួលបន្ទុកតាមកិច្ចការ ឬវិស័យជាក់លាក់ណាមួយ ឬមួយចំនួនត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋបាលស្រុក។

**មាត្រា ៣១.-**

ការិយាល័យ និងអង្គភាពនីមួយៗត្រូវរៀបចំផែនការសកម្មភាព និងរបាយការណ៍ជាទៀងទាត់តាមគោលការណ៍កំណត់ ព្រមទាំងត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់ ដើម្បីត្រួតពិនិត្យលើការងារដែលបានអនុវត្ត កំណត់បញ្ហាប្រឈមនានាដែលត្រូវដោះស្រាយ និងកំណត់ទិសដៅដែលត្រូវអនុវត្តបន្ត។

**មាត្រា ៣២.-**

ប្រធានការិយាល័យ និងអង្គភាពនីមួយៗត្រូវធានាថាបុគ្គលិកក្នុងការិយាល័យ និងអង្គភាពរបស់ខ្លួនមកបំពេញការងារជាទៀងទាត់ អនុវត្តតួនាទី ភារកិច្ចតាមលក្ខខណ្ឌការងារ គោរពតាមបទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌វិជ្ជាជីវៈដែលបានកំណត់។

រដ្ឋបាលស្រុកត្រូវរៀបចំការចុះវត្តមានបុគ្គលិកប្រចាំថ្ងៃ និងកំណត់អំពីបទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករបស់រដ្ឋបាលស្រុក។

**មាត្រា ៣៣.-**

ប្រធានការិយាល័យ និងអង្គភាពនីមួយៗត្រូវគ្រប់គ្រង ចាត់ចែង និងអនុវត្តការងារពាក់ព័ន្ធនឹងបុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងការងាររដ្ឋបាលស្របតាមនីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងលក្ខខណ្ឌការងារដែលបានកំណត់។

**មាត្រា ៣៤.-**

រដ្ឋបាលស្រុកត្រូវរៀបចំរបៀបរបបធ្វើការងារលម្អិតសម្រាប់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុក ដើម្បីធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងាររបស់ខ្លួន ដោយផ្អែកតាមគោលការណ៍នានាដែលបានកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៤

## ការិយាល័យប្រជាពលរដ្ឋ

**មាត្រា ៣៥.-**

ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុកដែលត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបំពេញមុខងារ តួនាទី ភារកិច្ច របៀបរបបការងារ និងបែបបទ នីតិវិធីស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៥

## ទំនាក់ទំនងការងារ

### ផ្នែកទី១

### ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាព

**មាត្រា ៣៦.-**

ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលមានតួនាទីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ បទដ្ឋានបច្ចេកទេស និងស្តង់ដាសេវាសម្រាប់ជាមូលដ្ឋានតម្រង់ទិសដល់រដ្ឋបាលស្រុកក្នុងការអនុវត្តមុខងារតាមវិស័យនីមួយៗ។

ក្រសួង ស្ថាប័ននីមួយៗទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាល និងរដ្ឋសភាអំពីវិស័យដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋបាលស្រុកមានតួនាទីប្រតិបត្តិមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងបទដ្ឋានបច្ចេកទេសផ្អែកតាមស្ថានភាពជាក់ស្តែងរបស់ស្រុកនីមួយៗ ដើម្បីចូលរួមសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅនៃវិស័យនីមួយៗ។

**មាត្រា ៣៧.-**

ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារួមមាន៖

- ក្រសួង ស្ថាប័នមានតួនាទីត្រួតពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្ដីសម្រេចនានារបស់រដ្ឋបាលស្រុក ស្របតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានាមានតួនាទីផ្ដល់ការគាំទ្របច្ចេកទេស ការណែនាំ ការធ្វើអន្តរាគមន៍ និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលស្រុកតាមការចាំបាច់
- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានាមានតួនាទីតាមដាន ត្រួតពិនិត្យ វាយតម្លៃ ធ្វើអធិការកិច្ច និងធ្វើសវនកម្មលើការបំពេញការងាររបស់រដ្ឋបាលស្រុកពាក់ព័ន្ធតែនឹងវិស័យរបស់ក្រសួង ស្ថាប័នសាមីនីមួយៗស្របតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានាអាចពិគ្រោះយោបល់ និងធ្វើកិច្ចសហប្រតិបត្តិការរួមគ្នាលើកិច្ចការចាំបាច់មួយចំនួនជាមួយរដ្ឋបាលស្រុក ដើម្បីធានាលើកកម្ពស់ប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន
- រដ្ឋបាលស្រុកមានតួនាទីធ្វើសេចក្ដីរាយការណ៍ជាទៀងទាត់ជូនក្រសួង ស្ថាប័នតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- កិច្ចការទំនាក់ទំនងផ្សេងៗទៀតតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមតម្រូវការចាំបាច់។

**មាត្រា ៣៨.-**

ក្រសួង ស្ថាប័ននានាត្រូវសហការសម្របសម្រួលជាមួយ គ.ជ.អ.ប. និងក្រសួងមហាផ្ទៃដើម្បីអនុវត្តបទប្បញ្ញត្តិនានានៃអនុក្រឹត្យនេះដែលពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នសាមីនីមួយៗ និងកិច្ចការដទៃទៀតដែលពាក់ព័ន្ធនឹងរដ្ឋបាលស្រុក។

**មាត្រា ៣៩.-**

ក្នុងករណីមិនចុះសម្រុងគ្នារវាងក្រសួង ស្ថាប័ននានា ជាមួយរដ្ឋបាលស្រុក គ.ជ.អ.ប.ត្រូវសម្របសម្រួលដោះស្រាយផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

## ផ្នែកទី២

## ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលខេត្ត

**មាត្រា ៤០.-**

ក្នុងនាមជានីតិបុគ្គលនៃនីតិសាធារណៈ រដ្ឋបាលស្រុក និងរដ្ឋបាលខេត្តមានស្វ័យភាព និងមានប្រព័ន្ធអភិបាលកិច្ចដោយឡែកៗពីគ្នា លើកលែងតែកិច្ចការមួយចំនួនដែលកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តតម្រូវឱ្យរដ្ឋបាលស្រុកអនុវត្តកិច្ចការទាំងនោះដោយត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះរដ្ឋបាលខេត្ត។

**មាត្រា ៤១.-**

ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលខេត្តរួមមាន៖

- រដ្ឋបាលខេត្តមានតួនាទីត្រួតពិនិត្យនីត្យានុកូលភាពរាល់ដីកា និងសេចក្ដីសម្រេចនានារបស់រដ្ឋបាលស្រុក តាមការធ្វើប្រតិភូកម្មអំណាចពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន
- រដ្ឋបាលខេត្តមានតួនាទីផ្ដល់អនុលោមភាពទៅលើកិច្ចការជាក់លាក់មួយចំនួនរបស់រដ្ឋបាលស្រុកតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រដ្ឋបាលខេត្តមានតួនាទីផ្ដល់ការគាំទ្របច្ចេកទេស ការធ្វើអន្តរាគមន៍ និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលស្រុក តាមការស្នើសុំរបស់រដ្ឋបាលស្រុក និងតាមការចាំបាច់
- រដ្ឋបាលខេត្តមានតួនាទីតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធ្វើអធិការកិច្ចលើការអនុវត្តមុខងាររបស់រដ្ឋបាលស្រុកតាមការធ្វើប្រតិភូកម្មអំណាចពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន
- គណៈអភិបាលខេត្តត្រូវធ្វើការដឹកនាំ ណែនាំ សម្របសម្រួលដល់គណៈអភិបាលស្រុក ដើម្បីធានារក្សាសណ្ដាប់ធ្នាប់ សន្តិសុខសាធារណៈ ការគោរពសិទ្ធិមនុស្ស ការគោរពច្បាប់ នៅក្នុងដែនសមត្ថកិច្ចរបស់ស្រុកនីមួយៗ
- រដ្ឋបាលខេត្តអាចពិគ្រោះយោបល់ និងធ្វើកិច្ចសហប្រតិបត្តិការរួមគ្នាលើកិច្ចការចាំបាច់មួយចំនួនជាមួយរដ្ឋបាលស្រុក ដើម្បីធានាលើកកម្ពស់ប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន
- រដ្ឋបាលស្រុកមានតួនាទីធ្វើរបាយការណ៍ជាទៀងទាត់ជូនរដ្ឋបាលខេត្តដើម្បីបូកសរុប និងរាយការណ៍ជូនក្រសួង ស្ថាប័ន តាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- កិច្ចការទំនាក់ទំនងផ្សេងៗទៀតតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមតម្រូវការចាំបាច់។

**មាត្រា ៤២.-**

ក្នុងករណីមិនចុះសម្រុងគ្នារវាងរដ្ឋបាលខេត្តជាមួយរដ្ឋបាលស្រុក ក្រសួងមហាផ្ទៃត្រូវសម្របសម្រួលដោះស្រាយផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៣

## ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក

**មាត្រា ៤៣.-**

ក្នុងនាមជានីតិបុគ្គលនៃនីតិសាធារណៈ រដ្ឋបាលស្រុក និងរដ្ឋបាលឃុំ សង្កាត់មានស្វ័យភាព និងមានប្រព័ន្ធអភិបាលកិច្ចដោយឡែកៗពីគ្នា លើកលែងតែកិច្ចការមួយចំនួនដែលកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តតម្រូវឱ្យរដ្ឋបាលឃុំ សង្កាត់អនុវត្តកិច្ចការទាំងនោះដោយត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះរដ្ឋបាលស្រុក។

**មាត្រា ៤៤.-**

រដ្ឋបាលស្រុកមានទំនាក់ទំនងការងារជាមួយរដ្ឋបាលឃុំ សង្កាត់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយធានានូវសិទ្ធិអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ ដូចមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុករួមមាន៖

- រដ្ឋបាលស្រុកមានតួនាទីត្រួតពិនិត្យនីត្យានុកូលភាពរាល់ដីកា និងសេចក្តីសម្រេចនានារបស់រដ្ឋបាលឃុំ សង្កាត់ តាមការធ្វើប្រតិភូកម្មអំណាចពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន
- រដ្ឋបាលស្រុកមានតួនាទីផ្តល់ការគាំទ្របច្ចេកទេស ការណែនាំ ការធ្វើអន្តរាគមន៍ និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលឃុំ សង្កាត់តាមការស្នើសុំរបស់រដ្ឋបាលឃុំ សង្កាត់ និងតាមការចាំបាច់
- រដ្ឋបាលស្រុកមានតួនាទីតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធ្វើអធិការកិច្ចលើការអនុវត្តមុខងាររបស់រដ្ឋបាលឃុំ សង្កាត់តាមការធ្វើប្រតិភូកម្មអំណាចពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន
- រដ្ឋបាលឃុំ សង្កាត់មានតួនាទីធ្វើរបាយការណ៍ជាទៀងទាត់ជូនរដ្ឋបាលស្រុក តាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រដ្ឋបាលស្រុកអាចពិគ្រោះយោបល់ និងធ្វើកិច្ចសហប្រតិបត្តិការរួមគ្នាលើកិច្ចការចាំបាច់មួយចំនួនជាមួយរដ្ឋបាលឃុំ សង្កាត់ ដើម្បីធានាលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន
- គណៈអភិបាលស្រុកត្រូវធ្វើការដឹកនាំ និងណែនាំដល់ចៅសង្កាត់ និងមេឃុំក្នុងស្រុក ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ
- កិច្ចការទំនាក់ទំនងផ្សេងៗទៀតតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមតម្រូវការចាំបាច់។

**មាត្រា ៤៥.-**

ក្នុងករណីមិនចុះសម្រុងគ្នារវាងរដ្ឋបាលស្រុក ជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក ក្រសួងមហាផ្ទៃត្រូវសម្របសម្រួលដោះស្រាយផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៤

## ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត

**មាត្រា ៤៦.-**

ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀតរួមមាន៖

- រដ្ឋបាលស្រុកអាចធ្វើការសម្របសម្រួល ការពិគ្រោះយោបល់ និងកិច្ចសហការរួមគ្នាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀតក្នុងការអនុវត្តមុខងារ គម្រោង កម្មវិធីនានា និងការដោះស្រាយតម្រូវការ និងបញ្ហាប្រឈមនានាដែលមានការពាក់ព័ន្ធគ្នាតាមរយៈការរៀបចំយន្តការគ្រប់គ្រងរួមគ្នា ឬការដាក់ចេញនូវដីកា ឬសេចក្តីសម្រេចរួមគ្នា



k

- រដ្ឋបាលស្រុកអាចធ្វើទំនាក់ទំនងការងារជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀតក្នុងការចែករំលែកពីគ្នាទៅវិញទៅមកនូវព័ត៌មាន ចំណេះដឹង ជំនាញ និងមេរៀនបទពិសោធន៍នានា
- កិច្ចការទំនាក់ទំនងផ្សេងៗទៀតតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមតម្រូវការចាំបាច់។

**មាត្រា ៤៧.-**

ក្នុងករណីមិនចុះសម្រុងគ្នារវាងរដ្ឋបាលស្រុក ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត ក្រសួងមហាផ្ទៃត្រូវសម្របសម្រួលដោះស្រាយផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៥

## ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយវិស័យឯកជន និងសង្គមស៊ីវិល

**មាត្រា ៤៨.-**

ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយវិស័យឯកជន និងសង្គមស៊ីវិលនានាដែលកំពុងប្រតិបត្តិការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមមាន៖

- រដ្ឋបាលស្រុកអាចធ្វើការសម្របសម្រួល និងផ្តល់ការលើកទឹកចិត្តដល់វិស័យឯកជន និងសង្គមស៊ីវិលនានាក្នុងការចូលរួមរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការ គម្រោង ឬកម្មវិធីនានារបស់រដ្ឋបាលស្រុក
- រដ្ឋបាលស្រុកអាចសម្របសម្រួលក្នុងការបង្កើតឡើងនូវភាពជាដៃគូជាមួយវិស័យឯកជន និងសង្គមស៊ីវិល ដើម្បីរួមគ្នាលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ
- រដ្ឋបាលស្រុកអាចផ្តល់ការគាំទ្រដល់វិស័យឯកជន និងសង្គមស៊ីវិលនានាក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានទៅតាមលទ្ធភាពធនធានរបស់រដ្ឋបាលស្រុក
- រដ្ឋបាលស្រុកផ្តល់ការលើកទឹកចិត្តដល់វិស័យឯកជន និងសង្គមស៊ីវិលនានាក្នុងការផ្តួចផ្តើមលើកឡើងនូវតម្រូវការ និងសំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ ដើម្បីឱ្យរដ្ឋបាលស្រុកដាក់ចេញនូវដីកា ឬសេចក្តីសម្រេច ឬផ្តល់កិច្ចអន្តរាគមន៍ដោះស្រាយ
- រដ្ឋបាលស្រុកត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយវិស័យឯកជន និងសង្គមស៊ីវិលនានា ដើម្បីចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមនានា។

## ជំពូកទី៦

## គណនេយ្យភាព

## ផ្នែកទី១

## គណនេយ្យភាពចំពោះប្រជាពលរដ្ឋ

**មាត្រា ៤៩.-**

រដ្ឋបាលស្រុកត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ ក្នុងការបំពេញតួនាទី ភារកិច្ចក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ៥០.-**

ក្នុងការធ្វើគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រដ្ឋបាលស្រុកត្រូវរៀបចំឱ្យមានយន្តការ មធ្យោបាយ និងនីតិវិធីនៃការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ ការទទួលព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋ និងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ដើម្បីធានាថារាល់សេចក្តីសម្រេចនានា និងរាល់សកម្មភាព ឬទង្វើរបស់រដ្ឋបាលស្រុកត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព បរិយាប័ន្ន និងសមធម៌សង្គម។

## ផ្នែកទី២

## គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន

**មាត្រា ៥១.-**

រដ្ឋបាលស្រុកត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នក្នុងការបំពេញតួនាទី ភារកិច្ចក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា ៥២.-**

ក្នុងការធ្វើគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន រដ្ឋបាលស្រុកត្រូវធានាថារាល់សេចក្តីសម្រេចនានា និងរាល់សកម្មភាព ឬទង្វើរបស់រដ្ឋបាលស្រុកត្រូវអនុលោមទៅតាមគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវារបស់ថ្នាក់ជាតិ។

សេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើងមិនស្របតាមគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំ ឬធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ដើម្បីឱ្យរដ្ឋបាលស្រុកកែតម្រូវ ឬលុបចោលនូវសេចក្តីសម្រេចដែលធ្វើឡើងមិនស្របច្បាប់នោះ។

**មាត្រា ៥៣.-**

អភិបាលត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានាក្នុងការអនុវត្តមុខងារដែលទទួលបានការធ្វើប្រតិភូកម្មពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន។

## ផ្នែកទី៣

## គណនេយ្យភាពផ្ទៃក្នុង

**មាត្រា ៥៤.-**

អភិបាល និងគណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន អំពីការអនុវត្តដីកា និងសេចក្ដីសម្រេចនានារបស់ក្រុមប្រឹក្សា។

**មាត្រា ៥៥.-**

គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា និងការិយាល័យប្រជាពលរដ្ឋត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ៥៦.-**

នាយករដ្ឋបាលត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះក្រុមប្រឹក្សា អភិបាល និងគណៈអភិបាលរបស់ខ្លួន។

**មាត្រា ៥៧.-**

ប្រធានការិយាល័យ និងប្រធានអង្គភាពនីមួយៗត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាល។

**មាត្រា ៥៨.-**

បុគ្គលិកទាំងអស់របស់រដ្ឋបាលស្រុកត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រធានការិយាល័យ និងប្រធានអង្គភាពផ្ទាល់របស់ខ្លួន និងត្រូវមានគណនេយ្យភាពដោយប្រយោលចំពោះនាយករដ្ឋបាល អភិបាល គណៈអភិបាល និងក្រុមប្រឹក្សាតាមឋានានុក្រម។

## ជំពូកទី៧

## បទប្បញ្ញត្តិដោយឡែកសម្រាប់រដ្ឋបាលស្រុកនៃខេត្តបាត់ដំបង

**មាត្រា ៥៩.-**

មុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលស្រុកនានានៃខេត្តបាត់ដំបងត្រូវបានកំណត់ដូចខាងក្រោម៖

- ការគ្រប់គ្រងការអប់រំកុមារតូច ការគ្រប់គ្រងការអប់រំបឋមសិក្សា និងការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធត្រូវបានផ្ទេរតាមរយៈការប្រគល់ទៅឱ្យរដ្ឋបាលស្រុកនានានៃខេត្តបាត់ដំបង
- ការគ្រប់គ្រងការអប់រំមធ្យមសិក្សា ការអភិវឌ្ឍយុវជន និងការងារអប់រំកាយនិងកីឡាត្រូវផ្ទេរតាមរយៈការធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលស្រុកនានានៃខេត្តបាត់ដំបង

មុខងាររង និងសកម្មភាពនៃមុខងារដែលត្រូវបានប្រគល់ និងធ្វើប្រតិភូកម្មតាមខ្លឹមសារនៃមាត្រានេះមានកំណត់ក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

**មាត្រា ៦០.-**

រដ្ឋបាលស្រុកនីមួយៗនៃខេត្តបាត់ដំបងមានការិយាល័យ និងអង្គភាពដូចមានកំណត់ក្នុងមាត្រា

៩នៃអនុក្រឹត្យនេះ និងត្រូវមានអង្គភាពបន្ថែមដូចខាងក្រោម ៖

- គ្រឹះស្ថានបឋមសិក្សាសាធារណៈ
- គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ

គ្រឹះស្ថានបឋមសិក្សាសាធារណៈ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍នៃក្រសួងអប់រំ យុវជន និងកីឡាដែលមាននៅថ្នាក់ស្រុកនៃខេត្តបាត់ដំបងត្រូវធ្វើសមាហរណកម្មមកស្ថិតក្រោមការគ្រប់គ្រងរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលស្រុកនៃខេត្តបាត់ដំបង។

**មាត្រា ៦១.-**

អង្គការលេខរបស់រដ្ឋបាលស្រុកនៃខេត្តបាត់ដំបងមានកំណត់ក្នុងឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យនេះ។

**មាត្រា ៦២.-**

គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈត្រូវដឹកនាំដោយនាយកមួយ (០១)រូប និងមាននាយករងយ៉ាងច្រើនចំនួនបី (០៣)រូបជាជំនួយការ។

ការតែងតាំង និងការបញ្ចប់មុខតំណែងនាយក នាយករងនៃគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងនាយក នាយករងនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈត្រូវអនុវត្តតាមតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន។

**មាត្រា ៦៣.-**

មជ្ឈមណ្ឌលសិក្សាសហគមន៍ត្រូវគ្រប់គ្រងដោយគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលត្រូវតែងតាំង និងផ្លាស់ប្តូរតាមគោលការណ៍ នីតិវិធី និងបែបបទជាធរមាន។

**មាត្រា ៦៤.-**

គ្រឹះស្ថានបឋមសិក្សាសាធារណៈមានតួនាទីគ្រប់គ្រង និងផ្តល់សេវាអប់រំកម្រិតបឋមសិក្សា និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន
- គ្រប់គ្រង និងប្រើប្រាស់បុគ្គលិកអប់រំបឋមសិក្សា
- គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលារៀន
- គ្រប់គ្រង ចាត់ចែង និងថែទាំសៀវភៅសិក្សាគោល
- គ្រប់គ្រងសំណង់អគារ សាងសង់ និងជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងសាលារៀន
- គ្រប់គ្រងសិស្សសាលាបឋមសិក្សា
- គ្រប់គ្រងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន
- គ្រប់គ្រងកម្មវិធីគាំទ្រការអប់រំបឋមសិក្សា
- ការងារអប់រំកាយ និងកីឡា
- អភិវឌ្ឍវិស័យអប់រំដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍនានា



ស

- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីអភិបាលស្រុក។

**មាត្រា ៦៥.-**

គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈមានតួនាទីគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងផ្តល់សេវាអប់រំកម្រិតមត្តេយ្យសិក្សា និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន
- គ្រប់គ្រង និងប្រើប្រាស់បុគ្គលិកអប់រំមត្តេយ្យសិក្សា
- ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលាមត្តេយ្យសិក្សា
- គ្រប់គ្រងសំណង់អគារ សាងសង់ និងជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងសាលារៀន
- គ្រប់គ្រងសិស្សមត្តេយ្យសិក្សា
- គ្រប់គ្រងកម្មវិធីគាំទ្រការអប់រំកុមារតូច
- អភិវឌ្ឍវិស័យអប់រំដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍនានា
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីអភិបាលស្រុក។

**មាត្រា ៦៦.-**

ការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ត្រូវអនុវត្តតាមបទប្បញ្ញត្តិ និងគោលការណ៍នានាដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

គ្រឹះស្ថានសិក្សាសាធារណៈមានស្វ័យភាពក្នុងការគ្រប់គ្រងការរៀន និងការបង្រៀន ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ ការវាយតម្លៃប្រសិទ្ធភាពបុគ្គលិកអប់រំ និងការងារគ្រប់គ្រងរដ្ឋបាល។

**មាត្រា ៦៧.-**

ការបង្កើត ការគ្រប់គ្រង និងតួនាទី ភារកិច្ចរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៦៨.-**

គ.ជ.អ.ប. ត្រូវដឹកនាំសម្របសម្រួលលើការសិក្សា និងការវាយតម្លៃទៅលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានប្រគល់ទៅឱ្យរដ្ឋបាលស្រុកនៃខេត្តបាត់ដំបង ដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាលក្នុងការសម្រេចប្រគល់មុខងារទាំងនេះទៅឱ្យរដ្ឋបាលស្រុកនៃខេត្តដទៃទៀត។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា ៦៩.-**

ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមានរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ រដ្ឋបាលស្រុក និងការិយាល័យ អង្គភាពជំនាញនានានៅថ្នាក់ស្រុកត្រូវបន្តអនុវត្តតាមរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនាពេលបច្ចុប្បន្ន។

**មាត្រា ៧០.-**

គ.ជ.អ.ប. ត្រូវដឹកនាំ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំនូវកិច្ចការនានាពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ បុគ្គលិក ការរៀបចំលិខិតបទដ្ឋានគតិយុត្ត ការផ្សព្វផ្សាយ ការបណ្តុះបណ្តាល និងកិច្ចការចាំបាច់ផ្សេងទៀត ដើម្បីធានាឱ្យរដ្ឋបាលស្រុកអាចចាប់ផ្តើមអនុវត្តនូវមុខងារ និងតួនាទី ភារកិច្ចរបស់ខ្លួនតាមរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងដែលបានកំណត់ក្នុងអនុក្រឹត្យនេះចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០តទៅ។

គ.ជ.អ.ប. ត្រូវរៀបចំផែនការសកម្មភាព និងថវិកា ដោយកំណត់អំពីក្របខ័ណ្ឌពេលវេលាជាក់លាក់ និងក្រសួង ស្ថាប័នទទួលខុសត្រូវច្បាស់លាស់ ដើម្បីរៀបចំ និងអនុវត្តកិច្ចការចាំបាច់នានាដូចបានកំណត់ក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ។

**មាត្រា ៧១.-**

ការិយាល័យ និងអង្គភាពជំនាញពាក់ព័ន្ធនានារបស់ក្រសួង ស្ថាប័នដែលមាននៅថ្នាក់ស្រុកត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុកតាមការកំណត់ដូចខាងក្រោម៖

- ផ្ទេរការិយាល័យអប់រំ យុវជន និងកីឡានៃក្រសួងអប់រំ យុវជន និងកីឡានៅថ្នាក់ស្រុកមកជាការិយាល័យអប់រំ យុវជន និងកីឡារបស់រដ្ឋបាលស្រុក
- ផ្ទេរការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅថ្នាក់ស្រុកមកជាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលរបស់រដ្ឋបាលស្រុក
- ការិយាល័យព័ត៌មាននៃក្រសួងព័ត៌មានត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុរបស់រដ្ឋបាលស្រុក
- ការិយាល័យផែនការ ស្ថិតិនៃក្រសួងផែនការត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់របស់រដ្ឋបាលស្រុក
- មណ្ឌលសេវាកម្មយុត្តិធម៌នៃក្រសួងយុត្តិធម៌ត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានរបស់រដ្ឋបាលស្រុក
- ការិយាល័យបរិស្ថាននៃក្រសួងបរិស្ថាន ការិយាល័យកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការិយាល័យធនធានទឹកនិងឧតុនិយមនៃក្រសួងធនធានទឹកនិងឧតុនិយម ត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថានរបស់រដ្ឋបាលស្រុក
- ការិយាល័យសាធារណការនិងដឹកជញ្ជូននៃក្រសួងសាធារណការនិងដឹកជញ្ជូន ការិយាល័យពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ការិយាល័យអភិវឌ្ឍន៍ជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ ការិយាល័យឧស្សាហកម្មនិងសិប្បកម្មនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម ការិយាល័យរ៉ែនិងថាមពលនៃក្រសួងរ៉ែនិងថាមពល ការិយាល័យទេសចរណ៍នៃក្រសួងទេសចរណ៍ និង

ការិយាល័យប្រៃសណីយ៍និងទូរគមនាគមន៍នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍របស់រដ្ឋបាលស្រុក

- ការិយាល័យសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទានៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការិយាល័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ការិយាល័យកិច្ចការនារីនៃក្រសួងកិច្ចការនារី ការិយាល័យវប្បធម៌និងវិចិត្រសិល្បៈនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងការិយាល័យធម្មការនិងសាសនានៃក្រសួងធម្មការនិងសាសនា ត្រូវធ្វើសមាហរណកម្មចូលមកក្នុងការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមរបស់រដ្ឋបាលស្រុក។

**មាត្រា ៧២.-**

ការិយាល័យ អង្គភាពនានារបស់រដ្ឋបាលស្រុកបច្ចុប្បន្នត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុកតាមការកំណត់ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ និងឬការិយាល័យគ្រប់គ្រងធនធានមនុស្ស និងឬការិយាល័យលេខាធិការក្រុមប្រឹក្សានៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុក
- ការិយាល័យអន្តរវិស័យត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យនីតិកម្មនិងសម្រុះសម្រួលវិវាទមូលដ្ឋាន និងឬការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហគមន៍ និងឬការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម និងឬការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាននៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុក
- ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យផែនការនិងគាំទ្រឃុំ សង្កាត់នៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុក
- អង្គភាពលទ្ធកម្មត្រូវធ្វើសមាហរណកម្មទៅក្នុងអង្គភាពលទ្ធកម្មនៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុក
- ការិយាល័យច្រកចេញចូលតែមួយត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យច្រកចេញចូលតែមួយនៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុក។

**មាត្រា ៧៣.-**

បុគ្គលិក ទ្រព្យសម្បត្តិ និងឯកសារលិខិតស្នាមនានានៃការិយាល័យ និងអង្គភាពនានាដែលត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលស្រុក ត្រូវផ្ទេរមកក្រោមការគ្រប់គ្រងរបស់ការិយាល័យឬអង្គភាពថ្មីដូចមានកំណត់ក្នុងមាត្រា៧១ និងមាត្រា៧២នៃអនុក្រឹត្យនេះ។

រដ្ឋបាលខេត្តត្រូវសម្របសម្រួល និងគាំទ្រដល់ការផ្ទេរជាក់ស្តែងនូវបុគ្គលិក ទ្រព្យសម្បត្តិ និងឯកសារលិខិតស្នាមនានាដូចបានកំណត់ក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ។

**មាត្រា ៧៤.-**

បុគ្គលិកដែលបានផ្ទេរមកបំពេញការងារនៅរដ្ឋបាលស្រុកត្រូវ ៖

- ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលស្រុកស្របតាមគោលការណ៍ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិជាធរមាន
- បន្តស្ថិតនៅក្នុងក្របខ័ណ្ឌដែលសាមីខ្លួនបានតាំងស៊ប់មុនពេលផ្ទេរមករដ្ឋបាលស្រុករហូតដល់មានការរៀបចំឡើងវិញស្របតាមមាត្រា១៣នៃអនុក្រឹត្យនេះ
- មានក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗមិនទាបជាងក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗដែលបុគ្គលិកទាំងនោះធ្លាប់បានទទួលមុនពេលផ្ទេរឡើយ។

**មាត្រា ៧៥.-**

ការផ្ទេរបុគ្គលិកក្នុងដំណាក់កាលនៃការធ្វើសមាហរណកម្មការិយាល័យជំនាញនានាទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលស្រុកត្រូវផ្អែកតាមគោលការណ៍ដូចខាងក្រោម ៖

- ប្រធាន និងអនុប្រធានការិយាល័យអប់រំ យុវជននិងកីឡា និងការិយាល័យរៀចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលដែលកំពុងកាន់មុខតំណែងបច្ចុប្បន្នត្រូវបន្តតែងតាំងជាប្រធាន និងអនុប្រធាននៃការិយាល័យទាំងពីរនេះ។ ក្នុងករណីដែលការិយាល័យណាមួយពុំទាន់មានប្រធាន ឬអនុប្រធានការិយាល័យ ការសម្រេចតែងតាំងប្រធាន ឬអនុប្រធានការិយាល័យនោះត្រូវផ្អែកតាមលក្ខខណ្ឌដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ
- ប្រធានការិយាល័យសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហគមន៍ ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម និងការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន ត្រូវបានតែងតាំងដោយជ្រើសរើសបេក្ខភាពចេញពីចំណោមប្រធានការិយាល័យជំនាញនានា និងឬប្រធានការិយាល័យនៃរដ្ឋបាលស្រុកដែលកំពុងកាន់មុខតំណែងបច្ចុប្បន្នដែលត្រូវបានធ្វើសមាហរណកម្មទៅក្នុងការិយាល័យទាំងនេះ។ ប្រធានការិយាល័យជំនាញទាំងឡាយណាដែលពុំត្រូវបានតែងតាំងជាប្រធានការិយាល័យក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្មី ត្រូវតែងតាំងជាអនុប្រធានការិយាល័យចង្កោមវិស័យនោះ។ អនុប្រធានការិយាល័យជំនាញទាំងអស់នៃការិយាល័យដែលត្រូវបានធ្វើសមាហរណកម្មត្រូវតែងតាំងជាអនុប្រធានការិយាល័យចង្កោមវិស័យនោះ
- ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ការិយាល័យច្រកចេញចូលតែមួយ និងអង្គភាពលទ្ធកម្មនៃរដ្ឋបាលស្រុកបច្ចុប្បន្នត្រូវបន្តរក្សាមុខតំណែងជាប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ការិយាល័យច្រកចេញចូលតែមួយ និងអង្គភាពលទ្ធកម្មនៃរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលស្រុក
- ប្រធាន និងអនុប្រធានការិយាល័យផែនការនិងគាំទ្រឃុំ សង្កាត់នៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុកត្រូវជ្រើសរើសចេញពីប្រធាន និងអនុប្រធានការិយាល័យផែនការនិងគាំទ្រឃុំ សង្កាត់បច្ចុប្បន្ន ឬការិយាល័យផែនការស្ថិតិនៃក្រសួងផែនការ



/k

- ការរៀបចំមុខតំណែងប្រធាន និងអនុប្រធាននៃការិយាល័យផ្សេងទៀតក្រៅពីការិយាល័យ និងអង្គភាពដូចបានកំណត់ក្នុងចំណុចត្រែទាំង៤ខាងលើនៃមាត្រានេះត្រូវជ្រើសរើសចេញពីប្រធាន ឬអនុប្រធានការិយាល័យនានាដែលត្រូវបានធ្វើសមាហរណកម្មបញ្ចូលមកក្នុងរចនាសម្ព័ន្ធថ្មី។ ការរៀបចំមុខតំណែងទាំងនេះត្រូវផ្អែកលើសមត្ថភាព ចំណេះដឹង ជំនាញ និងបទពិសោធន៍ការងារ
- បុគ្គលិកដែលត្រូវបានផ្ទេរពីការិយាល័យជំនាញនានាត្រូវរៀបចំបញ្ចូលទៅក្នុងការិយាល័យដែលពាក់ព័ន្ធនឹងវិស័យជំនាញរបស់ខ្លួន
- ក្នុងករណីមុខងារនៃវិស័យណាមួយដែលបានផ្ទេរមក ហើយពុំមានបុគ្គលិកត្រូវបានផ្ទេរមកជាមួយ រដ្ឋបាលស្រុកត្រូវរៀបចំឱ្យមានបុគ្គលិកទទួលខុសត្រូវលើមុខងារនោះ។ ក្នុងករណីនេះ ក្រសួង ស្ថាប័ននៃវិស័យជំនាញត្រូវផ្តល់ការបណ្តុះបណ្តាលជាបន្ទាន់ដល់មន្ត្រីទាំងនោះ។

**មាត្រា ៧៦.-**

គ.ជ.អ.ប. ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវសម្រេចអំពីការរៀបចំផ្ទេរបុគ្គលិក និងមុខតំណែងគ្រប់គ្រងតាមការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុកក្នុងដំណាក់កាលសមាហរណកម្មនេះ។

ក្រោយពេលធ្វើសមាហរណកម្ម ការតែងតាំង និងការបញ្ចប់មុខតំណែងនានានៃការិយាល័យ និងអង្គភាពចំណុះរដ្ឋបាលស្រុកត្រូវអនុវត្តតាមគោលការណ៍ នីតិវិធី និងបែបបទនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិជាធរមាន។

គ.ជ.អ.ប. អាចបង្កើតក្រុមការងារអន្តរក្រសួងមួយដែលមានសមាសភាពមកពីក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខាធិការដ្ឋានគ.ជ.អ.ប. និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីជួយដល់គ.ជ.អ.ប. ក្នុងការរៀបចំកិច្ចការទាំងនេះ។

**មាត្រា ៧៧.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់គ.ជ.អ.ប. ត្រូវកំណត់ទំហំធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ដើម្បីផ្ទេរទៅឱ្យរដ្ឋបាលស្រុកសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនានាដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះចាប់ពីខែមករា ឆ្នាំ២០២០តទៅ។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**មាត្រា ៧៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៧៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៦ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

**__កន្លែងទទួល:__**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត របស់ក្រុមប្រឹក្សានិងគណៈអភិបាលក្រុង របស់ក្រុមប្រឹក្សានិងគណៈអភិបាលស្រុក ព្រមទាំងទំនាក់ទំនងការងាររវាងរដ្ឋបាលខេត្ត ជាមួយរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់ក្នុងខេត្ត និងរដ្ឋបាលទាំងនេះជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល។

**មាត្រា ២.-**

រដ្ឋបាលខេត្តដែលប្រើក្នុងអនុក្រឹត្យនេះ គឺសំដៅទៅលើក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត។

រដ្ឋបាលក្រុងដែលប្រើក្នុងអនុក្រឹត្យនេះ គឺសំដៅទៅលើក្រុមប្រឹក្សានិងគណៈអភិបាលក្រុង។

រដ្ឋបាលស្រុកដែលប្រើក្នុងអនុក្រឹត្យនេះ គឺសំដៅទៅលើក្រុមប្រឹក្សានិងគណៈអភិបាលស្រុក។

**មាត្រា ៣.-**

ខេត្ត ក្រុង ស្រុក ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចិរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ។

**មាត្រា ៤.-**

ខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់ក្នុងខេត្ត ត្រូវមានក្រុមប្រឹក្សារៀង១ខ្លួនជាតំណាង ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

**មាត្រា ៥.-**

រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ទទួលសិទ្ធិអំណាចរបស់ខ្លួនដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀតដែលស្របនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

## ជំពូកទី២

## រដ្ឋបាលខេត្ត

### ផ្នែកទី១

### ក្រុមប្រឹក្សាខេត្ត

**មាត្រា ៦.-**

ក្រុមប្រឹក្សាខេត្តដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈ

ជាអ្នកការពារនិងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា ៧.-**

ក្រុមប្រឹក្សាខេត្ត ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលនៅជាធរមាន។

**មាត្រា ៨.-**

ក្រុមប្រឹក្សាខេត្ត មានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារ ភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្ម ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៩.-**

ក្នុងអំឡុងត្រីមាសទី៤នៃឆ្នាំនីមួយៗ ក្រុមប្រឹក្សាខេត្តត្រូវរៀបចំឱ្យមានវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ នៅតាមក្រុងនិងស្រុកនានាក្នុងខេត្ត។

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ ត្រូវចូលរួមដោយសមាជិកក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត សមាជិកក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង សមាជិកក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក សមាជិកក្រុមប្រឹក្សាឃុំ សមាជិកក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត តំណាងសហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធដទៃទៀតតាមការសម្រេចពីក្រុមប្រឹក្សាខេត្ត។

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ មានគោលបំណងដើម្បីឱ្យក្រុមប្រឹក្សាខេត្តជម្រាបជូនក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ សហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធនានា អំពីសកម្មភាពរបស់ក្រុមប្រឹក្សាខេត្តក្នុងរយៈពេលមួយ(០១)ឆ្នាំ ការឆ្លើយតបចំពោះសំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ សហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ការពិភាក្សាស្រាយបំភ្លឺអំពីបញ្ហានានាដល់អ្នកចូលរួម និងការប្រមូលមតិយោបល់នានាពីអ្នកចូលរួម ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន។

ប្រធានក្រុមប្រឹក្សាខេត្ត ជាអ្នកសម្របសម្រួលក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះ។

គណៈអភិបាលខេត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវធ្វើការបូកសរុប វាយតម្លៃអំពីលទ្ធផលនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះយ៉ាងយូរដប់ប្រាំ(១៥)ថ្ងៃបន្ទាប់។ ក្នុងការបូកសរុបវាយតម្លៃនេះ ត្រូវលើកឡើងនូវគោលការណ៍ វិធានការ ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន ក្នុងក្របខ័ណ្ឌតួនាទីសមត្ថកិច្ចរបស់រដ្ឋបាលខេត្ត។ ចំពោះកិច្ចការទាំងឡាយណា ដែលពាក់ព័ន្ធតួនាទី សមត្ថកិច្ចរបស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀត រដ្ឋបាលខេត្តត្រូវពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាដែលពាក់ព័ន្ធទាំងនោះ ដើម្បីលើកឡើងអំពីគោលការណ៍ វិធានការ ដោះស្រាយ

តាមសមត្ថកិច្ចរៀងៗខ្លួន។ ចំពោះកិច្ចការដែលពាក់ព័ន្ធតួនាទី សមត្ថកិច្ចរបស់ថ្នាក់ជាតិ រដ្ឋបាលខេត្តត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រសួងមហាផ្ទៃ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំបន្ថែមទៀតអំពីការរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់តាមការចាំបាច់។

**មាត្រា ១០.-**

ក្រុមប្រឹក្សាខេត្ត ត្រូវបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិនិងសេចក្តីសម្រេចខាងប្រតិបត្តិ តាមរយៈដីកា និងសេចក្តីសម្រេចនានាក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចទាំងនោះ ត្រូវបានអនុវត្តដោយមានការតាមដាននិងវាយតម្លៃជាប្រចាំ។

**មាត្រា ១១.-**

កិច្ចប្រជុំក្រុមប្រឹក្សាខេត្ត អាចយកជាការបានលុះត្រាតែកិច្ចប្រជុំនេះប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន។

សេចក្តីសម្រេចទាំងឡាយណា ដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន មិនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវណែនាំ ឬអាចធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាកែតម្រូវសេចក្តីសម្រេចដែលធ្វើឡើងមិនស្របច្បាប់នោះឡើងវិញ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាខេត្ត អាចចាត់ឱ្យគណៈកម្មាធិការណាមួយ ឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការឬអនុគណៈកម្មាធិការឬក្រុមការងារនានាដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចតាមការចាំបាច់។ ក្នុងករណីនេះ គណៈអភិបាលខេត្តត្រូវដឹកនាំនាយករដ្ឋបាលសាលាខេត្ត និងទីចាត់ការពាក់ព័ន្ធនៃសាលាខេត្ត ដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ។

គណៈអភិបាលខេត្ត ដោយមាននាយករដ្ឋបាលសាលាខេត្តជាជំនួយការ ត្រូវធ្វើការសម្របសម្រួល ណែនាំដល់ទីចាត់ការនានានៃសាលាខេត្ត រៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេច ដើម្បីដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យពិភាក្សា និងអនុម័ត។

អភិបាលខេត្ត ត្រូវណែនាំនាយករដ្ឋបាលសាលាខេត្ត ឱ្យរៀបចំដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច ឱ្យស្របតាមទម្រង់ដែលកំណត់ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាខេត្តចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន និងត្រូវប្រថាប់ត្រារដ្ឋបាលខេត្ត។

ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យអភិបាលខេត្តចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកា ឬសេចក្តីសម្រេចទាំងឡាយណាដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច លើកលែងតែមានការកំណត់ផ្សេងពីនេះ ព្រមទាំងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។

**មាត្រា ១៣.-**

ប្រធានក្រុមប្រឹក្សាខេត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានសិទ្ធិចុះហត្ថលេខានិងប្រថាប់ត្រារដ្ឋបាលខេត្តលើ :

- ដីកាឬសេចក្ដីសម្រេចដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច
- សេចក្ដីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាខេត្ត
- កំណត់ហេតុប្រជុំដែលត្រូវបានអនុម័តដោយអង្គប្រជុំក្រុមប្រឹក្សាខេត្ត
- សំណើដកហូតអភិបាលខេត្តឬអភិបាលរងខេត្តចេញពីមុខតំណែងតាមការសម្រេចពីក្រុមប្រឹក្សាខេត្ត តាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា១៩២នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាខេត្ត
- ប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្តរយៈពេលដប់ពីរ(១២)ខែ
- សំណើសុំផ្លាស់ប្ដូរសមាជិកក្រុមប្រឹក្សាខេត្ត
- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

គណៈអភិបាលខេត្ត ត្រូវជួយក្រុមប្រឹក្សារបស់ខ្លួនក្នុងការរៀបចំឯកសារខាងលើនេះ លើកលែងតែឯកសារក្នុងចំណុចគំនូសទី៤។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្ដីណែនាំអំពីទម្រង់នៃឯកសារខាងលើតាមការចាំបាច់។

**មាត្រា ១៤.-**

រាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាខេត្តត្រូវធ្វើសេចក្ដីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្ដីសម្រេចខាងប្រតិបត្តិដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលខេត្ត និងវិធានការ បែបបទ នីតិវិធីចាត់ចែងការងារ តាមការចាំបាច់ដែលទាក់ទងទៅនឹង :

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីដែលស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាខេត្ត
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា
- ថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលខេត្ត
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាខេត្ត
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត

- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាខេត្ត ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនិងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត
- ការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលខេត្ត
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ១៥.-**

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាខេត្តត្រូវធ្វើការសម្រេចរៀងរាល់កិច្ចប្រជុំដូចមានចែងក្នុងមាត្រា១៤នៃអនុក្រឹត្យនេះ ក្រុមប្រឹក្សាខេត្តអាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងៗទៀតរួមមាន :

- ការកោះអញ្ជើញអភិបាលខេត្ត ឬអភិបាលរងខេត្ត ឬគណៈអភិបាលខេត្ត ឬបុគ្គលដែលពាក់ព័ន្ធ មកសាកសួរអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខេត្ត ឬហេតុការណ៍ណាមួយដែលកើតមានក្នុងខេត្ត ឬការដោះស្រាយបញ្ហាបន្ទាន់និងពិសេសណាមួយ ព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់រដ្ឋបាលខេត្ត
- ការសម្រេចឱ្យមានការសិក្សាស្រាវជ្រាវឬការស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សាខេត្តយល់ថា មានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និងសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវឬការធ្វើអង្កេតនេះ ព្រមទាំងណែនាំដល់គណៈអភិបាលខេត្តអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនេះ
- ការពិនិត្យ ស្រាវជ្រាវ និងការធ្វើសេចក្តីរាយការណ៍ទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការរំលោភអំណាចដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការពិនិត្យនិងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដោយក្រុមប្រឹក្សាខេត្ត ឬសមាជិកក្រុមប្រឹក្សាខេត្ត ឬគណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត តាមគោលការណ៍ដូចមានចែងក្នុងផ្នែកទី៥ ជំពូកទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការពិនិត្យនិងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់និងនីតិវិធីជាធរមាន
- ការពិនិត្យនិងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរឬការតវ៉ានានាពីសំណាក់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ពិនិត្យនិងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដែលរៀបចំដោយគណៈអភិបាលខេត្ត
- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលខេត្តយល់ឃើញថាចាំបាច់។

**មាត្រា ១៦.-**

ក្រុមប្រឹក្សាខេត្ត ត្រូវប្រើប្រាស់អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ដោយផ្អែកតាមគោលការណ៍ បែបបទ និង នីតិវិធីដែលកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

ក្នុងករណីកិច្ចការណាមួយដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួន ហើយដែលកិច្ចការនោះ ច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តមិនបានចែងអំពីបែបបទនិងនីតិវិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិ ឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យគណៈអភិបាលខេត្តធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទនិងនីតិវិធីសមស្រប ដោយឈរ លើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យនិងអនុម័ត ដើម្បីដោះស្រាយ កិច្ចការទាំងនេះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធនានាធ្វើការបញ្ជាក់នូវ បែបបទ នីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនេះ។

ក្នុងករណីកិច្ចការណាមួយដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទ និងនីតិវិធីដែរ ប៉ុន្តែបែបបទ និងនីតិវិធីនោះចែងមិនច្បាស់លាស់ឬមិនស្របនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយដែលក្រុមប្រឹក្សាខេត្ត មិនអាចអនុវត្តបាន ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យគណៈអភិបាលខេត្តធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវផ្អែកតាមយន្តការនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅ ថ្នាក់ក្រោមជាតិ(គ.ជ.អ.ប.) ធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យនិងដោះស្រាយ ករណីនេះ។

**មាត្រា ១៧.-**

អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាខេត្តបានសម្រេចរួចហើយ គណៈអភិបាលខេត្តត្រូវ ទទួលខុសត្រូវក្នុងការចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

គណៈអភិបាលខេត្ត ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញឬវិសាមញ្ញ របស់ក្រុមប្រឹក្សាខេត្ត ដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥នៃអនុក្រឹត្យនេះ។

ក្រុមប្រឹក្សាខេត្ត ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលខេត្ត ដើម្បីធានាថាគណៈអភិបាលខេត្តអនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការ សម្រេចរបស់ក្រុមប្រឹក្សាខេត្ត។

គ.ជ.អ.ប. ត្រូវដាក់ចេញនូវគោលការណ៍ណែនាំ គាំទ្រដល់ក្រុមប្រឹក្សាខេត្តក្នុងការរៀបចំនូវប្រព័ន្ធតាមដាន ត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខេត្ត។

## ផ្នែកទី២
## អំពីគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត

**មាត្រា ១៨.-**

ក្រុមប្រឹក្សាខេត្ត ត្រូវមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមាន :

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ
- គណៈកម្មាធិការលទ្ធកម្ម ។

កិច្ចដំណើរការនៃគណៈកម្មាធិការទាំងបីខាងលើ ត្រូវផ្អែកតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទាំងនេះ ។

**មាត្រា ១៩.-**

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សាខេត្តអាចបង្កើតគណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះ មិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយតួនាទី ភារកិច្ចរបស់គណៈកម្មាធិការទាំងបីដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឡើយ ។

ក្រុមប្រឹក្សាខេត្តអាចបង្កើតអនុគណៈកម្មាធិការឬក្រុមការងារផ្សេងៗទៀត តាមការស្នើសុំរបស់គណៈកម្មាធិការនានាឬគណៈអភិបាលខេត្ត ។

អនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ ត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការឬគណៈអភិបាលខេត្ត ។

**មាត្រា ២០.-**

ក្រុមប្រឹក្សាខេត្ត អាចតែងតាំងសមាជិកក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត អភិបាលរងខេត្ត បុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត តំណាងក្រុមប្រឹក្សាប្រភេទផ្សេងទៀតក្នុងដែនសមត្ថកិច្ចរបស់ខេត្ត តំណាងសហគមន៍ប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់ ជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង ។

ក្រុមប្រឹក្សាខេត្ត ត្រូវសម្រេចពីចំនួនសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ការតែងតាំងប្រធាន អនុប្រធាន និងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាដែលខ្លួនបានបង្កើតឡើង ។

គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ត្រូវមានតំណាងស្ត្រីសមស្រប រួមទាំងតំណែងប្រធាន ឬ អនុប្រធានគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារផង ។

ក្រុមប្រឹក្សាខេត្ត អាចរំសាយគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង តាមការចាំបាច់ ឬតាមសំណើរបស់គណៈកម្មាធិការ ឬគណៈអភិបាលខេត្ត ។

**មាត្រា ២១.-**

គណៈអភិបាលខេត្ត អាចស្នើសុំក្រុមប្រឹក្សាខេត្តដើម្បីឱ្យគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយដែលក្រុមប្រឹក្សាខេត្តបានបង្កើតឡើង រួមទាំងគណៈកម្មាធិការទាំងបី(០៣)ដែលតម្រូវឱ្យបង្កើតឡើងដោយ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជួយសិក្សាផ្តល់យោបល់លើបញ្ហាណាមួយ ឬមួយចំនួនដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈអភិបាលខេត្ត។

**មាត្រា ២២.-**

ក្រុមប្រឹក្សាខេត្ត ត្រូវទទួលខុសត្រូវរាល់ការសម្រេចនិងសកម្មភាពរបស់គណៈកម្មាធិការនានា និងទទួលខុសត្រូវចំពោះផលវិបាកនានាដែលកើតចេញពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ។

**មាត្រា ២៣.-**

ក្រុមប្រឹក្សាខេត្ត ត្រូវណែនាំឱ្យគណៈអភិបាលខេត្តផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន ការគាំទ្រផ្នែកច្បាប់ និងបច្ចេកទេស ព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការទាំងបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលក្រុមប្រឹក្សាខេត្តបានបង្កើតឡើង។

**មាត្រា ២៤.-**

គណៈកម្មាធិការដែលបានបង្កើតឡើង ត្រូវមានសេចក្តីរាយការណ៍ប្រចាំត្រីមាស ឆមាស ឆ្នាំ និងតាមតម្រូវការចាំបាច់នានា។

សេចក្តីរាយការណ៍ខាងលើនេះ ត្រូវចម្លងជូនគណៈអភិបាលខេត្ត ដើម្បីធ្វើការបូកសរុប និងរាយការណ៍ជូនក្រុមប្រឹក្សាខេត្ត។

ក្រុមប្រឹក្សាខេត្ត អាចតម្រូវឱ្យគណៈកម្មាធិការណាមួយរាយការណ៍ដោយផ្ទាល់អំពីកិច្ចការពិសេសនិងបន្ទាន់ណាមួយក្នុងកិច្ចប្រជុំរបស់ខ្លួនតាមការចាំបាច់។

## ផ្នែកទី៣

## គណៈអភិបាលខេត្ត

**មាត្រា ២៥.-**

ខេត្តនីមួយៗ ត្រូវមានគណៈអភិបាលខេត្តមួយដែលរួមមាន អភិបាលខេត្ត អភិបាលរងខេត្ត ដែលត្រូវបានតែងតាំងឡើងស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ២៦.-**

អភិបាលខេត្ត អភិបាលរងខេត្ត មិនមែនជាសមាជិកក្រុមប្រឹក្សាខេត្តឡើយ។

**មាត្រា ២៧.-**

គណៈអភិបាលខេត្ត ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន អំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខេត្ត និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ២៨.-**

គណៈអភិបាលខេត្ត មានភារកិច្ចផ្តល់យោបល់ រាយការណ៍ជូនក្រុមប្រឹក្សាខេត្ត និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខេត្ត ទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។

**មាត្រា ២៩.-**

គណៈអភិបាលខេត្ត ត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាខេត្តអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាខេត្ត ដើម្បីក្រុមប្រឹក្សាខេត្តធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញ ទាក់ទងនឹង :

– ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាខេត្ត និងរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ
– ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ ឬបានផ្ទេរស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
– ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ
– ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
– គម្រោងថវិកាប្រចាំឆ្នាំ
– ការបង្កើត ការកែសម្រួល ឬការរំសាយទីចាត់ការ ឬការិយាល័យនានា
– ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
– ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរសក្តិ និងការបញ្ឈប់បុគ្គលិក
– ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់ប្រាក់បៀវត្ស និងកម្រៃផ្សេងៗនៃបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
– ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
– ការកំណត់យុទ្ធសាស្ត្រដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
– ការរៀបចំរបាយការណ៍ប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សាខេត្ត ពិនិត្យ និងអនុម័តមិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ដែលពាក់ព័ន្ធនឹង :
  + ដីកានិងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាខេត្ត និងសកម្មភាព លទ្ធផលនៃការអនុវត្ត
  + របាយការណ៍ហិរញ្ញវត្ថុ
  + ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលខេត្តនិងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
  + វិធានការចាំបាច់ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាខេត្ត

+ វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ

+ កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាខេត្តយល់ឃើញថា ចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។

– របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស

– ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាខេត្ត

– ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជាការរៀបចំក្តារព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានា ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

– កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ៣០.-**

នៅពេលបានទទួលរបាយការណ៍ឬព័ត៌មានអំពីការរំលោភអំណាចដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាលខេត្តត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថា មានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលខេត្តត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ជូនក្រុមប្រឹក្សាខេត្តនិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៣១.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា២៩ និងមាត្រា៣០ នៃអនុក្រឹត្យនេះ និងការងារដទៃទៀតដែលខ្លួនយល់ឃើញថាចាំបាច់ អភិបាលខេត្តត្រូវយកការងារទាំងនោះមកពិគ្រោះពិភាក្សាក្នុងគណៈអភិបាលរបស់ខ្លួនដោយឈរលើគោលការណ៍ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេច និងគោលការណ៍ណែនាំពីក្រុមប្រឹក្សារបស់ខ្លួន។

អភិបាលខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាខេត្តអំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលរបស់ខ្លួន។

អភិបាលរងខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលខេត្ត លើភារកិច្ចនានាដែលបានប្រគល់ ហើយត្រូវរួមជាមួយអភិបាលខេត្តទទួលខុសត្រូវអំពីការសម្រេចនិងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន។

ដើម្បីធានាឱ្យបាននូវគោលការណ៍នៃការអនុវត្តការងារនេះ គណៈអភិបាលខេត្តត្រូវជួបប្រជុំគ្នាប្រចាំអឌ្ឍមាស។ ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗជាការប្រជុំប្រចាំខែ។

ក្រៅពីការប្រជុំប្រចាំអឌ្ឍមាសនិងការប្រជុំប្រចាំខែខាងលើ គណៈអភិបាលខេត្តអាចកោះប្រជុំតាមការចាំបាច់។

រៀងរាល់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ។

**មាត្រា ៣២.-**

គណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ដែលបានសម្រេច និង/ឬដែលបានអនុវត្តកិច្ចការណាមួយផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាខេត្ត ការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពឡើយ។

គណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេច ឬសកម្មភាពខាងលើនេះ។

**មាត្រា ៣៣.-**

គណៈអភិបាលខេត្ត ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលខេត្ត និងអភិបាលរងខេត្ត ហើយសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំអំពីការបែងចែកភារកិច្ចដល់អភិបាលខេត្ត អភិបាលរងខេត្ត និងរបៀបរបបអនុវត្តភារកិច្ចដែលបានបែងចែកនោះ។

**មាត្រា ៣៤.-**

អភិបាលខេត្ត ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សារបស់ខ្លួន លើកលែងតែលិខិតបទដ្ឋានដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាខេត្តចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនដូចមានចែងក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ។

អភិបាលខេត្ត អាចប្រគល់សិទ្ធិដល់អភិបាលរងខេត្តក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន ក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងខេត្តនីមួយៗ។

អភិបាលខេត្ត ត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ និងបែបបទ នីតិវិធីចំពោះឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងខេត្ត។

អភិបាលខេត្ត មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងខេត្តណាមួយដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់ និងមិនស្របតាមបែបបទ នីតិវិធី។ ការប្រគល់និងការដកហូតសិទ្ធិក្នុងការចុះហត្ថលេខានេះ អភិបាលខេត្តត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធីនៃការប្រគល់សិទ្ធិចុះហត្ថលេខានេះ។

**មាត្រា ៣៥.-**

ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងខេត្ត អភិបាលខេត្តមានភារកិច្ច :

- ណែនាំដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ឱ្យអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងមន្ទីរ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ

- សម្របសម្រួល តម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំនៅខេត្ត ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលខេត្តត្រូវធ្វើការសម្របសម្រួលជាមួយមន្ទីរ អង្គភាព និងទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីរួមគ្នាអនុវត្តកិច្ចការនោះដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត អភិបាលខេត្តត្រូវធ្វើការសម្របសម្រួលតម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ក្នុងការធ្វើសមាហរណកម្មផែនការនិងថវិការបស់ខ្លួនទៅក្នុងផែនការនិងថវិការបស់ក្រុមប្រឹក្សាខេត្ត។
- ពិនិត្យ វាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុដល់ប្រធានមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានា តាមគោលការណ៍កំណត់
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខេត្តជាមុន ក្នុងការផ្តល់យោបល់ដល់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នលើបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានាដែលប្រចាំនៅខេត្ត។ ក្នុងករណីមិនគាំទ្រចំពោះបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពណាមួយ អភិបាលខេត្តត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់អំពីហេតុផលដែលមិនគាំទ្រនោះជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដើម្បីពិនិត្យពិចារណា។ ក្នុងករណីរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីឯកភាពតាមរបាយការណ៍របស់អភិបាលខេត្ត រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវផ្លាស់ប្តូរបេក្ខភាពដែលបានស្នើឡើងឱ្យបានសមស្រប។ ក្នុងករណីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីស្រាវជ្រាវឃើញថា ហេតុផលដែលបានបញ្ជាក់ក្នុងរបាយការណ៍របស់អភិបាលខេត្តពុំមានមូលដ្ឋានច្បាស់លាស់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវបញ្ជាក់ជូនអភិបាលខេត្ត ដើម្បីទទួលយកបេក្ខភាពដែលបានស្នើតែងតាំងនោះ។ ក្នុងករណីមិនមានការឯកភាពរវាងអភិបាលខេត្ត ជាមួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីទៅលើបេក្ខភាពដែលស្នើតែងតាំងនោះ រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីត្រូវធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ សម្រេច។ អភិបាលខេត្តត្រូវរាយការណ៍ករណីនេះជូនក្រុមប្រឹក្សារបស់ខ្លួននិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- ក្នុងករណីពិនិត្យឃើញភាពមិនប្រក្រតីក្នុងមន្ទីរ អង្គភាព និងទីភ្នាក់ងារណាមួយ ឬការប្រព្រឹត្តខុសឆ្គងរបស់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវទីភ្នាក់ងារណាមួយ អភិបាលខេត្តត្រូវធ្វើការណែនាំជាបន្ទាន់ដល់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះ ឱ្យធ្វើការកែលម្អឡើងវិញជាបន្ទាន់។ ក្នុងករណីប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះមិនបានកែប្រែ ឬក្នុងករណីភាពមិនប្រក្រតីឬការប្រព្រឹត្តខុសឆ្គងខាងលើមានលក្ខណៈធ្ងន់ធ្ងរ អភិបាលខេត្តត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីនៃមន្ទីរ អង្គភាព និងទីភ្នាក់ងារទាំងនោះ។ រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីត្រូវធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ដើម្បីដោះស្រាយទៅតាមច្បាប់។

- អភិបាលខេត្ត មានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីឬប្រធានស្ថាប័ន ដើម្បីដកហូតពីមុខតំណែងនូវប្រធានមន្ទីរ អង្គភាព ឬអ្នកទទួលខុសត្រូវទីភ្នាក់ងារណាមួយដែលប្រព្រឹត្តខុសឆ្គង ហើយដែលមិនអាចធ្វើយុត្តិកម្មបាន។

ដើម្បីធានាឱ្យអភិបាលខេត្តអនុវត្តនូវតួនាទី ភារកិច្ចខាងលើនេះ សេចក្តីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ត្រូវដាក់ជូនអភិបាលខេត្តដើម្បីពិនិត្យ ផ្តល់យោបល់ជាមុន។ ប្រសិនបើឯកភាព អភិបាលខេត្តត្រូវចុះហត្ថលេខាលើរបាយការណ៍នេះជាមួយប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ។ ចំពោះសេចក្តីរាយការណ៍ក្រៅពីនោះរបស់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ត្រូវចម្លងជូនសាលាខេត្ត។

**មាត្រា ៣៦.-**

អភិបាលខេត្ត ត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារនិងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងខេត្ត។

អភិបាលខេត្ត គឺជាប្រធានគណៈបញ្ជាការឯកភាពខេត្ត ក្នុងការដឹកនាំ សម្របសម្រួលមន្ទីរ អង្គភាពពាក់ព័ន្ធនានា រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងខេត្ត។

**មាត្រា ៣៧.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា៣៥និងមាត្រា៣៦នៃអនុក្រឹត្យនេះ អភិបាលខេត្តត្រូវធ្វើការបែងចែកភារកិច្ចដល់អភិបាលរងខេត្តក្នុងគណៈអភិបាលរបស់ខ្លួន ឱ្យជួយក្នុងការងារខាងលើនេះ។

អភិបាលរងខេត្តដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួនចំពោះមុខអភិបាលខេត្ត។

អភិបាលខេត្ត ត្រូវកោះប្រជុំគណៈអភិបាលខេត្តតាមការចាំបាច់ ដើម្បីពិគ្រោះពិភាក្សាលើបញ្ហាណាមួយដែលខ្លួនយល់ឃើញថាចាំបាច់ត្រូវធ្វើការពិភាក្សាក្នុងគណៈអភិបាលខេត្ត សំដៅលើកកម្ពស់ការចូលរួមអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា។

គ្រប់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុប្រជុំ។

**មាត្រា ៣៨.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា៣៥និងមាត្រា៣៦នៃអនុក្រឹត្យនេះ អភិបាលខេត្តត្រូវគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានា និងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា ស្របទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ៣៩.-**

អភិបាលខេត្ត ដោយមាននាយករដ្ឋបាលសាលាខេត្តជាជំនួយការ ត្រូវធ្វើសេចក្តីរាយការណ៍អំពីសកម្មភាព និងលទ្ធផលនៃការអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាលនិងតំណាងក្រសួង ស្ថាប័ននានា ព្រមទាំងស្ថានភាពនៃការងារទាំងនោះ ក្នុងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីមានបញ្ហាណាមួយដែលពាក់ព័ន្ធដល់ការអនុវត្តតួនាទីរបស់អភិបាលខេត្តក្នុងនាមជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬមានការទាមទារ តវ៉ាពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាខេត្តអាចតម្រូវឱ្យអភិបាលខេត្តធ្វើសេចក្តីរាយការណ៍ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន។

ក្រុមប្រឹក្សាខេត្ត អាចផ្តល់អនុសាសន៍ និងការណែនាំដល់អភិបាលខេត្តអំពីការអនុវត្តតួនាទីខាងលើនេះ ដើម្បីឆ្លើយតបតម្រូវការជាអាទិភាពនិងបញ្ហាប្រឈមនានារបស់មូលដ្ឋាន។

អភិបាលខេត្ត ត្រូវទទួលយកអនុសាសន៍និងការណែនាំពីក្រុមប្រឹក្សារបស់ខ្លួន ដើម្បីធ្វើការណែនាំ សម្របសម្រួល និងតម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ក្នុងការឆ្លើយតបតម្រូវការទាំងនោះ ហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនវិញ។

**មាត្រា ៤០.-**

ក្នុងករណីអភិបាលខេត្តអវត្តមាន អភិបាលខេត្តត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងខេត្តមួយរូបឱ្យទទួលជាអភិបាលខេត្តស្តីទី។

ប្រសិនបើអភិបាលខេត្តអវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរងខេត្តដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃអនុក្រឹត្យតែងតាំងអភិបាលរងនៃគណៈអភិបាលខេត្ត ត្រូវធ្វើជាអភិបាលខេត្តស្តីទី។

ក្នុងករណីអភិបាលខេត្តស្តីទីអវត្តមាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាស ដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងខេត្តមួយរូបឱ្យទទួលជាអភិបាលខេត្តស្តីទី។

អភិបាលខេត្តស្តីទី ត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលខេត្ត នៅពេលដែលអភិបាលខេត្តមានវត្តមានវិញ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្ទេរសិទ្ធិនេះ។

**មាត្រា ៤១.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើសេចក្តីណែនាំស្តីពីការសុំច្បាប់ឈប់សម្រាករបស់អភិបាលខេត្ត អភិបាលរងខេត្ត និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត។

## ផ្នែកទី៤

## នាយករដ្ឋបាលសាលាខេត្ត

**មាត្រា ៤២.-**

ក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលខេត្ត ត្រូវមាននាយករដ្ឋបាលមួយ(០១)រូប ហៅថានាយករដ្ឋបាលសាលាខេត្ត

ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្អែកតាមសំណើពីអភិបាលខេត្ត យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាខេត្ត។

នាយករដ្ឋបាលសាលាខេត្ត ត្រូវមាននាយករងរដ្ឋបាលពីរ(០២)រូបជាជំនួយការ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្អែកតាមសំណើពីអភិបាលខេត្ត យោងតាមការសម្រេចពីក្រុមប្រឹក្សាខេត្ត។

នាយករដ្ឋបាលសាលាខេត្ត ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរស័ក្តិចាប់ពីអនុមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ។

នាយករងរដ្ឋបាលសាលាខេត្ត ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរស័ក្តិចាប់ពីនាយក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។

**មាត្រា ៤៣.-**

លក្ខណសម្បត្តិនិងនីតិវិធីសម្រាប់ការតែងតាំងនាយករដ្ឋបាលសាលាខេត្ត និងនាយករងរដ្ឋបាលសាលាខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញប្រកាសឬសេចក្តីណែនាំអំពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់នាយករដ្ឋបាលសាលាខេត្ត និងនាយករងរដ្ឋបាលសាលាខេត្ត។

**មាត្រា ៤៤.-**

នាយករដ្ឋបាលសាលាខេត្ត មានតួនាទីជាជំនួយការដល់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងអភិបាលខេត្តក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងការធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខេត្ត។

ក្នុងតួនាទីនេះ នាយករដ្ឋបាលសាលាខេត្តត្រូវធ្វើរបាយការណ៍ និងត្រូវមានគណនេយ្យភាពចំពោះគណៈអភិបាលខេត្ត អភិបាលខេត្ត និងក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ៤៥.-**

ក្នុងការអនុវត្តតួនាទីដូចមានចែងក្នុងមាត្រា៤៤នៃអនុក្រឹត្យនេះ នាយករដ្ឋបាលសាលាខេត្តមានភារកិច្ច :

- រៀបចំនិងដាក់ជូនគណៈអភិបាលខេត្ត ពិនិត្យ សម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខេត្ត ផ្អែកតាមក្របខ័ណ្ឌសមត្ថកិច្ចរបស់គណៈអភិបាលខេត្ត ហើយត្រូវធានាថាកិច្ចការទាំងនោះត្រូវបានរៀបចំឡើងស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងទម្រង់បែបបទនៃលិខិតស្នាមរដ្ឋបាល
- រៀបចំនិងដាក់ជូនគណៈអភិបាលខេត្ត នូវវិធាននិងគោលការណ៍ក្នុងការអនុវត្តដីកានិងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខេត្ត
- ធ្វើជាសេនាធិការជូនអភិបាលខេត្តនិងប្រធានក្រុមប្រឹក្សាខេត្ត ក្នុងការត្រៀមរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខេត្ត រួមទាំងការសម្របសម្រួលក្នុងការរៀបចំឯកសារនិងខ្លឹមសារសម្រាប់របៀបវារៈនីមួយៗនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខេត្ត ស្របតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សារបស់ខ្លួន។ សេចក្តីព្រាងរបៀបវារៈ ឯកសារ និងខ្លឹមសារទាំងអស់ដែលនាយករដ្ឋបាលសាលាខេត្ត បានរៀបចំសម្រាប់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត ត្រូវតែដាក់ជូនគណៈអភិបាលខេត្ត ដើម្បីពិនិត្យ

និងផ្តល់យោបល់ជាមុន លើកលែងតែមានការកំណត់ផ្សេងដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

- ធ្វើជាសេនាធិការជូនក្រុមប្រឹក្សាខេត្តក្នុងការរៀបចំនិងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំ និងកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខេត្ត
- ត្រៀមរៀបចំកិច្ចការនានាសម្រាប់បម្រើឱ្យកិច្ចប្រជុំទាំងអស់របស់គណៈអភិបាលខេត្ត តាមការណែនាំរបស់អភិបាលខេត្ត
- ធានាក្នុងការទទួលនិងបែងចែកលិខិតស្នាម ឯកសារនានាឱ្យបានត្រឹមត្រូវ ដល់សមាជិកក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត និងអភិបាលរងខេត្ត ព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានា
- ធានារក្សាទុកដាក់ឱ្យបានត្រឹមត្រូវនិងគង់វង្សនូវឯកសារ លិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តនិងរដ្ឋបាលរបស់ខ្លួន
- គ្រប់គ្រងនិងប្រើប្រាស់ត្រារដ្ឋបាលខេត្តឱ្យបានត្រឹមត្រូវតាមការកំណត់ដូចមានចែងក្នុងមាត្រា៥៣នៃអនុក្រឹត្យនេះ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត អភិបាលខេត្ត ឬដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ៤៦.-**

នាយករដ្ឋបាលសាលាខេត្ត មានសិទ្ធិចូលរួម និងបញ្ចេញយោបល់គ្រប់កិច្ចប្រជុំក្រុមប្រឹក្សាខេត្ត កិច្ចប្រជុំគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាខេត្ត និងកិច្ចប្រជុំគណៈអភិបាលខេត្ត ប៉ុន្តែពុំមានសិទ្ធិអនុម័តឡើយ លើកលែងតែនាយករដ្ឋបាលសាលាខេត្តជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយរបស់ក្រុមប្រឹក្សាខេត្ត។

**មាត្រា ៤៧.-**

ក្នុងការចូលរួមក្នុងកិច្ចប្រជុំដូចមានចែងក្នុងមាត្រា៤៦នៃអនុក្រឹត្យនេះ និងការអនុវត្តការងារប្រចាំថ្ងៃ នាយករដ្ឋបាលសាលាខេត្ត អាចផ្តល់យោបល់ដល់ក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលរបស់ខ្លួន អំពីបញ្ហាច្បាប់ និងបច្ចេកទេស ដើម្បីធានាថាសេចក្តីសម្រេច និងសកម្មភាពនានារបស់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងអភិបាលខេត្ត មានលក្ខណៈសមស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបទដ្ឋានជាតិសម្រាប់សុវត្ថិភាពនិងគុណភាពដែលបានកំណត់ ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងសាលាខេត្ត។

**មាត្រា ៤៨.-**

ដោយមានការដឹកនាំ ណែនាំពីគណៈអភិបាលខេត្ត និងអភិបាលខេត្ត នាយករដ្ឋបាលសាលាខេត្តត្រូវធានាឱ្យនាយកទីចាត់ការ មន្ត្រី បុគ្គលិកទាំងអស់អនុវត្តការងារឱ្យបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីនានា និងការសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។

ក្នុងការសិក្សាខាងលើនេះ គ.ជ.អ.ប. ត្រូវធ្វើការពិគ្រោះយោបល់និងធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំយុទ្ធសាស្ត្រ និងដំណាក់កាលសមស្របក្នុងដំណើរការធ្វើសមាហរណកម្មនេះ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា ២១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ២១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២១៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល

## រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ពីគោលការណ៍ យន្តការ និងនីតិវិធីសម្រាប់ការពិគ្រោះយោបល់ក្នុងការរៀបចំការគ្រប់គ្រងនិងការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចមានកំណត់ត្រង់មាត្រា៣៨និងមាត្រា៣៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ២.-**

រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងអនុក្រឹត្យនេះ សំដៅត្រឹមតែរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមិនត្រូវអនុវត្តចំពោះការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ លើកលែងតែសកម្មភាពមួយចំនួនដែលទាក់ទងនឹងការចូលរួមរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍក្រុង ស្រុក ខណ្ឌ។

ផែនការអភិវឌ្ឍនិងកម្មវិនិយោគរបស់ខណ្ឌ សង្កាត់ ត្រូវដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់រាជធានីភ្នំពេញ។

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់សង្កាត់ក្នុងក្រុង ត្រូវដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់ក្រុង។

**មាត្រា ៤.-**

ផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រើប្រាស់ធ្វើជាមូលដ្ឋានយុទ្ធសាស្ត្រសម្រាប់ណែនាំរាល់ការធ្វើសេចក្តីសម្រេចក្នុងការងារអភិវឌ្ឍ ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលនឹងត្រូវទទួលហិរញ្ញប្បទានក្រោមក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងធនធាន ថវិកាពីប្រភពនានាតាមលទ្ធភាពជាក់ស្តែង។ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី២

## គោលការណ៍រួម

## នៃការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល

## របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ៥.-**

ការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រព្រឹត្តទៅតាមគោលការណ៍រួម ដូចខាងក្រោម ÷

- ការចែករំលែកព័ត៌មាន
- តម្លាភាព
- សង្គតិភាពនិងសុខដុមនីយកម្ម
- ការចូលរួមពិគ្រោះយោបល់ជាទូទៅ
- ការឆ្លើយតបនឹងតម្រូវការ
- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
- ប្រសិទ្ធភាពនិងសុក្រឹតភាពសេដ្ឋកិច្ចនិងសង្គម
- ការធានាចីរភាពធនធានធម្មជាតិនិងបរិស្ថាន
- ការធានាសមធម៌។

## ជំពូកទី៣
## យន្តការនិងភារកិច្ចក្នុងការកសាងនិងអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**មាត្រា ៦.-**

ក្រុមប្រឹក្សាទទួលខុសត្រូវ ៖

- ណែនាំគោលនយោបាយទូទៅសម្រាប់រៀបចំខ្លឹមសារផែនការអភិវឌ្ឍ រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយរក្សាសង្គតិភាពជាមួយក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងថវិកាប្រចាំឆ្នាំនិងធនធានថវិកាពីប្រភពនានាតាមលទ្ធភាពជាក់ស្តែង
- ពិនិត្យនិងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យនិងអនុម័តផែនការអភិវឌ្ឍនៅឆ្នាំទីមួយនៃអាណត្តិរបស់ខ្លួន និងកម្មវិធីវិនិយោគបីឆ្នាំរំកិលជារៀងរាល់ឆ្នាំ
- ពិនិត្យនិងអនុម័តសំណើកែតម្រូវផែនការអភិវឌ្ឍក្នុងករណីចាំបាច់
- ផ្តល់សុពលភាពដល់លទ្ធផលត្រួតពិនិត្យនិងវាយតម្លៃអំពីការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលរាយការណ៍ដោយគណៈអភិបាល។

**មាត្រា ៧.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សា ទទួលខុសត្រូវ ៖

- សម្របសម្រួលការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល

- ពិនិត្យនិងជូនយោបល់ទៅក្រុមប្រឹក្សា មុនធ្វើការអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យនិងជូនយោបល់ទៅក្រុមប្រឹក្សាលើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល។

**មាត្រា ៨.-**

គណៈអភិបាល ទទួលខុសត្រូវ ៖

- ដឹកនាំការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលជារៀងរាល់ឆ្នាំនៅថ្នាក់រដ្ឋបាលខ្លួន ស្របតាមការណែនាំពីក្រុមប្រឹក្សា ដូចបានកំណត់ក្នុងមាត្រា៦ខាងលើ ដោយធានាលក្ខណៈសង្គតិភាពរវាងខ្លឹមសាររបស់ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ជាមួយនឹងផែនការនិងគោលការណ៍ជាធរមាននានារបស់ជាតិ របស់រដ្ឋបាលថ្នាក់លើ និងផ្តោះទៅរកការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ
- ដឹកនាំសិក្ខាសាលា វេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ចាត់ចែងអនុវត្តនិងតាមដានពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រាយការណ៍ជូនគ្រប់អង្គប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាមួយនឹងអនុសាសន៍ចាំបាច់ សម្រាប់លើកកម្ពស់ការអនុវត្តផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សារួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រងនិងការត្រួតពិនិត្យរបស់ ៖
    - ក្រុមប្រឹក្សារួមគ្នា
    - ប្រភេទក្រុមប្រឹក្សាផ្សេងៗ
    - ក្រសួង ស្ថាប័នឬអង្គភាពនានារបស់រាជរដ្ឋាភិបាល
    - ដៃគូពាក់ព័ន្ធនានា
- ធានាឱ្យមានអន្តរាគមន៍រហ័សក្នុងការដោះស្រាយការលំបាកឬបញ្ហានានាដែលកើតមានឡើងជាយថាហេតុក្នុងអំឡុងពេលអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល។

**មាត្រា ៩.-**

តាមការឯកភាពពីក្រុមប្រឹក្សានិងដោយមានការគាំទ្រពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈអភិបាលរាជធានី ខេត្ត ត្រូវបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់ខ្លួន។ ក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ ត្រូវមានសមាសភាពយ៉ាងតិច ៖

- អភិបាលរាជធានី ខេត្ត ប្រធាន

- អភិបាលរងរាជធានី ខេត្ត០១រូប អនុប្រធាន
- នាយករដ្ឋបាលសាលារាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរផែនការរាជធានី ខេត្ត សមាជិកអចិន្ត្រៃយ៍
- ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត សមាជិក
- នាយកទីចាត់ការហិរញ្ញវត្ថុក្រុមប្រឹក្សារាជធានី ខេត្ត សមាជិក
- ប្រធានឬតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ សមាជិក
- ប្រធានឬតំណាងមន្ទីរនិងអង្គភាពជំនាញនានានៅរាជធានី ខេត្ត សមាជិក
- នាយកឬតំណាងទីចាត់ការចំណុះសាលារាជធានី ខេត្ត សមាជិក

**មាត្រា ១០.-**

តាមការឯកភាពពីក្រុមប្រឹក្សានិងដោយមានការគាំទ្រពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់ខ្លួន។ ក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ ត្រូវមានសមាសភាពយ៉ាងតិច ÷

- អភិបាលក្រុង ស្រុក ខណ្ឌ ប្រធាន
- អភិបាលរងក្រុង ស្រុក ខណ្ឌ០១រូប អនុប្រធាន
- នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ សមាជិក
- ប្រធានការិយាល័យផែនការ ស្ថិតិក្រុង ស្រុក ខណ្ឌ សមាជិកអចិន្ត្រៃយ៍
- ប្រធានការិយាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌ សមាជិក
- ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុសាលាក្រុង ស្រុក ខណ្ឌ សមាជិក
- ប្រធានឬតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ សមាជិក
- តំណាងអង្គភាពគាំទ្រឃុំ សង្កាត់ សមាជិក
- ប្រធានឬតំណាងការិយាល័យនិងអង្គភាពជំនាញនានានៅក្រុង ស្រុក ខណ្ឌ សមាជិក
- ប្រធានឬតំណាងការិយាល័យចំណុះសាលាក្រុង ស្រុក ខណ្ឌ សមាជិក

**មាត្រា ១១.-**

ក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ មានភារកិច្ច ÷

- រៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលជូនគណៈអភិបាល
- ជួយគណៈអភិបាល ធ្វើការរៀបចំសិក្ខាសាលា វេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយផ្អែកលើលទ្ធផលរបស់សិក្ខាសាលានិងកិច្ចប្រជុំពិគ្រោះយោបល់នានា។

## ជំពូកទី៤
## នីតិវិធី
## ការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**មាត្រា ១២.-**

ក្នុងឆ្នាំទីមួយនៃអាណត្តិរបស់ខ្លួន ក្រុមប្រឹក្សាត្រូវកសាងផែនការអភិវឌ្ឍដែលមានសុពលភាពរយៈពេលប្រាំឆ្នាំ និងរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលលើកទី១ សម្រាប់ថ្នាក់រដ្ឋបាលខ្លួន។ កម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

**មាត្រា ១៣.-**

ក្នុងការរៀបចំនិងអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវមានការពិគ្រោះយោបល់ជាមួយនឹង ÷

- ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ប្រភេទក្រុមប្រឹក្សាដទៃទៀតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- និងអ្នកពាក់ព័ន្ធនានា។

**មាត្រា ១៤.-**

វិធីសាស្ត្រសម្រាប់ធ្វើការប្រជុំពិគ្រោះយោបល់អំពីការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវកំណត់ដោយក្រុមប្រឹក្សា តាមតម្រូវការចាំបាច់។

រាល់សេចក្តីសម្រេចរបស់កិច្ចប្រជុំរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ជាធាតុចូលសម្រាប់ក្រុមប្រឹក្សាធ្វើការពិនិត្យនិងអនុម័តលើសេចក្តីព្រាង។

**មាត្រា ១៥.-**

ក្នុងកិច្ចប្រជុំរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ត្រូវមានការចូលរួមពីប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ ពីក្រុង ស្រុក ខណ្ឌនៅក្នុងរាជធានី ខេត្ត។

**មាត្រា ១៦.-**

ក្នុងកិច្ចប្រជុំរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុង ស្រុក ខណ្ឌ ត្រូវមានការចូលរួមពីមេឃុំ ចៅសង្កាត់ និងអ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំ សង្កាត់ ពីឃុំ សង្កាត់នីមួយៗនៅក្នុងក្រុង ស្រុក ខណ្ឌ។

# ជំពូកទី៥
## ការអនុម័ត ការចាត់ចែងអនុវត្ត
## ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**មាត្រា ១៧.-**

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវអនុម័តដោយសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្ដាលនៃសមាជិកទាំងអស់របស់ក្រុមប្រឹក្សា។

**មាត្រា ១៨.-**

សេចក្ដីស្នើកែសម្រួលលើផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវអនុម័តដោយសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្ដាលនៃសមាជិកទាំងអស់របស់ក្រុមប្រឹក្សា។

**មាត្រា ១៩.-**

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវតម្កល់ទុកជាឯកសារមួយច្បាប់នៅសាលារាជធានី ខេត្ត មួយច្បាប់នៅមន្ទីរផែនការរាជធានី ខេត្ត មួយច្បាប់នៅក្រសួងមហាផ្ទៃ មួយច្បាប់នៅក្រសួងផែនការ។

**មាត្រា ២០.-**

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវតម្កល់ទុកជាឯកសារមួយច្បាប់នៅសាលារាជធានី ខេត្ត មួយច្បាប់នៅមន្ទីរផែនការរាជធានី ខេត្ត មួយច្បាប់នៅសាលាក្រុង ស្រុក ខណ្ឌ។

**មាត្រា ២១.-**

ក្រុមប្រឹក្សាត្រូវផ្សព្វផ្សាយជាសាធារណៈនិងបន្ទាន់នូវផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល បន្ទាប់ពីអនុម័តរួច ជូនសាធារណជន និងភាគីពាក់ព័ន្ធបានដឹង។

**មាត្រា ២២.-**

ក្រុមប្រឹក្សាត្រូវណែនាំឱ្យគណៈអភិបាលចាត់ចែងអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័ត ដោយមានតម្លាភាព មានគណនេយ្យភាព មានការចូលរួម និងមានប្រសិទ្ធភាព។

**មាត្រា ២៣.-**

ករណីក្រុមប្រឹក្សាត្រូវបានរំសាយមុនអាណត្តិ ក្រុមប្រឹក្សាថ្មីដែលទទួលការងារបន្តអាចទទួលយកផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលមុនទាំងស្រុងឬអាចរៀបចំកែសម្រួលផែនការអភិវឌ្ឍសម្រាប់រយៈពេលដែលនៅសល់របស់អាណត្តិ។

**មាត្រា ២៤.-**

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល មានសុពលភាពរហូតដល់មានផែនការអភិវឌ្ឍថ្មី និងកម្មវិធីវិនិយោគបីឆ្នាំរំកិលថ្មីដែលបានអនុម័តដោយក្រុមប្រឹក្សាអាណត្តិបន្ទាប់។

## ជំពូកទី៦

## ការតាមដាន វាយតម្លៃ និងរបាយការណ៍

**មាត្រា ២៥.-**

ក្រុមប្រឹក្សាត្រូវចាត់ចែងឱ្យមានការតាមដានពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងបណ្តាសកម្មភាពពាក់ព័ន្ធដែលអនុវត្តដោយស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិនានា និងផ្នែកឯកជននៅក្នុងដែនដីរដ្ឋបាលរបស់ខ្លួន។

**មាត្រា ២៦.-**

នៅចុងឆ្នាំសារពើពន្ធនីមួយៗ គណៈអភិបាលត្រូវដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ជូនក្រុមប្រឹក្សាពិនិត្យ។ របាយការណ៍ប្រចាំឆ្នាំត្រូវមាន ÷

- វឌ្ឍនភាពការងារអនុវត្តក្នុងឆ្នាំកន្លងមក
- ទិសដៅការងារសម្រាប់អនុវត្តក្នុងឆ្នាំខាងមុខ
- សេចក្តីសន្និដ្ឋានរួម។

**មាត្រា ២៧.-**

ក្រុមប្រឹក្សាត្រូវអនុម័តនិងផ្ញើជូនទៅគ្រប់ថ្នាក់ពាក់ព័ន្ធមានសមត្ថកិច្ចនូវរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្នុងអំឡុងពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធនីមួយៗ។

**មាត្រា ២៨.-**

សេចក្តីណែនាំលំអិតសម្រាប់អនុវត្តការកសាងនិងការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្នុងអនុក្រឹត្យនេះ ត្រូវកំណត់និងអាចធ្វើបច្ចុប្បន្នភាពតាមតម្រូវការជាក់ស្តែង ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃនិងក្រសួងផែនការ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា ២៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៥ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា៣០*
*-រាជកិច្ច*
*-ឯកសារ កាលប្បវត្តិ*